ប្រវត្តិនៃការនេសាទរបស់ព្រឹទ្ធាចារ្យ នៅខេត្តកំពង់ធំ

FACT

Sustainable Livelihoods

សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល

# ទន្លេសាបខ្ញុំ



មេសា - ២០០៥

ម.ឯ.ឯ.ក AIDOC
Code: 142-024
Date:
Donated by:

# ទន្លេសាបខ្ញុំ

រៀបចំដោយ

លោក ឯម ច័ន្ទណារិទ្ធ (FACT/CWS)
ក.សេង ផល្លា (FACT)
លោក ឡុង លីហ៊ួរ (ADHOC)
លោកស្រី ជុំ ចន្ទ័ពុទ្ធារី (COWS)
លោក ហ៊ុយ ថុល (WFYD)
លោក អុំ ថាច់ អនុសីយ៍ឯក
លោក ជួប ជន់ជា (OKRCD)
លោក ស៊ុំ សុង (FYDO)
លោក ឡុង ឆាន (COP)
លោក ឈន ថៃ (WFY)
លោក គិត សៀប (CODEC)
លោក កង សាអ៊ុំ (HOM)
លោក អាំ សេន (CODEC)
លោក អាំ សេន (DOCS)

មេសា ២០០៩

# អារម្ភកថា

បឹងទន្លេសាប គឺជាប្រភពធនធានដ៏មានសារៈសំខាន់សំរាប់ទ្រទ្រង់សេដ្ឋកិច្ចជាតិ ហើយប្រជាពលរដ្ឋកម្ពុជាទូទាំងប្រទេស ជាពិសេសអ្នករស់នៅជនបទពឹងផ្អែកទាំងស្រុងទៅលើធនធានជលផល បន្ទាប់ពីស្រូវ។ ដោយសារបឹងទន្លេសាបបានផ្តល់នូវសារៈប្រយោជន៍ដ៏លើសលប់ ទើបអង្គការសម្ពន្ធ័ភាព ដើម្បីអភិរក្សធនធានជលផល **(FACT)** បានចុះទៅប្រមូលរឿងដើម្បីចងក្រងទុកជាឯកសារស្តីពីប្រវត្តិពិតរបស់អ្នកនេសាទនៅជុំវិញបឹងទន្លេសាប ក្នុងគោលបំណងឆ្លុះបញ្ចាំងពីតថភាពពិតនៃបឹងទន្លេសាបដែលមានទំនាក់ទំនងយ៉ាងជិតស្និតទៅជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជំនឿទំនៀមទំលាប់ប្រពៃណី ប្រវត្តិទីតាំងភូមិសាស្រ្ត។ ការសិក្សាស្រាវជ្រាវនេះត្រូវធ្វើឡើងតាមរយៈការសំភាសន៍ជាមួយមនុស្សដែលមានវ័យចំណាស់ក្នុងភូមិ ឬអ្នកដែលអាចចងចាំបានល្អពីភាពសំបូរធនធាន នៅក្នុងបឹងទន្លេសាបកាលពីអតីតកាលពីប្រវត្តិបឹងបួរជំនឿផ្សេងៗ សកម្មភាពនេសាទ ប្រវត្តិទីតាំងភូមិសាស្រ្ត ជាដើម ។

ប្រសិនជាគ្មានការប្រមូលកត់ត្រាទុកទេរឿងទាំងនេះមានការរាយប៉ាយ និងបាត់បង់នូវឯកសារមួយដ៏មានតំលៃជាក់ជាពុំខាន ដោយហេតុនេះបានជាអង្គការសម្ពន្ធ័ភាពដើម្បីអភិរក្សធនធានជលផលខិតខំស្រាវជ្រាវ និងចងក្រងពីប្រវត្តិអ្នកនេសាទក៏ដូចជាប្រវត្តិទីតាំងភូមិសាស្រ្តនៅជុំវិញបឹងទន្លេសាបដោយមានខេត្តចំនួន៥រួមមាន ខេត្តកំពង់ធំ ពោធិ៍សាត់ បាត់ដំបង កំពង់ឆ្នាំង និងខេត្តសៀមរាប។ ក្នុងការចុះប្រមូលរឿងក្រុមសម្ពន្ធ័ភាពដើម្បីអភិរក្សធនធានជលផល បានចូលរួមសហការពីបណ្តាអង្គការនានា នៅ

តាមខេត្តនីមួយៗដោយបានជួយជ្រោមជ្រែងអស់ពីកំលាំងកាយ និងកំលាំងចិត្ត ទើបអាចផលិតចេញជាកូនសៀវភៅមួយសំរាប់ទុកជាឯកសារ ដល់អ្នកដែលចាប់អារម្មណ៍ ឬអ្នកស្រាវជ្រាវបន្តទៀត ។

ជាទីបញ្ចប់ អង្គការសម្ពន្ធ័ភាពដើម្បីអភិរក្សធនធានជលផលសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះប្រជាពលរដ្ឋខេត្តទាំង៥ ដែលបានរួមសហការផ្តល់ជាកិច្ចសំភាសន៍ទាក់ទងនឹងប្រវត្តិផ្ទាល់ខ្លួនក៏ដូចប្រវត្តិផ្សេងៗ ដែលមានប្រយោជន៍សំរាប់ក្រុមការងាររបស់អង្គការយើងខ្ញុំ ជាពិសេសសូមថ្លែងអំណរគុណចំពោះអង្គការអុកស្វាមមេរិកកាំង (Oxfam America) ដែលបានផ្តល់ជាមូលនិធិសំរាប់ការសិក្សាស្រាវជ្រាវនេះ ។

ក្រុមការងារយើងខ្ញុំនឹងរង់ចាំទទួលការរិះគន់កែលំអរពីសំណាក់មិត្តអ្នកអានក៏ដូចជាប្រជាពលរដ្ឋគ្រប់រូប ដើម្បីធ្វើអោយស្នាដៃនេះកាន់តែមានលក្ខណៈប្រសើរ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២៥ ខែ មិនា ឆ្នាំ ២០០៥

ដោយសម្ពន្ធ័ភាពដើម្បីអភិរក្សធនធានជលផល

# មាតិកា


-ប្រវត្តិបឹងបបែល .......... ១
-ប្រវត្តិបឹងរៀល .......... ៧
-ប្រវត្តិបឹងក្បាលក្របី .......... ១១
-ប្រវត្តិបឹងសណ្ដាយ .......... ១៥
-ប្រវត្តិបឹងខែលមាស .......... ១៩
-ប្រវត្តិបឹងបន្ទះជាល .......... ២៤
-ប្រវត្តិឡូតិ៍បំរុង .......... ២៩
-ប្រវត្តិបឹងកន្សោមចាប .......... ៣៣
-ប្រវត្តិបឹងរាល .......... ៣៨
-ប្រវត្តិបឹងក្បាលព្រួស .......... ៤២
-ប្រវត្តិបឹងដំរីស្លាប់ .......... ៤៦
-ប្រវត្តិបឹងពាក់ព្រ័ទ្ធ .......... ៥០
-ប្រវត្តិបឹងតាពីរ .......... ៥៤
-ប្រវត្តិបឹងកាប់ផ្សោត .......... ៥៨
-ប្រវត្តិបឹងពាក់ថែប .......... ៦២
-ប្រវត្តិបឹងអន្ទង់ .......... ៦៦
-ប្រវត្តិបឹងប្រវែង .......... ៧១
-ប្រវត្តិបឹងផ្សោត .......... ៧៥
-ប្រវត្តិបឹងតាសែង .......... ៨០
-ប្រវត្តិបឹងភក់ .......... ៨៥

# ប្រវត្តិបឹងបបែល

ខេត្តកំពង់ធំ គឺជាខេត្តមួយស្ថិតនៅចំកណ្តាលនៃប្រទេសកម្ពុជា និងមានស្រុកចំនួន០៨ បើយើងធ្វើដំណើរពីខេត្តទៅភ្នំពេញ គេត្រូវឆ្លងកាត់ស្រុកបីគឺស្រុកស្ទឹងសែន ស្រុកសន្ទុក និងស្រុកបារាយណ៍។ ដោយឡែកស្រុកបារាយណ៍ ជាស្រុកមួយសំបូរទៅដោយបឹងធំជាច្រើន ដែលទទួលរបបទឹកពីបឹងទន្លេសាបនៅរដូវវស្សា ជារៀងរាល់ឆ្នាំ ជាក់ស្តែងដូចជា *បឹងបបែល* ។

តាមការសំភាសន៏របស់លោកតា **យ៉ិន ស៊ីម** មានអាយុ៦៨ឆ្នាំ និងមានស្រុកកំណើតនៅភូមិកងមាស ឃុំត្នោតជុំ ស្រុកបារាយណ៏ ខេត្តកំពង់ធំបាន



**លោកតា យ៉ិន ស៊ីម ជាប្រជាពលរដ្ឋនៅភូមិកងមាស**

រៀបរាប់ពីជីវិតផ្ទាល់ខ្លួនថា គាត់មានកូនចំនួន៦នាក់ក្នុងនោះ មានប្រុស ៣នាក់ ប្រពន្ធរបស់គាត់មានឈ្មោះ **យាយ វុធ** ។ កាលពីដើម គាត់ជាប្រជាកសិករ និងជាអ្នកនេសាទម្នាក់ ដែលតែងតែទៅនេសាទនៅក្នុងបឹងបបែលនេះ តាំងតែពីតូចមក ទាំងប្រាំង និង វស្សា។ សព្វថ្ងៃនេះគាត់បានចូលរក្សាសីលនៅវត្តកងមាស ឃុំត្នោតជុំ ស្រុកបារាយ-ណ៏។ គាត់បានមានប្រសាសន៏បន្តទៀតថា បឹងបបែលជាបឹងមួយដែលស្ថិតនៅភូមិកងមាស ឃុំត្នោតជុំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ដែលមានចំងាយពី

ភូមិកងមាស៥គីឡូម៉ែត្រ និងចំងាយពីបឹងទន្លេសាប ប្រហែល៨០ទៅ៩០គីឡូម៉ែត្រ ហើយបើគិតពីខេត្តកំពង់ធំមានចំងាយ ៥២គីឡូម៉ែត្រ។ បឹងនេះមានរាងទ្រវែង ដែលមានបណ្តោយពីជើងទៅត្បូង និងទទឹងពីកើតទៅលិច។ កាលពីដើមឡើយ បឹងនេះមានបណ្តោយប្រវែង២គីឡូម៉ែត្រ និងទទឹង១គីឡូម៉ែត្រ។ នៅរដូវវស្សា



ទិដ្ឋភាពបឹង បបែលមើលពីចំងាយ

បឹងនេះមានជំរៅជ្រៅបំផុតនោះ គឺ១៥ម៉ែត្រ និងកន្លែងរាក់ល្មម គឺប្រហែលជា ១០ម៉ែត្រ។ នៅរដូវប្រាំងបឹងនេះជំរៅនៅកន្លែងរាក់ល្មម ប្រហែលជា៥ម៉ែត្រ ទៅ៨ម៉ែត្រ។ នៅចំកណ្តាលបឹងមានអន្លង់ធំមួយ ហើយក្នុងអន្លង់នោះមានថ្មមួយដុំធ្លាក់ជារូបគោ ដែលជានិមិត្តរូបមួយសំរាប់អោយអ្នកនេសាទមកប្រាថ្នាសុំសេចក្តីសុខ។ គាត់បានបញ្ជាក់ទៀតថា ថ្មនេះគឺស័ក្តិសិទ្ធិណាស់បើគេប៉ងប្រាថ្នាចង់បានអ្វីគឺបានសំរេចដូចការប្រាថ្នា។ ក្រៅពីថ្មនេះ នៅមានវត្ថុបុរាណជាច្រើនទៀតដូចជា ចានបញ្ជុរុង ដែលមានរាងដូចជើងពាន និងសំណារព្រមទាំងមានរបស់របរជាច្រើនទៀត។ របស់របរទាំងនេះប្រជានេសាទតែងតែរកបាន ហើយយកទៅប្រើប្រាស់ជាធម្មតាគ្មាន បង្កភាពចង្រៃដល់ពួកគាត់ឡើយ។ បឹងនេះមានប្រពន្ធ័ផ្លូវទឹក៣ មួយជាអូរ និង២ទៀត ហៅថា ដៃអាវកក់ និងដៃដំរីជាន់ ព្រោះដៃនោះវាធ្លាក់ទៅដល់បឹងមួយឈ្មោះ បឹងដំរីជាន់។

ប្រពន្ធ័ផ្លូវទឹកទាំងនេះមានសារៈសំខាន់ណាស់ព្រោះទឹកនៅរដូវវស្សា ទឹកតែងតែហូរចូលមកបឹងបបែលនេះជារៀងរាល់ឆ្នាំ។ កាលពីដើមនៅក្នុងបឹងនេះ មានសត្វបបែលដ៏ធំរស់នៅ ប្រជាពលរដ្ឋដែលធ្វើដំណើរតាមបឹងនេះ តែងជួបប្រទះវាជាញឹកញាប់ ហើយវាតែងតែបង្កគ្រោះថ្នាក់ដូចជា កោសទូកមិនអោយទៅមុខ ទាល់តែនាំគ្នាធ្វើការបួងសួងសុំអង្វរដល់លោកតាម្ចាស់ទឹក ម្ចាស់ដី ទើបអាចបន្តដំណើរទៅមុខទៀតបាន។ លុះក្រោយមកទៀតមានថៅកែម្នាក់ឈ្មោះ **កែ ហាម៉ីងលី** ជាជនជាតិចិន និងជាអ្នកមានជាងគេនៅក្នុងស្រុកបារាយណ៍ បានមកធ្វើការទំនាក់ទំនងជាមួយមេភូមិ មេឃុំ ដើម្បីបង្ហូរទឹកចេញពីបឹងក្នុងគោលបំណងចាប់យកមច្ឆាជាតិ និងវត្ថុបុរាណដែលមានតំលៃនៅក្នុងបឹងនោះ។ ថៅកែនោះបានជីកព្រែកមួយចេញពីបឹងទៅស្ទឹងជីនិត ប្រវែងប្រហែលជាពគីឡូម៉ែត្រ ឃើញដូច្នេះបងប្អូនក៏នាំគ្នាទៅបន់ស្រន់បួងសួងសុំសេចក្ដីសុខពីលោកតាម្ចាស់ទឹកម្ចាស់ដី ដើម្បីកុំអោយទឹករីងពីបឹងនោះ រំពេចនោះស្រាប់តែមេឃប្រែជាខ្មៅងងឹត និងមានខ្យល់ធ្វើអោយសត្វបបែល និងត្រីតូចធំគ្រប់ប្រភេទក្នុងបឹងនោះ ផ្អើលចេញមកនៅតាមក្បែរមាត់បឹង ព្រមជាមួយភ្លៀងមួយមេយ៉ាងធំ និងមានរន្ទះបាញ់មកពីទិសខាងលិចមកកើតឈាងខាងជើងមាត់បឹង ធ្លាក់ចំអន្លង់មួយធ្វើអោយទឹកហូរចេញមកបង្កើតជាអន្លង់មួយហៅថា អន្លង់បឹងរន្ទះបាញ់ រីឯអណ្ដូង។ ចំពោះព្រែកជីកដែលថៅកែនោះបានជីកគេហៅថា ព្រែកមីងលី រហូតដល់សព្វថ្ងៃ។ ដោយឃើញស្ថានភាពដ៏អស្ចារ្យរបស់សត្វបបែល ប្រជាពលរដ្ឋក៏ហៅបឹងនោះថា បឹងបបែលរហូតមកដល់សព្វថ្ងៃនេះទៅ។ គាត់ក៏បានមានប្រសាសន៍ទៀតថា កាលពីដើម នៅជុំ

វិញបឹងនេះមានព្រៃរនាមដុះក្រាស់ណាស់ដូចជា ដើមត្រស់ ប្របួយ ថ្មើម អណ្តើក អញ្ចាញ ក្រេវ៉ាន់ ត្រសែង ជាំព្រីង ខ្ញុំ ផ្អោល ដើមត្រឡក ដើមរាំង ត្រសេក និងមានដើមឈើតូចៗជាច្រើនទៀត ដែលជាជំរករបស់មច្ឆាជាតិ ព្រមទាំងមានសត្វល្មូន បក្សាបក្សីគ្រប់ប្រភេទសត្វតូច ធំ។ ចំពោះដើមឈើដែលធំជាងគេមានកំពស់ចាប់ពី១៥ ទៅ២០ម៉ែត្រ ហើយមានទំហំដើមចាប់ពី៤ទៅ៦អោប វាមានសារៈសំខាន់ណាស់សំរាប់សត្វ តូច ធំដើម្បីពងកូន និងផ្តល់ជាទីជំរក ។

គាត់បានមានប្រសាសន៍ទៀតថា កាលគាត់អាយុ១៨ឆ្នាំ គាត់បានចេញទៅនេសាទជាមួយប្អូននៅក្បែរបឹងបបែលតាមទូក នៅពេលទៅដល់ដើមឈើធំមួយស្រាប់តែប្រទះឃើញសុទ្ធតែត្រីធំៗជាច្រើននៅក្រោមដើមឈើនោះ ពេលនោះគាត់ក៏អោយប្អូនងាកទូកទៅដើម្បីរើសត្រី ពេលទៅដល់ក៏ស្រាប់តែឃើញមានទាំងពងសត្វគ្រប់ប្រភេទ។ គាត់ចាប់ផ្តើមព្រឺក្បាលខ្លាកដោយខ្លាចសត្វអសិរពិស ដូចជាពស់ ជាពិសេសភ័យខ្លាចជួបសត្វដំរី និងសត្វខ្លា គាត់ក៏ប្រញាប់ប្រញាល់នាំប្អូនត្រឡប់មកផ្ទះវិញប្រកបដោយសុវត្ថិភាព។ គាត់បានបន្តទៀតថា កាលពីសម័យដើមនោះ សត្វមានច្រើនណាស់ដូចជា កុក ក្រសា ប្រវឹក ទោម រនាល ក្អែកទឹក មាន់ទឹក ស្មោញ ទង់ ត្រដេវិច លលក មៀម ខ្លែងស្រាក ត្រយង រស់នៅពាសពេញព្រៃ និងសត្វល្មូនមានដូចជា ក្រពើ ពស់វែកស្រវ៉ើ ពស់វែកក្របី ពស់ទ្រូងរនាម ពស់ក្រចាន់ ពស់ព្រលិត ពស់ថ្លាន់ អណ្តើក កន្ធាយ អន្ទង់។ សត្វក្រពើភាគច្រើនធំៗ ហើយពីដើមក្បាលរបស់វាប្រវែងចាប់ពីពាហត្ថ។ សត្វព្រៃវិញនោះមានដូចជា សត្វដំរី

ខ្លាតូច ខ្លាធំ ជ្រូកព្រៃ ឈ្លូស សត្វប្រើស សត្វរមាំង សត្វចចក ពួកនេះវាច្រើនតែរស់នៅនារដូវប្រាំង គឺចាប់ពីខែកក្តិក រហូតដល់ខែជេស ចំពោះត្រីវិញនោះមានដូចជា ត្រីរ៉ស់ ត្រីសណ្តាយ ត្រីឆ្តោរ ត្រីគល់រាំង ត្រីខ្ញឹង ត្រីគ្រុំ ត្រីក្អែក ត្រីពោធិ៍ ត្រីអណ្តែង ត្រីរាជ ត្រីដំរី និងត្រីតូចៗជាច្រើនទៀត។ កាលពីដើមត្រីដែលធំមានទំងន់ចាប់ពី៥០ទៅ៦០គីឡូក្រាម ភាគច្រើននៅក្នុងអន្លង់ជ្រៅ ចំពោះអ្នកមកនេសាទគេច្រើនមករកនេសាទនៅរដូវប្រាំង គឺចាប់ពីរដូវច្រូតកាត់រហូតដល់ខែឧសភា ទើបគេត្រលប់មកលំនៅដ្ឋានវិញ។ ពួកគេភាគច្រើនមកពីស្រុកបារាយណ៍ច្រើន ដោយចុះមកជាក្រុមបរទេះ មានទាំងប្រដាប់ប្រដាគ្រប់ប្រភេទដូចជា ស្នផ្លែមួយ សមផ្លែបី អង្រុតបង្កៃ អញ្ចងដែលធ្វើអំពីធ្មៃក្រឡា៨ហ៊ុន ក្រោយពីនេសាទបានហើយ គេច្រើនយកតែត្រីណាធំ ចំពោះត្រីតូចគេមិនយកទេ ភាគច្រើនគេយកវាធ្វើផ្អក ប្រហុក ត្រីងៀតប្រឡាក់ហាលទុកសំរាប់ខែធ្វើស្រែ ជាពិសេសពួកគាត់មិនដែលលក់ទេ គឺចែកគ្នាហូបក្នុងភូមិ ។

ក្នុងឆ្នាំ១៩៧០-១៩៨០ ត្រីត្រូវថយចុះបន្តិចម្តងៗ ចំណែកសត្វបក្សីនៅធម្មតាតែសត្វធំត្រូវបាត់ខ្លះ និងល្មូនត្រូវបាត់អស់មួយចំនួនដូចជាក្រពើ ជាពិសេសសត្វបបែលត្រូវដាច់ពូជ ហើយដើមឈើធំៗត្រូវគេកាប់អស់មួយចំនួនហើយ ។

ក្នុងកំឡុងឆ្នាំ១៩៨០-១៩៩៥ ព្រៃក្បែរនោះត្រូវប្រជាពលរដ្ឋកាប់បំផ្លាញដើម្បីធ្វើស្រែប្រាំងចំពោះសត្វដំរី ខ្លាតូចធំ ប្រើស រមាំង ឈ្លូស ជ្រូកព្រៃត្រូវបាត់បង់អស់ចំណែកត្រីក៏ត្រូវបាត់បង់មួយចំនួនដែរ។ លុះមកដល់ឆ្នាំ១៩៩៥ ដល់បច្ចុប្បន្ននេះ ព្រៃ

រនាមត្រូវបានគេកាប់ដើម្បីយកដីធ្វើស្រែអស់ហើយ ដែលធ្វើអោយសត្វត្រូវបាត់បង់ជំរក និងការបរបាញ់ ការបំពុលធ្វើអោយសត្វស្ទើរតែផុតពូជ នៅមានតែសត្វកុក ក្រសា ប្រវីក មាន់ទឹក ក្អែកទឹក ឯត្រីត្រូវគេរកបានច្រើនដែរតែច្រើនមានតូចៗ។ ចំណែកសត្វល្មូនវិញនៅតិចតួចបំផុតបាត់អស់ក្រពើ កន្ធាយ ពស់ទ្រូងរនាម។ ឥឡូវជំរៅទឹកបឹងកាន់តែរាក់ ពេលរដូវវស្សានៅតែ៧ម៉ែត្រ រដូវប្រាំងជំរៅតែ២.៥ម៉ែត្រ។ អ្នកមកនេសាទពួកគេច្រើនប្រើឧបករណ៍ទំនើបដូចជា ឆក់ អួនក្រឡាញ៉ឹក បំពុលត្រី សំរាស់ អញ្ចង លប ជុច បូមបាចអោយរីង ជាពិសេសការដួសកូនត្រី ការកៀរនឹងស្បៃមុង ដែលជាកត្តាមួយដែលធ្វើអោយត្រីត្រូវផុតពូជទាំងអស់ និងប្រជាពលរដ្ឋក៏ត្រូវអស់អ្វីពឹងពាក់ទៀតដែរ។ លោកតាបានសំណូមពរៈ

១-សុំអោយរដ្ឋាភិបាលនិងអង្គការជាតិ អន្តរជាតិជួយទប់ស្កាត់ចំពោះឧបករណ៍ខុសច្បាប់ ។

២-សុំកុំអោយប្រជាពលរដ្ឋកាប់ និងដុតព្រៃរនាម ជាពិសេសការដួសយកកូនត្រី ។

# ប្រវត្តិបឹងរៀល

កាលពីសម័យមុន ស្រុកបារាយណ៍គឺជាទីរួមខេត្តមួយដែលមានឈ្មោះថា ខេត្តបារាយណ៍ ដែលខាងលិចជាប់ជាមួយខេត្តកំពង់លែង តែបច្ចុប្បន្នគេហៅថា ខេត្តកំពង់ឆ្នាំង។ បើគេធ្វើដំណើរទៅទិសខាងលិចតាមភូមិចតុលោក ឃុំបារាយណ៍ និងជួបប្រទះនឹងបឹងមួយឈ្មោះថា បឹងរៀល ។

តាមការសំភាសន៍លោកតា **អ៊ុក រេន** អាយុ៨១ឆ្នាំ មានស្រុកកំណើតនៅ



លោកតា អ៊ុក រេន ជាប្រជាពលរដ្ឋនៅភូមិចតុលោក

ភូមិចតុលោក ឃុំបារាយណ៍ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ប្រពន្ធគាត់ឈ្មោះ **អ៊ុក ទីម**។ កាលពីដើមឡើយ គាត់ជាប្រជាកសិករ និងជាអ្នកនេសាទដែលចុះទៅនេសាទនៅបឹងរាលនេះតាំងពីអាយុ១៣ឆ្នាំមកម្ល៉េះ។ បឹងនេះមានទីតាំងស្ថិតនៅទិសខាងលិចនៃ ភូមិចតុលោកហើយមានចំងាយ៩គីឡូម៉ែត្រ ពីភូមិ និងចំងាយ១២គីឡូម៉ែត្រពីផ្លូវជាតិលេខ ៦ បើគិតពីខេត្តកំពង់ធំទៅបឹងមានចំងាយ៦២គីឡូម៉ែត្រ តែបើពីបឹងរាលទៅបឹងទន្លេសាបប្រហែល១២០គីឡូម៉ែត្រ។ នៅរដូវវស្សាបឹងនេះមានបណ្តោយ ៥គីឡូម៉ែត្រ និងទទឹង២គីឡូម៉ែត្រ ជំរៅពី១០ទៅ១៥ម៉ែត្រ ចំណែកនៅរដូវប្រាំងបឹងនេះ ជំរៅពី៧ ទៅ៨ម៉ែត្រ និងទទឹងពី១ទៅ១,៥គីឡូម៉ែត្រ។ លោកតាក៏មានប្រសាសន៍ទៀតថា បឹង

នេះមានព្រំប្រទល់ខាងកើតជាប់នឹងទួលតាសៀក ខាងលិចទល់ នឹងផ្លូវដំរី ខាងជើងទល់វាលស្មោញ និងត្រពាំងគល់ ខាងត្បូងទល់នឹងកំពង់លែង។ នៅក្នុងបឹងនោះមានអន្លង់ចំនួន៥គឺ អន្លង់គល់ អន្លងអាវពពេជ្យ អន្លង់រឹង អន្លង់ទាវ ក្រៅពីនោះ



ទិដ្ឋភាពបឹងរៀល មើលពីចំងាយ

បឹងនេះមានដៃខាងជើង គឺដៃពពេជ្យ ដៃឡាវ៉ៃ ដៃអន្លង់-ទាវ និងដៃបឹងប្រវឹក។ ខាងត្បូងមានដៃអន្លង់ត្រស់ និងដៃកាសាន ខាងលិចមានដៃបឹងរាលតូច ដៃផ្លូវដំរីជាប់ស្ទឹងស្លាប់។ គាត់បញ្ជាក់ទៀតថា កាលពីដើមនៅជុំវិញបឹងមានព្រៃរនាមដុះក្រាស់ និងដើមឈើធំៗដូចជាដើមតាឡូក ជាំព្រីង ត្រសែង ផ្គរ ភ្នំភ្លេង រាំង ទានព្រៃ ត្រែង និងដើមឈើធំៗប៉ុនកង់រទេះកំពស់១៥ទៅ ២០ម៉ែត្រ។ នៅក្នុងបឹងមានកំប្លោក ចក ត្រីបបឿន ចំពោះសត្វព្រៃសំបូរដូចជា ដំរីព្រៃ ក្របីព្រៃ រមាំង ខ្លា ភេ ស្វា ជ្រូកព្រៃ ខ្លាត្រី ពស់វែក។ នៅជិតខ្ទមអ្នកតាមានក្រពើអ្នកតាមួយដ៏ធំប៉ុនទូកប៉ុកចាយ ប្រវែងបណ្តោយ ២៥ម៉ែត្រ ទទឹង៥ម៉ែត្រ។ សត្វបក្សាបក្សីមាន កុក ទោម ត្មាត ស្មោញ ក្រៀល រនាល ក្អែកទឹក មាន់ទឹក ក្រសា ប្រវឹក ខ្វែក និងសត្វតូចៗជាច្រើនទៀត។ គាត់មានប្រសាសន៍ទៀតថា នៅក្នុងបឹងមានត្រីគ្រប់ប្រភេទដូចជា ត្រីសណ្តាយ រ៉ស់ ឆ្តោរ

ឈ្លូញ ខ្ជឹង ឆ្លាំង ក្រាយ ននេល ក្អី ដំរី ឆ្អិន គល់រាំង ជាដើម។ ត្រីធំៗអាចមានទំងន់ដល់ពី៣០ទៅ ៣៥គីឡូក្រាមដែលជាត្រីមេបឹង។ ចំពោះសត្វល្មូនមានក្រពើ អនរូង អណ្តើក គន្ធាយ ពស់តូចធំគ្រប់ប្រភេទ។ ក្រោយពីរដូវច្រូតកាត់ ហើយប្រជាពលរដ្ឋតែងនាំគ្នាចុះមកនេសាទនៅបឹងនេះ ហើយភាគច្រើនជាអ្នកស្រុកមកពីស្រុកបារាយណ៍និងចំការលើ ខេត្តកំពង់ធំ ដោយនាំគ្នាបររទេះចុះមក និងនាំមកជាមួយនូវឧបករណ៍នេសាទមាន ស្ន អង្រុត ចំរ៉ប បបក់ បង្កៃ សន្ទូចចង ផ្តាក់កាប់។ ប្រជាពលរដ្ឋដែលតែងមកនេសាទច្រើនយកតែត្រីណាធំៗធ្វើប្រហុក ត្រីងៀត ត្រីឆ្អើរទុកត្រៀមបំរុងធ្វើស្រែចំការរយៈពេល១ឆ្នាំ ហើយជំនាន់នោះពុំលក់ដូរទេ គឺចែកគ្នាហូបធម្មតា។ គាត់ក៏មានប្រសាសន៍ទៀតថា មូលហេតុដែលគេហៅថា បឹងរៀលនោះគឺកាលពីព្រេងនាយបឹងរៀលនេះ គឺសំបូរត្រីរៀលណាស់ និងសត្វក្រពើ (ជាពិសេសត្រីរៀលបារ៉ត និងក្រពើបារ៉ត)យ៉ាងធំ ហើយមានរូបចំលាក់លោកតាធ្វើពីថ្មខ្មៅពូកែណាស់ អ្នកស្រុកតែងធ្វើបុណ្យទានសែនព្រេនបន់ស្រន់ជារៀងរាល់ឆ្នាំ ពេលចុះទៅនេសាទម្តងៗ រឺក៏ចង់ធ្វើការងាររកន្លែងណាមួយ។ នៅថ្ងៃពេញបូរមីគេតែងតែលឺភ្លេងពិនពាទ្យ ហើយត្រីបារ៉ត និងក្រពើបារ៉តលេចឡើងព្រមទាំងត្រីសត្វមច្ឆាជាតិទាំងអស់ដោយឃើញភាពអស្ចារ្យបែបនេះទើបគេដាក់ឈ្មោះថា បឹងរាលរហូតមកដល់សព្វថ្ងៃនេះ។ បច្ចុប្បន្ននេះ បឹងរៀលនៅរដូវប្រាំងមានជំរៅតែ២ ទៅ៥ម៉ែត្រប៉ុណ្ណោះ ហើយទទឹងប្រវែង១គីឡូម៉ែត្រ ចំណែកនៅរដូវវស្សាជំរៅពី៧ម៉ែត្រទៅ១០ម៉ែត្រ និងទទឹងជាង២គីឡូម៉ែត្រ។ ចំពោះព្រៃឈើវិញ សព្វថ្ងៃឈើធំៗបានបាត់បង់អស់ទៅហើយ នៅ

តែព្រៃតូចៗ និងព្រៃរនាមនៅមានតិចតួចដែរ(ព្រៃរនាមបាត់បង់ដោយសារតែការកាប់រុករានព្រៃធ្វើស្រែ និងការដុតព្រៃដើម្បីចាប់សត្វ)។ ចំណែកសត្វវិញ សព្វថ្ងៃនេះគឺឈានទៅរកដាច់ពូជអស់ហើយ ដោយសារតែគ្មានទីជំរក ការបំពុល និងការបំផ្លាញរបស់មនុស្ស ជាពិសេសនៅសម័យសង្គ្រាម។ រីឯត្រីវិញគឺមានតិចប្រភេទណាស់ ចំពោះការបាត់បង់ច្រើនដូច ជាត្រីគល់រាំង ត្រីក្ហេ ត្រីទនេល ជាពិសេសពួកត្រីមេប៊ីង ហើយសត្វល្មូនត្រូវបាត់ផុតពូជដូចជាក្រពើ គន្ធាយ ពស់ លើសពីនេះទៀត គឺសត្វដំរី ខ្លា មិនឃើញមានតែម្តង ។

ដូចនេះក្នុងនាមគាត់ជាប្រជាពលរដ្ឋនៅក្នុងភូមិសំណូមពរអោយរដ្ឋាភិបាលមានគំរោងជួយអភិរក្សបឹងនេះឡើងវិញ និងលុបបំបាត់ចោលនូវការឆក់ ការដួសកូនត្រីកាប់ព្រៃ និងដុតព្រៃរនាម ។

# ប្រវត្តិបឹងក្បាលក្របី

បើយើងធ្វើដំណើរតាមផ្លូវជាតិលេខ០៦ ពីទិសខាងត្បូង ទៅទិសខាងជើងមក ស្រុកសន្ទុក ឆ្លងកាត់ស្ទឹងតាំងក្រសាំងមកដល់គល់ស្ពានស៊ីម៉ង់ នៅខាងស្តាំគល់ស្ពាន ប្រហែលជា១០ម៉ែត្រ យើងនឹងឃើញផ្លូវលំមួយក្រាលគ្រោះក្រហមឆ្ពោះទៅទិសខាង លិចដោយកាត់ភូមិពីរគឺភូមិសង់ឃ្លាំង និងភូមិចំបក់ជើង។ ចំងាយ៥គីឡូម៉ែត្រពីភូមិ ចំបក់ជើងស្របតាមស្ទឹងតាំងក្រសាំង យើងនឹងឃើញបឹងមួយដែលមានព្រៃរនាមដុះ នៅកណ្តាលបឹងនោះដែលគេហៅថា បឹងក្បាលក្របី ។

លុះយើងចូលមកដល់ភូមិចំបក់ជើង ឃុំតាំងក្រសាំង ស្រុកសន្ទុក ក្រុមការ-ងារបានជួបសំភាសន៍ជាមួយព្រឹទ្ធាចារ្យម្នាក់ដែលរស់នៅទីនោះ ឈ្មោះ **ង៉ិន គីមសន** អាយុ៧៣ មានកូន៦នាក់ ប្រុស១នាក់ ស្រី៥នាក់។ កាលពីអាយុ១៦ឆ្នាំ គាត់ជាប្រជា កសិករ ក្រៅពីនេះលោកក៏ជាអ្នកនេសាទនៅបឹងក្បាលក្របីនេះផងដែរ ។



**លោក ង៉ិន គីមសន ជាប្រជាពលរដ្ឋ**

លោកតាបានរៀបរាប់អោយដឹងថា បឹងនេះ មានចំងាយ៣០គីឡូម៉ែត្រ ពីកំពង់ធំ និង ចំងាយ១៥០គីឡូម៉ែត្រ ទៅបឹងទន្លេសាប និងមានព្រំប្រទល់ខាងជើងជាប់នឹងបឹងថ្នាន់ ខាងត្បូងជាប់ស្ទឹងជីនិត ខាងកើតជាប់វាល ស្រែតំបន់ព្រៃកក្របី ខាងលិចជាប់វាល ស្រែបឹងចក។នៅរដូវវស្សា បឹងនេះមាន ជំរៅ៥ម៉ែត្រមានបណ្តោយ៦០០ម៉ែត្រ

ទទឹង៤០០ម៉ែត្រ ហើយនៅរដូវប្រាំងមានជំរៅ២ម៉ែត្រ បណ្តោយ៤៥០ម៉ែត្រ ទទឹង ២៥០ម៉ែត្រ។ គាត់បានដំណាលប្រាប់យើងពីប្រវត្តិបឹងក្បាលក្របីនេះថា កាលពីដើមឡើយមានលោកតាម្នាក់ឈ្មោះថា តាគង់ រស់នៅភូមិចំបក់ គាត់ធ្វើស្រែនៅក្បែរមាត់បឹងមួយ ថ្ងៃមួយពេលគាត់ទៅស្រែពេលទៅដល់បឹងនោះ ក៏ប្រទះឃើញសត្វក្របីមួយដែលកំពុងលង់ត្រនេលបាស់ជើងឡើងលើទាំងបួន ហើយក្របីព្រៃនោះធំខ្លាំងណាស់ គុលស្នែងរបស់វាមួយជាន់ និងប្រអប់ជើងទំហំដល់ទៅ១.៥តឹក។ ពេលនោះ គាត់មានចិត្តក្លាហានក៏សំរេចចិត្តលោតទៅជាន់គុលស្នែងទាំងពីរដោយដៃម្ខាងកាន់ពូថៅរួចគាត់ក៏បានកាប់កក្របីរហូតដល់ស្លាប់ ហើយគាត់ក៏បានវះសាច់យកទៅផ្ទះ និងប្រាប់អ្នកភូមិអោយមកវះសាច់ក្របីនោះដែរ។ ពេលនោះប្រជាពលរដ្ឋក៏ផ្អើលទៅវះសាច់ក្របីនោះទាល់តែអស់។ ចាប់តាំងពីពេលនោះមក គេក៏នាំគ្នាដាក់ឈ្មោះបឹងនេះថា *បឹងក្បាលក្របី* រហូតមកដល់សព្វថ្ងៃនេះ។ លោកតាបានអោយដឹងទៀតថា បឹងក្បាលក្របីនេះកាលពីដើមមានត្រីច្រើនប្រភេទណាស់ដូចជា ត្រីរ៉ស់ ត្រីគល់រាំង ត្រីក្រាយ ត្រីឆ្តោរ ត្រីខ្ជឹង ត្រីដំរី ត្រីកែ្អក ត្រីគ្រុំ។ល។ ភាគច្រើនត្រីដែលធំជាងគេនៅក្នុងបឹងនោះគឺត្រីក្រាយ និងត្រីគល់រាំងដែលមានទំងន់ចាប់ពី១៥គីឡូក្រាម ទៅ២០គីឡូក្រាម។ នៅជុំវិញបឹងមានសុទ្ធតែព្រៃរនាមដុះជុំជិតពិបាកនឹងចូលណាស់ ហើយនៅក្នុងបឹងមានពពួករុក្ខជាតិគ្រប់ប្រភេទដូចជា សារាយ កំប្លោក ចក បៀន ស្រងែ កក់មូល ដែលជាចំនីរបស់ត្រីយ៉ាងសំបូរហូរហៀរ។ ក្រៅពីនេះមានដើមត្រសែង ដើមត្រឡក ដើមផ្ចោល ដើមរាំង ដើមតាអ្នួរដែលមានអង្កត់ផ្ចិតរហូតដល់១ម៉ែត្រ ដើមទាំងនេះបាន

ផ្តល់ជាជំរកដល់សត្វគ្រប់ប្រភេទ និងដើម្បីពងកូន។ កាលពីដើម ដោយសារតំបន់នេះមានលក្ខណៈអំណោយផលទើបធ្វើអោយសត្វសំបូរណាស់ដូចជាសត្វស្មោញ សត្វប្រវិក សត្វក្រសា សត្វកុក សត្វទោម សត្វមាន់ទឹក សត្វអកទឹក សត្វត្រដេវរិច និងសត្វលូនជាច្រើនដូចជាសត្វក្រពើ ពស់វែកស្រវ៉ើ ពស់វែកក្របី ពស់ទ្រូងរនាម ពស់ថ្លាន់ ពស់ក្រចាន់ ពស់ព្រៃ អណ្តើក កន្ធាយ។ លើសពីនេះមានសត្វធំៗដូចជាខ្លាធំ ខ្លាតូច ជ្រូកព្រៃ ឈ្លូស រមាំង ប្រើស ស្វា ដំរីដែលគេតែងតែប្រទះឃើញពួកនៅរជូវសំរក ដោយពួកវាចុះមកពីព្រៃខាងលើ។ គាត់បានរៀបរាប់ប្រាប់យើងពីប្រវត្តិរបស់គាត់កាលពីនៅក្មេងថា ថ្ងៃមួយគាត់បាននាំគ្នាទៅនេសាទនៅក្នុងបឹងនេះ ដោយមានទូកចំនួន៧ទូក ពេលមួយនោះក៏នាំគ្នារៀបចំចេញទៅបង់សំណាញ់មានគ្នាចំនួន ១០នាក់ ពេលអុំទូកទៅប្រហែលជា២០នាទីក៏ប្រទះឃើញហ្វូងដំរីមួយហ្វូងកំពុងឆ្លងកាត់ពេលនោះគាត់ក៏នាំគ្នីគ្នាអុំទូកកៀងដំរីអោយចុះទឹកកាន់តែជ្រៅ តែដំរីបែរជានាំគ្នាឡើងទៅលើទូលក្បែរបឹងវិញដោយឈរផ្ដុំគ្នាក្បាលចេញមកក្រៅ ហើយពួកគាត់ក៏ស្រែកប្រាប់គ្នាកុំអោយទូកថយក្រោយ អ្នកខ្លះស្រែកសន្ធប់ស្រាប់តែពេលនោះហ្វូងដំរីក៏បញ្ចេញសកម្មភាពដោយយកដៃញាត់មាត់វា ហើយបក់ត្រចៀកដាក់ពួកគាត់ មួយសន្ទុះក្រោយមកមេខ្យល់ដំរីក៏ស្រែកច្រេចៗ លើកដៃឡើងលើទៅទិសឥសានស្រាប់ហ្វូងដំរីក៏រត់ទៅទិសនោះអស់ទៅ។ គាត់មានប្រសាសន៍ទៀតថា កាលពីដើមមុខរបរសំខាន់របស់ប្រជាពលរដ្ឋ គឺការនេសាទនេះឯង ហើយប្រជានេសាទដែលតែងតែមកនេសាទនៅក្នុងបឹងនេះគឺច្រើនមកពីភូមិចំបក់ កងមាស ព្នៅ តាំងក្រសាំង ដោយ

ពួកគេច្រើនមកនេសាទនៅរដូវប្រាំងតាមរទេះ និងរដូវវស្សាតាមទូកដោយប្រើប្រាស់ឧបករណ៍ដូចជា ស្ទូ ផ្លែមួយ សមផ្លែបី អញ្ចងក្រឡាពី៦ទៅ៧ហ៊ុនធ្វើអំពីធ្មៃ អង្រុត់បង្កៃ សន្ទូច។ល។ ភាគច្រើននៅសម័យនោះ គេច្រើនយកតែត្រីណាធំៗ ដើម្បីធ្វើជាផ្អក ត្រីឆ្អើរ ត្រីងៀត ប្រហុក។ ក្នុងឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៩៥ បឹងក្បាលក្របីត្រូវបានគេកាប់ព្រៃរនាមអស់មួយចំនួនដើម្បីធ្វើស្រែ ចំណែកត្រីវិញនោះ គឺនៅសំបូរដដែល រីឯសត្វធំៗត្រូវបាត់អស់ជាច្រើន ជាពិសេសគឺសត្វដំរីត្រូវបាត់ពូជអស់ទៅហើយ។ បច្ចុប្បន្នត្រីនៅសល់តែត្រីតូចៗ ហើយត្រីធំៗកំរចាប់បានណាស់ បើចាប់បានអស់ធំបំផុតទំងន់ត្រឹមតែ០.៥គីឡូក្រាមប៉ុណ្ណោះ ព្រៃរនាមត្រូវគេបំផ្លាញអស់ដោយសារប្រជាពលរដ្ឋនាំគ្នាកាប់ព្រៃធ្វើស្រែប្រាំង ធ្វើចំការ និងដុតព្រៃដើម្បីចាប់សត្វធ្វើអោយពពួកសត្វព្រៃសត្វស្លាបត្រូវក្លាយទៅជាចំណីរបស់មនុស្ស ហើយសត្វខ្លះលែងរស់នៅតំបន់នេះទៀត ហើយវារត់ទៅនៅតំបន់ឆ្ងាយៗជិតព្រំដែន ខ្លះរស់នៅប្រទេសគេអស់ហើយ។ បើយើងមើលទៅផ្ទៃបឹងត្រូវរាក់ នៅរដូវវស្សាមានជំរៅតែ៤ម៉ែត្រ ហើយរដូវប្រាំងមានជំរៅតែ១ម៉ែត្រ នៅជុំវិញបឹងគឺហ៊ុំព័ទ្ធទៅដោយវាលស្រែរបស់ប្រជាពល-រដ្ឋ។ ការបាត់បង់ពូជត្រី គឺដោយសារតែការប្រើប្រាស់ឧបករណ៍ ឆក់ បូម បាចអួនក្រឡាញឹក សំរាស់ ជីកបៀ និងស្បៃមុង ជាពិសេស ការជួសយកកូនត្រីនៅរដូវត្រីពង។ ក្នុងនាមគាត់ជាប្រជាពលរដ្ឋខ្មែរមួយរូបសំណូមពរដល់រដ្ឋាភិបាលជួយធ្វើយ៉ាងណាទប់ស្កាត់កុំអោយឧបករណ៍ឆក់ទៀត ជាពិសេសការកាប់ព្រៃ ដុតព្រៃ និងការបំពុលសត្វគ្រប់ប្រភេទ និងជួយអភិរក្សព្រៃឡើងវិញផង ។

# ប្រវត្តិបឹងសណ្តាយ

សង្គមខ្មែរយើងចាប់តាំងពីបុរាណកាលមកមានប្រជាពលរដ្ឋភាគច្រើនជាកសិករ និងប្រកបមុខរបរនេសាទទៅតាមប្រពៃណី។ ដោយឡែកនៅក្នុងភូមិកងមាស ឃុំត្នោតជុំ ស្រុកបារាយណ៍មានបឹងមួយឈ្មោះថា បឹងសណ្តាយដែលទទួលរបបទឹកពីទន្លេសាបជារៀងរាល់ឆ្នាំ ។

បឹងសណ្តាយនេះមានចំងាយ៩គីឡូម៉ែត្រពីភូមិកងមាស ស្រុកបារាយណ៍ តែបើយើងគិតចាប់ពីខេត្តកំពង់ធំមកបឹងនេះមានចំងាយ៣៩គីឡូម៉ែត្រ ហើយបើគិតពីបឹងនេះទៅទន្លេសាបមានចំងាយប្រមាណ៩០គីឡូម៉ែត្រ។ បឹងនេះមានរាងទ្រវែងដែលមានបណ្តោយ ១គីឡូម៉ែត្រ និងទទឹង ២០០ម៉ែត្រ ។

ក្រុមអ្នកស្រាវជ្រាវបានជួបសំភាសន៍ជាមួយលោកតា **វ៉ាន់ ស៊ុយ** ដែលមាន-



**លោកតា វ៉ាន់ ស៊ុយ**

អាយុ៦៨ឆ្នាំ មានភូមិកំណើតនៅភូមិកងមាស ឃុំត្នោតជុំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ។ គាត់មានកូនចំនួន៧នាក់ ដែលមានស្រី៥នាក់ និងប្រុស២នាក់។ ចាប់តាំងពីគាត់មានអាយុ ១៨ឆ្នាំ គាត់ចាប់ផ្តើមប្រកបមុខរបរ ជាអ្នកនេសាទនៅបឹងសណ្តាយនេះ ក្រៅពីនេះគាត់គឺជាប្រជាកសិករផងដែរ។ រហូតមកដល់អាយុ៦២ឆ្នាំ ទើបគាត់ឈប់នេសាទដល់បច្ចុប្បន្ននេះ។ គាត់បានអោយដឹងថា មូលហេតុដែលគេដាក់ឈ្មោះថា បឹងសណ្តាយ

ព្រោះកាលពីយូរយារណាស់មកហើយ មាននារីមួយក្រុមទៅរកត្រីនៅបឹងនោះ ស្រាប់តែពេលកំពុងតែរក មានត្រីសណ្តាយមួយក្បាលយ៉ាងធំហែលមកដោល ហើយបុកត្រូវដោះនារីម្នាក់បណ្តាលអោយនារីម្នាក់នោះសន្លប់ ក្រោយមកក្រុមនារីផ្សេងៗទៀតក៏សែងនារីម្នាក់នោះទៅផ្ទះវិញ។ ដោយសារឃើញត្រីសណ្តាយធំពេកទើបគេហៅបឹងនេះថា *បឹងត្រីសណ្តាយ* តែក្រោយមកគេក៏ប្តូរហៅទៅជា *បឹងសណ្តាយ* រហូតមក។គាត់បានបន្តទៀតថា កាលពីដើមបឹងសណ្តាយនេះមានអន្លង់មួយនៅចំកណ្តាល និងមានជំរៅ៧ម៉ែត្រ ទៅ១០ម៉ែត្រ ហើយនៅរដូវប្រាំងមានជំរៅពី១,៥ទៅ ២ម៉ែត្រ បឹងនេះមានព្រំប្រទល់ខាងកើតទល់នឹងត្រពាំងលានកែវ ខាងលិចទល់នឹងណោងបោន ខាងជើងទល់នឹងអូតាធូ ខាងត្បូងទល់នឹងត្រពាំងពោធិ។ កាលនោះបឹងនេះហ៊ុំព័ទ្ធទៅដោយព្រៃរនាមក្រាស់ដូចជា ដើមកក់ អញ្ចាង ថ្លើមអណ្តើក និងដើមឈើធំៗជាច្រើនដូចជា ដើមត្រសែង ដើមផ្តៅល ដើមរាំង ហើយដើមទាំងនោះច្រើនទៀតសុទ្ធតែធំៗដុះពាសពេញព្រៃដែលធ្វើអោយទីនោះក្លាយទៅជាជំរកសត្វព្រៃមានទាំងដំរី ខ្លាតូច ធំ ឈ្លូស រមាំង ទន្សាយ ប្រើស មករស់នៅ។ គាត់បានរៀបរាប់ពីរឿងផ្ទាល់ខ្លួនថា កាលពីនៅតូចពេលរដូវទឹកសំរក គាត់តែងតែចេញទៅនេសាទជាមួយនឹងឪពុករបស់គាត់នៅក្នុងបឹងនោះ ដោយអុំទូកសំដៅទៅមាត់បឹងសណ្តាយខាងត្បូង។ កាលនោះគាត់បានឃើញដានក្រពើមួយដ៏ធំវារសំដៅទៅត្រពាំងតូចដៃអណ្តូងដែលមានដានទទឹង៧ហត្ថ។ ឪពុកគាត់ និងគាត់បានដោលទូកទៅតាមរកមើលដាននោះស្រាប់តែប្រទះឃើញក្រពើមួយធំកំពុងសំកាំងខ្លួនលើទួលមួយនៅពីមុខទូករបស់គាត់។ ដោយឃើញបែបនេះ គាត់ និងឪពុកក៏ដោលទូកត្រលប់មកវិញទាំងការភ័យខ្លាច។ ដោយឡែកព្រៃ

នៅជុំវិញបឹងនេះជាជំរករបស់បក្សាបក្សីគ្រប់ប្រភេទមាន ទោម ក្រសា កុក មៀម ខ្លែង គ្រៀល ត្រដក់ ស្មោញ ប្រវឹក រស់នៅពាសពេញព្រៃរនាម។ ចំណែកនៅក្នុងបឹងវិញមានកំប្លោក បឿន ក្រចាប់ សារ៉ាយទឹក និងរុក្ខជាតិជាច្រើនទៀតដែលធ្វើអោយត្រីនៅបឹងនេះសំបូរហើយធំៗទៀតដូចជា ត្រីរ៉ស់ ត្រីដំរី ត្រីស្លាត ត្រីគល់រាំង ត្រីសណ្តាយ ត្រីឆ្តោរ ត្រីខ្នាន់ ត្រីកេស ត្រីក្រាយ ត្រីខ្ទឹង និងត្រីធំៗជាច្រើនប្រភេទទៀតដែលមានទំងន់ចាប់ពី២០ ទៅ៣០គីឡូក្រាម និងត្រីប្រភេទតូចៗជាច្រើនទៀតនៅពេញបឹង។ នៅជុំវិញបឹងមានសត្វល្មូនជាច្រើនប្រភេទដូចជាអណ្តើក ក្រពើ គន្ធាយ និងពស់គ្រប់ប្រភេទ។ ដោយសារប្រជាពលរដ្ឋខ្មែរយើងពីមុនរស់នៅពឹងផ្អែកលើធនធាន ត្រីដូចនេះហើយមានអ្នកមកពីស្រុកបារាយណ៍ សន្ទុក តែងបរទេះមករកនេសាទត្រីនៅបឹងនេះ ដោយប្រើឧបករណ៍នេសាទដូចជា ស្នផ្លែមួយ សមផ្លែ៣ អញ្ចងក្រលាចាប់ពី៥ហ៊ុន។ ប្រជានេសាទរកត្រីបានពួកគេកំរធ្វើការលក់ដូរណាស់ ពួកគេច្រើនយកត្រីមកកែច្នៃធ្វើជាប្រហុក ផ្អក ត្រីងៀត ត្រីឆ្អើរ។ល។

គាត់បានមានប្រសាសន៍ទៀតថា ក្រោយសម័យសង្គ្រាមរាំរ៉ៃ បឹងនេះមានភាពប្រែប្រួលខ្លាំងណាស់ ជាពិសេសប្រជានេសាទក្រីក្រនាំគ្នាកាប់ព្រៃរនាម និងព្រៃលិចទឹកចាប់ដីធ្វើស្រែ និងធ្វើចំការអស់យ៉ាងច្រើន ដែលជាហេតុធ្វើអោយពពួកសត្វព្រៃគ្មានទីជំរកខ្លះនិងត្រូវគេបាញ់យកធ្វើជាអាហារខ្លះ តែគួរអោយស្តាយបំផុតនោះប្រភេទសត្វធំៗដូចជា ដំរីព្រៃ ខ្លា រមាំង ឈ្លូស ក្រពើ គន្ធាយ ពស់ធំៗគ្រប់ប្រភេទបានរត់ចោលព្រៃអស់ហើយ។ ដោយបច្ចុប្បន្ន បរិមាណប្រជាពលរដ្ឋចេះតែកើនឡើង តំរូវការក៏កាន់តែកើនឡើងដែរធ្វើអោយប្រជាពលរដ្ឋបានរុករានព្រៃក្បែរបឹងយកដីធ្វើ

ស្រែប្រាំង ហើយបានដុតព្រៃ ការបំពុល ការវាយលប់ដើម្បីចាប់សត្វ។ ធនធានធម្មជាតិសត្វព្រៃបានបាត់បង់អស់ទៅហើយ ចំណែកឯធនធានត្រីនៅក្នុងបឹងវិញមានសល់តិចតួចប៉ុណ្ណោះ ជាពិសេសត្រីសណ្តាយដែលធ្លាប់តែសំបូរនិងធំៗត្រូវបានបាត់អស់ទៅ ហើយបឹងនេះនៅសល់តែឈ្មោះជាប់រហូតមកដល់សព្វថ្ងៃនេះតែប៉ុណ្ណោះ។ បើយើងក្រឡេកទៅមើលទំហំបឹងនោះមានទំហំតូចជាងមុន ហើយកាន់តែរាក់ទៅៗនៅរដូវវស្សាទឹកមានជំរៅតែ៤ទៅ៥ម៉ែត្រប៉ុណ្ណោះ នេះដោយសារតែទឹកហូរច្រោះធ្វើអោយដីបាក់ហូរចូលទៅក្នុងបឹងព្រោះគ្មានព្រៃឈើជួយទប់ដី។ ពពួកសត្វព្រៃនៅតំបន់នេះបានផុតពូជអស់ទៅហើយ នៅឃើញមានតែសត្វស្លាបដូចជាកុក ក្រសាបន្តិចបន្តួចទេ ហើយនៅក្នុងបឹងមានត្រីតិចតួចដូចជា ត្រីកេស ត្រីដឺរី ត្រីឆ្កោ ត្រីឆ្អិនត្រីរ៉ស់ និងប្រភេទត្រីតូចៗជាច្រើនទៀត។ ឥឡូវនេះ មានអ្នកនេសាទច្រើនបានប្រើប្រាស់ឧបករណ៍ទំនើបៗខុសច្បាប់ដូចជា ឆក់ ឈឹប អួនក្រឡាញឹក សំរាស់ បៀរជាពិសេសការដួសកូនត្រីនូវរដូវត្រីពងកូន ចំណែកពពួកសត្វល្មូនគ្រប់ប្រភេទបានបាត់អស់ហើយ។ គាត់យល់ឃើញថា បើគ្មានការទប់ស្កាត់ទេនោះធនធានដែលធ្លាប់តែសំបូរប្រាកដជារលាយអស់នៅពេលឆាប់ៗខាងមុខនេះ។ គាត់បានសំនួមពរដល់អ្នកដែលពាក់ព័ន្ធ មន្ត្រីរាជការទាំងអស់សុំអោយជួយលុបបំបាត់ចោលអោយអស់នូវការប្រើប្រាស់ឧបករណ៍ទំនើបដូចជាការកាប់ព្រៃ ដុតព្រៃ បូមបាចបឹងដើម្បីចាប់ត្រី និងជួយអភិរក្សធនធានដែលកំពុងមានដើម្បីអោយប្រទេសយើងសំបូរធនធានដូចពីមុនវិញ។

# ប្រវត្តិបឹងខែលមាស

ស្រុកបារាយណ៍ជាស្រុកមួយដែលស្ថិតនៅទិសខាងត្បូងឈាង ខាងលិចនៃខេត្តកំពង់ធំ ស្រុកនេះខាងលិចជាប់ ជាមួយបឹងទន្លេសាបរហូតទៅដល់ព្រំប្រទល់ខេត្តកំពង់ឆ្នាំង នៅទិសនិរតីមានព្រំប្រទល់ជាប់ជាមួយខេត្តកំពង់ចាម បើយើងធ្វើដំណើរទៅទិសខាងត្បូងឈាងខាងលិច និងឆ្លងកាត់ភូមិកងមាស ឃុំត្នោតជុំដែលជាភូមិមួយមានបឹងដែលទាក់ទងជាមួយនឹងប្រវត្តិសាស្ត្ររវាងសង្គ្រាមខ្មែរជាមួយសៀម នោះគឺបឹងខែលមាស ។

តាមការសំភាសន៍លោកតាឈ្មោះ **ប៊ុន ស៊យ** ដែលមានអាយុ ៦៣ឆ្នាំ និងមានកូន៦នាក់ ស្រីពនាក់ ប្រុសពនាក់ គាត់មានស្រុកកំណើតនៅភូមិកងមាស ឃុំត្នោតជុំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ។ ចាប់តាំងពីអាយុ៦ឆ្នាំ គាត់តែងទៅឃ្វាលក្របីនៅក្បែរបឹងនោះ ហើយទៅរកនេសាទត្រីនៅបឹងនោះព្រមទាំងជាប្រជាកសិករផងដែរ។ គាត់មានប្រសាសន៍ថាបឹងខែលមាស មានចំងាយ១០គីឡូម៉ែត្រពីភូមិកងមាស និង៤០គីឡូម៉ែត្រពីខេត្តកំពង់ធំ បើគិតពីបឹងខែលមាសទៅបឹងទន្លេសាបមាន ចំងាយ៣០ ទៅ៣៥គីឡូម៉ែត្រ។ បឹងនេះមានព្រំប្រទល់ខាងកើតទល់ជាមួយនឹងដងស្ទឹងសែន ខាងលិចទល់នឹងវាលថ្កូវ ខាងជើងទល់ជាមួយទួល



**លោកតា ប៊ុន ស៊យ**

ខែលមាស ខាងត្បូងទល់នឹងអន្លង់ដូង។ បឹងនេះពីដើមឡើយនៅរដូវវស្សាមានបណ្តោយ១,៥គីឡូម៉ែត្រ ទទឹង ៣៥០ម៉ែត្រ ទឹកមានជំរៅ១៥ម៉ែត្រ ឯនៅរដូវប្រាំងមានបណ្តោយ៨០០ម៉ែត្រ ទទឹង១៨០ម៉ែត្រ ទៅ២០០ម៉ែត្រ និងមានជំរៅពី៤ ទៅ៥ម៉ែត្រ។ បឹងនេះទទួលរបបទឹកនៅរដូវវស្សាតាមរយៈដងស្ទឹងជីនិត និងមានដៃមួយឈ្មោះថា ដៃខែលមាសតូច ហើយដៃមួយទៀតគឺហូរទៅបឹងរូងរាំង។ នៅក្នុងបឹងនោះមានអន្លង់មួយនៅចំកណ្តាលបឹងដែលមានទំហំប្រហែលជា៣ ទៅ៤ម៉ែត្រ ។

ចំពោះប្រវត្តិបឹងនេះ តាមរយៈលោកតា យ៉ិន ស៊ីមដែលមានអាយុ ៦៨ឆ្នាំ រស់នៅភូមិកងមាស ឃុំត្នោតជុំ ស្រុកបារាយណ៍ ខេត្តកំពង់ធំបានអោយដឹងថា កាលពីជំនាន់សង្គ្រាមខ្មែរច្បាំងជាមួយសៀមនៅបឹងរាលរហូតដល់សៀមបាក់ទ័ព ហើយទ័ពខ្មែរយើងក៏ដេញតាមរហូតដល់បឹងមួយ ស្រាប់តែទ័ពសៀមរត់ឡើងទៅទួលមួយដែលនៅទិសខាងលិច។ ដោយឃើញបែបនោះ ទ័ពខ្មែរក៏បោះជំរុំនៅជិតទួលនោះស្រាប់តែប្រទះឃើញខែលមួយនៅជិតទួលនោះ ពេលនោះទ័ពខ្មែរក៏បានរៀបចំយុទ្ធសាស្ត្រ និងកងទ័ពដើម្បីទប់ទល់នឹងកងទ័ពសៀម។ ពេលប្រយុទ្ធ ស្រាប់តែប្រទះឃើញខែលមួយទៀតនៅលើទួលនោះ តាំងពីថ្ងៃដែលឃើញខែលទាំង២ នោះមកគេក៏ហៅទួលនោះថា *ទួលខែលមាសតូច* ។ ក្រោយមកមេទ័ពខ្មែរបានបញ្ជាកងទ័ពអោយមកមើលបឹងក៏ឃើញមានខែលមួយនៅក្នុងបឹង ហើយនៅទួលខាងជើងក៏ប្រទះឃើញខែលមួយទៀតទើបគេហៅទួលនេះថា *ទួលខែលមាសធំ* ។ ទីបញ្ចប់សៀមបាក់ទ័ពរត់ចោលទួលទាំង២នោះ តាំងពីពេលនោះមកគេក៏ហៅទួលទាំងពីរនោះថា *ទួលសៀមរងគ្រោះ*

តមកគេក៏ហៅថា *ទួលគ្រោះ* (ទួលខែលមាសតូច ហៅថាទួលគ្រោះតូច ឯទួលខែលមាសធំ ហៅថា ទួលគ្រោះធំ តមកគេក៏ហៅទួលទាំងពីរនេះថា *ទួលគ្រោះ* តែម្តង)។ លោកតា **យិន ស៊ីម** បានមានប្រសាសន៍ទៀតថា ដោយខែលទាំងបួននេះសុទ្ធតែធ្វើអំពីមាសហើយទួលទាំងពីរនេះ សុទ្ធតែលយចូលទៅក្នុងបឹងប្រជាពលរដ្ឋខ្មែរយើងក៏ហៅបឹងនេះថា *បឹងខែលមាស* រហូតមកដល់បច្ចុប្បន្ននេះ ។

គាត់ក៏មានប្រសាសន៍ទៀតថា ពីដើមនៅជុំវិញបឹងនេះមានព្រៃបីប្រភេទ។ ប្រភេទព្រៃរនាមដូចជាដើមត្រស់ ដើមភ្នំភ្លែង វល្លិត្រី វល្លិប្រេង និងមួយទៀតជាប្រភេទព្រៃលិចទឹកមានដើមប្របួយ ដើមអញ្ចាញ ដើមថ្មើមអណ្តើក និងប្រភេទព្រៃដែលមានដើមឈើធំៗដូចជា ដើមរាំង ដើមចា ដើមខ្ទុំ ដើមត្រសែង ដើមថ្កោល ដើមសណ្តាន់។ សម័យនោះព្រៃរនាមគឺស្កកខ្លាំងណាស់គឺសំរាប់តែសត្វជ្រកនិងជាកន្លែងសំរាប់កំដៅទឹកដល់ត្រីគ្រប់ប្រភេទដូចជា ត្រីឆ្តោរ ត្រីក្រុំ ត្រីគល់រាំងត្រីឆ្អិន ត្រីរ៉ស់ ត្រីក្លាំងហាយ ត្រីឆ្លាំង ត្រីពោធិ៍ ត្រីកេស ត្រីក្អែក សុទ្ធតែជាប្រភេទត្រីធំៗដែលមានទំងន់ចាប់ពី២០ ទៅ៣០គីឡូក្រាម និងមានប្រភេទត្រីតូចៗជាច្រើនទៀតត្រីដែលធំៗជាងគេ អ្នកនេសាទតែងតែប្រលែងវាទៅវិញព្រោះគេមានជំនឿថាវាជាស្តេចត្រី និងជាត្រីរបស់អ្នកតាដែលតាមថែរក្សាបឹង និងអ្នកនេសាទអោយបានសេចក្តីសុខ និងរកត្រីបានច្រើន ជាពិសេសទៅទៀតព្រៃនេះក៏សំរាប់ត្រីពងកូន។ ចំពោះដើមឈើដែលធំៗបំផុតនោះ គឺមានកំពស់ពី២៥ម៉ែត្រ ទៅ៣០ម៉ែត្រ ហើយមានមែកសាខាទំហំបីទៅបួនអោបដែលសំរាប់អោយសត្វព្រៃធំៗ និងសត្វល្មូនរស់នៅ

ហើយក៏ជាជំរករបស់បក្សាបក្សី និងពងកូនដែរ។ បើយើងដើរទៅក្បែរដើមនោះ យើងនឹងឃើញមានត្រីងាប់ និងស្អុយជាច្រើនដែលសល់ពីសត្វវាស៊ីហើយទំលាក់មកដី ជួនកាលប្រជាពលរដ្ឋអុំទូកទៅដើម្បីឈរចាំរើសត្រី និងពងសត្វនៅក្រោមដើមឈើធំៗនោះ។ នៅតំបន់នោះសំបូរសត្វណាស់ដូចជា កុក ក្រសា ទោម ត្រៀល ផ្កាត ក្អែក ស្មោញ ពស់វែក ពស់ទ្រូងរនាម ពស់ថ្លាន់ ពស់ក្រចាន់ អន្សង ក្រពើ អណ្តើក កន្ធាយ ជ្រូកព្រៃ ឈ្លូស ស្វា ទន្សាយ សំពោច ខ្លាតូច ធំ ដំរី ដែល សត្វទាំងនេះគេច្រើនឃើញនៅរដូវប្រាំងមានស្ទើរតែគ្រប់ប្រភេទ ។

គាត់បានអោយដឹងទៀតថា កាលអាយុ១៦ឆ្នាំ គាត់បានទៅរកស្ទូចត្រីនៅបឹងខែលមាសនេះពេលទៅដល់មាត់បឹង គាត់ក៏បានឈប់សំរាកនៅលើវាលមួយ ស្រាប់តែពេលនោះក៏លឺសំលេងដើរក្នុងទឹក ពេលនោះគាត់ឃើញដំរីទាំងហ្វូងដើរមករកគាត់ ។ គាត់ភ័យខ្លាំងណាស់ក៏រត់ទៅរកទូក ហើយអុំទៅកន្លែងម្តាយរបស់គាត់ដែលនៅក្នុងរោងមួយឆ្ងាយពីបឹង ហើយក៏សំងំដេករហូតទល់ព្រឹកទើបមកសារសន្ធូចវិញ។

ក្នុងកំឡុងឆ្នាំ១៩៧៩ ទៅ១៩៩៥ គាត់សង្កេត ឃើញថាព្រៃលិចទឹកមួយចំនួនបានក្លាយទៅជាវាលស្រែប្រាំងរបស់ប្រជាពលរដ្ឋ ឯព្រៃឈើដែលមានដើមឈើធំៗសល់តែដើមតូចៗ ហើយខ្លះមានទំហំតែ១អោបប៉ុណ្ណោះ ហើយពពួកសត្វព្រៃ បក្សាបក្សី និងសត្វល្មូនបានបាត់បង់អស់យ៉ាងច្រើន នៅសល់តែប្រភេទសត្វមួយចំនួនប៉ុណ្ណោះ។ លុះមកដល់សម័យឥឡូវ នៅជុំវិញបឹងបានផ្លាស់ប្តូរអស់ទៅហើយ ធនធានធម្មជាតិដែលសំបូរបែបពីសម័យមុនបានប្រែក្លាយទៅជាទីវាល មិនឃើញមានធម្មជាតិ

ស្រស់បំព្រងដូចពីមុនទៀតឡើយ។ តំបន់ព្រៃលិចទឹកត្រូវបានប្រជាពលរដ្ឋរុករានដីធ្វើស្រែអស់ទៅហើយ ហើយថែមទាំងកាប់ព្រៃ ដុតបំផ្លាញព្រៃដើម្បីចាប់សត្វទៀតធ្វើអោយពូជសត្វគ្រប់ប្រភេទស្ទើរតែផុតពូជអស់ទៅហើយ។ ប្រភេទសត្វខ្លះបានផុតពូជទៅហើយ ចំណែកនៅក្នុងបឹងពុំសូវមានវារីជាតិ និងមច្ឆាជាតិរស់នៅច្រើនកុះករដូចពីមុនទេ ដោយសារតែអ្នកនេសាទបានប្រើឧបករណ៍ឆក់ ឈឹប អួនក្រឡាញ៉ិក និងមងគ្រប់ប្រភេទ។ ចំពោះជំរៅទឹកវិញនៅរដូវវស្សាមានជំរៅតែ៧ទៅ៨ម៉ែត្រ នៅរដូវប្រាំងជំរៅពី១,៥ម៉ែត្រ ទៅ២ម៉ែត្រ និងមានទទឹងត្រឹមតែ១០០ទៅ ១៥០ម៉ែត្រតែប៉ុណ្ណោះ។ គាត់សំណូមពរអោយរាជរដ្ឋាភិបាលជួយបំបាត់នូវឧបករណ៍ខុសច្បាប់ដូចជាឆក់ បំពុលសត្វ បូមបាច ដួសកូនត្រី និងជួយថែរក្សាព្រៃលិចទឹកឡើងវិញ ។

# ប្រវត្តិបឹងបន្ទះជាល

បឹងបន្ទះជាល ជាបឹងដ៏សំខាន់មួយនៅក្នុងឃុំសាន់គរ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ហើយបឹងនេះស្ថិតនៅក្នុងឡូតិ៍លេខ០១ ដែលមានចំងាយប្រហែល៨គីឡូម៉ែត្រពីភូមិប្រាសាទអណ្តែត ឃុំសាន់គរ ហើយបើគិតពីទីរួមខេត្តកំពង់ធំមានចំងាយ៣៨គីឡូម៉ែត្រ។ បឹងនេះមានដៃតភ្ជាប់ជាមួយបឹងរៀល ដែលទទួលឥទ្ធិពលពីបឹងទន្លេសាប ហើយគេតែងហៅថាបឹងរៀលបន្ទះជាល តែក្រោយមកម្ចាស់ឡូតិ៍បានចែកបឹងនេះជាពីរ សំរាប់ធ្វើអាជីវកម្មអោយអ្នកគ្រប់គ្រងបន្តគឺបឹងរៀល និងបឹងបន្ទះជាល ។

បឹងបន្ទះជាលមានព្រំប្រទល់ខាងកើតជាប់នឹងជីពេរ ខាងលិចជាប់នឹងបឹងទឹកល្អក់ ខាងជើងមានដៃមួយហៅថាដៃតាតី និងខាងត្បូងជាប់នឹងស្ទឹងសែនតាមអូរគន្ធរ។ នៅរដូវវស្សា បឹងនេះមានបណ្តោយប្រវែងប្រហែល៦ គីឡូម៉ែត្រ ទទឹង៦០០ ម៉ែត្រ និងមានជំរៅទឹកពី៤ទៅ៥ម៉ែត្រ រីឯនៅកណ្តាលបឹងមានជំរៅដល់ទៅ៩ម៉ែត្រ គឺអន្លង់អាកុក។ នៅរដូវប្រាំង បឹងនេះមានបណ្តោយប្រវែង៤គីឡូម៉ែត្រ និងទទឹង៣០០ម៉ែត្រ ជំរៅប្រហែល១.៥០ម៉ែត្រ។

តាមការសំភាសន៍ជាមួយលោកតា **ប៊ុត ផុន** អាយុ៦៦ឆ្នាំ មានស្រុកកំណើតនៅភូមិជ័យ ឃុំសាន់គរ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ និងមានកូន១០នាក់ ប្រុស៧នាក់ ស្រី៣នាក់។ គាត់មានមុខរបរតាំងពីក្មេងមកគឺនេសាទ និងធ្វើស្រែ ហើយគាត់ក៏ជាអតីតអ្នកនេសាទមួយរូបធ្លាប់បានជួលបឹងនេះពីថៅកែឡូតិ៍ ដើម្បីធ្វើអាជីវកម្មអស់ជាច្រើនឆ្នាំមកហើយដែរ។ បឹងនេះកាលពីដើមមានជនជាតិ ចាម យួន បានមករស់នៅ

និងធ្វើជាថៅកែឡូតិ៍រហូតតំបន់នេះបានជាប់ងារថា បន្ទាយចាមរហូតមក។ គាត់បានអោយដឹងទៀតថា បឹងនេះកាលពីដើមមានព្រៃធំៗជាច្រើនដុះព័ទ្ធជុំវិញ ដូចជាដើមរាំង ដើមត្រសែង ដើមតាអួរខ្ពស់ៗដែលមានទំហំមុខកាត់ជាង១ម៉ែត្រ រីឯព្រៃរនាមវិញ ក៏ដុះក្រាស់ជិត ពុំអាចដើរចេញចូលបានឡើយ បើសិនពុំស្គាល់ច្រកផ្លូវ។ បឹងបន្ទះជាលនេះសំបូរដោយអន្លង់ជាច្រើនដែលសំបូរដោយត្រីជាច្រើនប្រភេទដូចជា ត្រីគល់រាំង



លោកតា ប៊ុត ផុន

ត្រីរ៉ស់ ត្រីឆ្តោរ ត្រីសណ្តាយ ត្រីក្រាយ ត្រីឆ្លាំង ត្រីស្លាត ត្រីឆ្ពិន ត្រីក្អែក ត្រីក្រុំ និងត្រីដំរី ជាដើម។ ត្រីទាំងអស់នេះសុទ្ធសឹងជាត្រីធំៗមានទំងន់ចាប់ពី៧ទៅ១៥គីឡូក្រាម។ ដោយបឹងនេះសំបូរអន្លង់និងធ្វើអោយ ត្រីសំបូរនោះគេចូលចិត្តមកនេ-សាទនៅបឹងនេះណាស់ ប្រជាពលរដ្ឋទាំងអស់នោះច្រើនចុះទៅជាក្រុមៗមានបួនដប់ម្ភៃទេះជួនកាលមានរហូតដល់រាប់រយរទេះមកពីស្រុកស្ទោង និងស្រុកកំពង់ស្វាយ ដោយខ្លះទៀតទៅរកទិញផ្ទាល់ ហើយខ្លះទៀតចុះទៅរកត្រីដោយខ្លួនឯង។ ពួកគេច្រើនចុះទៅរកត្រីនៅរដូវច្រូតកាត់ ហើយត្រឡប់មកផ្ទះវិញនៅពេលជិតចូលឆ្នាំខ្មែរ។ ពួកគេនេសាទដោយប្រើឧបករណ៍នេសាទមានរត់ព្រួល អង្រុត ស្ន សម មង អញ្ចង និងអួនដែលមានក្រឡាពាហ៊ុនអួសដោយកំលាំងមនុស្សពី៤ ទៅ៥នាក់។ អ្នកនេសាទ

នៅទីនោះគេតែងមានទំលាប់មួយគឺបើជាប់ត្រីធំជាងគេ គេតែងតែលែងទៅវិញទុកដើម្បីទុកបន្តពូជ ម្យ៉ាងទៀតពួកគេមានជំនឿថា វាជាត្រីមេបឹង រឺជាត្រីរបស់អ្នកតាទុកសំរាប់ថែរក្សាពូជត្រីក្នុងបឹង ។

គាត់បានបញ្ជាក់ទៀតថា គាត់បានធ្វើឡូតិ៍នៅក្នុងបឹងនេះតាំងពីឆ្នាំ១៩៨៤ ម៉្លេះដោយចាប់ត្រីរបស់គាត់មានអួនប្រវែង២០០ម៉ែត្រអូសក្នុងមួយអួនបានត្រីចំនួន២ ទៅ៣តោនត្រី។ ចំណែកផលដែលបានពីនេសាទគេច្រើនធ្វើត្រីងៀត ប្រឡាក់ ធ្វើប្រហុកផ្អក ឬក៏ឆ្អើរ ទុកសំរាប់លក់នៅទីផ្សារឬសំរាប់ លក់ជូនប្រជាកសិករនៅតាមជនបទដូចជាស្រុកស្ទោង កំពង់ស្វាយ៨ ដែលពួកគេចុះទៅទិញដល់បឹងសំរាប់ត្រៀមនៅរដូវដកស្ទូង។ ជួនកាលត្រីស្រស់មួយចំនួនគាត់លក់អោយឈ្មួញដែលដឹកតាមកង់រទេះមកផ្សារសាន់គរ។ មិនត្រឹមតែត្រីទេដែលសំបូរ ចំណែកសត្វបក្សាបក្សីវិញក៏មានច្រើនណាស់ដែរដូចជា រនាល កុក ក្រសា ត្រដក់ ទុង ស្មោញ ក្អែកទឹក និងពពួកល្មូនមួយចំនួនក៏សំបូរដែរដូចជា ក្រពើ ពស់វែក ពស់ថ្លាន់ កន្ធាយ អណ្តើក ភេ ហើយសត្វព្រៃវិញមានដំរី ខ្លា ប្រើស រមាំង ឈ្លូស តែងតែមកចុះមកផឹកទឹកបឹងទាំងហ្វូង។ ។

ថ្ងៃមួយ គាត់បានជួបប្រទះនឹងគ្រោះអាសន្នមួយដែលធ្វើអោយគាត់មានការភ័យខ្លាំងរហូតដល់ឈឺមួយរយៈពេល។ នោះកាលគាត់នៅពីជំទង់ ឪពុករបស់គាត់ប្រើអោយគាត់ទៅកាប់ត្រែងជាមួយបងប្រុស និងអ្នកភូមិ៥នាក់ទៀត ដើម្បីយកមកធ្វើជាលំនៅដ្ឋានដោយអ្នកទាំងនោះមានការប្រមាថ និយាយលេងសើចច្រើន ដោយ

ខ្លះថាថ្ងៃនេះបានម្ហូបឆ្ងាញ់ ដោយបានប្រមោយដំរី ប្រអប់ជើងដំរី ស្លឹកត្រចៀកដំរីធ្វើម្ហូប ស្រាប់តែនិយាយពុំទាន់ផុតពីមាត់ផង ឃើញដំរីមួយយ៉ាងធំដេកនៅខាងមុខ ចំណែកឆ្កែដើរខាងមុខពួកគាត់ក៏រត់ទៅព្រុសដំរី ពេលនោះដំរីក៏ងើបស្ទុះឡើងតតាំងជាមួយឆ្កែដែលធ្វើអោយពួកគាត់រត់ទៅឡើងដើមឈើយ៉ាងប្រញាប់តែ មិនទាន់ដល់ដើមឈើផង ដំរីក៏បែរមុខមកដេញពួកគាត់ម្តង ក្នុងពេលនោះបងរបស់គាត់បានដោះម្ជុកគ្រវែងចោលដើម្បីទប់ដំណើរដំរី។ ជាបច្ច័យល្អ អោយពួកគាត់មានឱកាសបានឡើងដើមឈើគ្រប់គ្នា មួយស្របក់ក្រោយមកដំរីវាថយចេញពួកគាត់ក៏បានរួចខ្លួនទៅ។ តាំងពីថ្ងៃនោះមក គាត់ចាប់ផ្តើមមានជំងឺឈឺជ្រុះសក់ រហូតទាល់តែក្រុមគ្រួសារគាត់បែរបន់សែនព្រេនអ្នកតានៅទីនោះ ទើបជំងឺរបស់គាត់បានជាសះស្បើយឡើងវិញ។

គាត់បានមានប្រសាសន៍បន្តទៀតថា លុះមកដល់ឥឡូវនេះធនធានដែលធ្លាប់តែសំបូរបែរជាត្រូវរងការបំផ្លិចបំផ្លាញដូចជាត្រីត្រូវបាត់បង់អស់ ពូជត្រីមួយចំនួនដូចជាត្រីគល់រាំង ត្រីរាជ ត្រីក្អែ ត្រីសណ្តាយ ។ល។ ការបាត់បង់បែបនេះគឺដោយសារតែប្រជានេសាទប្រើប្រាស់ឧបករណ៍ខុសច្បាប់ និងទំនើប១ដូចជាការឆក់ ការអូសអួនក្រលាញ៉ែក ឈ៉ុប មងគ្រប់ប្រភេទគួបផ្សំ និងឧបករណ៍បុរាណ និងការបំផ្លាញជំរកនៅជុំវិញបឹង។ ក្រៅពីនេះព្រៃរនាម និងព្រៃលិចទឹក ត្រូវបានគេលួចកាប់បំផ្លាញដើម្បីធ្វើស្រែ និងដុតព្រៃ ដើម្បីចាប់សត្វ។ រហូតដល់យើងសង្កេតឃើញមានតែសត្វកុក ក្រសា ខ្លែង មាន់ទឹក មានចំនួនតិចតួចណាស់សឹងតែគ្មានផង។ ដើមឈើធំ១គឺអស់រលីញគ្មានសល់ ព្រមទាំងសត្វព្រៃធំ១ផុតពូជអស់ទៅហើយ។ ចំណែកសត្វ

ល្អវិញគឺបាត់ច្រើនណាស់ដូចជាក្រពើ កន្ធាយ ពស់ទ្រូងរនាម ពស់ថ្លាន់ សត្វស្វា។ គាត់បានសម្តែងនូវភាពសោកស្តាយថា បើយើងនៅតែមិនរិះរកវិធីថែរក្សា និងអភិរក្សធនធានដែលនៅសល់ទេ នោះធនធានធម្មជាតិរបស់យើងនឹងវិនាសសាបសូន្យនៅពេលអនាគត ។

ដូច្នេះគាត់សន្ទូមពរអោយរាជរដ្ឋាភិបាលជួយដោះស្រាយពីបញ្ហាធ្វើស្រែប្រាំងនៅជុំវិញបឹងដែលអាចបណ្តាលអោយទឹកក្នុងបឹងអាចរីង ចំណែកត្រីក្នុងទឹកក៏អស់ព្រៃនៅជុំវិញបឹងក៏អស់ទៀត និងជួយអភិរក្សបឹងនេះឡើងវិញផង ។

# ប្រវត្តិឡូត៍បំរុង

បើតាមប្រវត្តិសាស្ត្រនៅក្នុងប្រទេសកម្ពុជា ជាប្រទេសមួយដែលមានឡូត៍ជាច្រើន ជាពិសេសនៅក្នុងបឹងទន្លេសាប។ បឹងទន្លេសាបនេះហ៊ុំព័ទ្ធដោយខេត្តចំនួន៥ក្នុងនោះក៏មានខេត្តកំពង់ធំមួយដែរ។ ក្នុងខេត្តនេះមានឡូត៍ទាំងអស់ចំនួន ០៧ ក្នុងចំណោមឡូត៍នោះមានឡូត៍មួយឈ្មោះថាឡូត៍បំរុង ដែលមានជំរៅជ្រៅសំរាប់រក្សាពូជត្រី ហើយឡូត៍នេះស្ថិតនៅក្នុងការការពារ និងហាមឃាត់នាពេលបច្ចុប្បន្ននេះ ។

បើតាមការសំភាសន៍ជាមួយ លោកអ៊ុំ **ឡៀង សុខ** ដែលមានអាយុ ៥៦ឆ្នាំ នៅភូមិកំពង់ចំលង ឃុំផាត់សណ្ដាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំបានរៀបរាប់ថា កន្លងមកគាត់ជាប្រជានេសាទប្រចាំឃុំនោះ តែរហូតមកដល់បច្ចុប្បន្នគាត់ជា ក្រុមប្រឹក្សាឃុំផាត់សណ្ដាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដែលជានិច្ចជាកាលគាត់តែងតែទៅនេសាទនៅក្បែរឡូត៍នេះចាប់តាំងពីគាត់នៅអាយុ១៨ឆ្នាំ រហូតដល់ឆ្នាំ១៩៩៥។ គាត់បានមានប្រសាសន៍ថាឡូត៍បំរុង រឺហៅថាឡូត៍លេខពីរស្ទួន ពីដើមឡើយ គេហៅថាឈូងឆកក្រោយដែលមានបណ្ដោយ៨គីឡូម៉ែត្រ លាតសន្ធឹងពីក្បាលកោះផាត់សណ្ដាយទៅព្រែកពាមសែន ហើយមានទទឹង ៨០០ម៉ែត្រ និងជំរៅនៅរដូវប្រាំងពី៣ ទៅ៨ម៉ែត្រ ចំណែកនៅរដូវ



**ការសំភាសន៍ជាមួយលោកអ៊ុំ ឡៀង សុខ**

វស្សាមានជំរៅពី១០ទៅ១៣ម៉ែត្រ។

កាលពីដើមឡើយឡូតិ៍បំរុងជាឈូងមួយដែលសំបូរ ទៅដោយព្រៃរនាមគ្រប់ប្រភេទដុះព័ទ្ធជុំវិញ ហើយនៅសម័យនោះបក្សាបក្សីសំបូរណាស់ដូចជាសត្វកុក ក្រសារនាល ប្រវីក និងមានសត្វល្មូនដូចជា ពស់ជាច្រើនប្រភេទអណ្តើក គន្ធាយជាច្រើន ព្រមទាំងមានបឹងមួយចំនួនតែងតែទទួលពូជត្រីមករស់នៅដោយពួកវាឆ្លងតាមដៃបឹងជាប់ជាមួយបឹងទន្លេសាប ជាពិសេសឡូតិ៍នេះតែម្តងដែលពូជត្រីទាំងនោះត្រូវឆ្លងកាត់ដើម្បីមកពងនៅក្នុងបឹងទាំងនោះ ដែលជាមូលហេតុធ្វើអោយឡូតិ៍នេះសំបូរទៅដោយពូជត្រីគ្រប់ប្រភេទ ហើយម្យ៉ាងទៀតនៅក្នុងឡូតិ៍នេះមានរន្ធសំរាប់ត្រីកុំនៅចំកណ្តាលព្រមទាំងព្រៃរនាមក្បែរឡូតិ៍ជាតំបន់សំរាប់ត្រីជ្រក និងងាយស្រួលក្នុងការពងកូននៅពេលរដូវត្រីពង។ ក្រៅពីនេះឡូតិ៍ក៏ស្ថិតនៅជាប់ជាមួយដងស្ទឹងសែនយើងផងដែរ ដែលធ្វើអោយត្រីរត់ចូលមកក្នុងឡូតិ៍ តាមរយៈខ្សែទឹកនៅរដូវទឹកសំរក។ កាលនោះនៅក្នុងឡូតិ៍នេះសំបូរទៅដោយ ត្រីគ្រប់ប្រភេទគឺ មានច្រើន ណាស់ដូចជាត្រីក្រាយ ត្រីកេស ត្រីឆ្ពិន ត្រីក្អែក ត្រីឆ្តោរ ត្រីគ្រុំ ត្រីគល់រាំង និងត្រីតូចៗជាច្រើនទៀត។ បើយើងសង្កេតទៅ មើលក្នុងឡូតិ៍នេះ គឺមានស៊ងពីរជាស៊ងដ៏សំខាន់សំរាប់ចាប់ត្រីនៅពេលដែលម្ចាស់ឡូតិ៍ត្រូវការ ជាពិសេសនៅរដូវប្រាំងជារដូវដែលត្រីមកកុំក្នុងឡូតិ៍។ បើយើងពិនិត្យ មើលត្រីដែលនៅក្នុងស៊ងគឺមានច្រើនប្រភេទណាស់ហើយធំៗទៀត។ នៅក្នុងសម័យ នោះក្នុងឡូតិ៍នេះមានថៅកែជាច្រើនមកធ្វើហើយផ្លាស់ប្តូរជាបន្តបន្ទាប់។ គាត់ក៏បានបន្ថែមទៀតថា ថៅកែភាគច្រើនធ្វើឡូតិ៍នេះចេះតែខាតពុំសូវទទួលបានផល

ចំណេញច្រើនទេ ចំពោះបច្ចេកទេសគាត់ពុំបានបញ្ជាក់ច្បាស់ទេ។ ដោយឃើញសភាពបែបនោះឡូតិ៍នេះត្រូវបានផ្អាក ដោយគ្មានថៅកែណាមកដេញថ្លៃដើម្បីកាន់កាប់ឡូតិ៍ទេ។ បើតាមប្រសាសន៍របស់លោកតា **សាំង សួរ** ដែលធ្លាប់ជាប្រជានេសាទនៅតំបន់នោះបានអោយដឹងថា ក្រោយពីគេផ្អាករហូតដល់ឆ្នាំ១៩៦៨ ស្រាប់តែមានថៅកែមួយរូបមកពីប្រទេសវៀតណាមដែលមានឈ្មោះ **បា ឡឹយ** បានមករៀបចំឡូតិ៍នេះដោយគាត់ប្រើបច្ចេកទេសចាប់ត្រីយកក្នុងឡូតិ៍នេះដោយរៀបចំដាក់ជាសំរាស់ដើម្បីអោយកុមគ្នា ពេលគាត់រៀបចំក្នុងរយៈពេលនោះស្រាប់តែទទួលបានប្រាក់ចំណេញច្រើន នេះក៏ដោយសារតែរយៈកាលដែលគេផ្អាកនោះជាឱកាសធ្វើអោយត្រីកើន និងសំបូរខុសធម្មតាដែរ។ បន្ទាប់ពីលោក **បា ឡឹយ** បានឈប់ទៅ ឡូតិ៍នេះត្រូវធ្លាក់ក្នុងកម្មសិទ្ធរបស់ លោក **សេង ញឹ** ដោយប្រើមធ្យោបាយដូចលោក **បា ឡឹយ** ហើយកាន់កាប់រហូតដល់ឆ្នាំ១៩៧០។ ក្រោយពីឆ្នាំ១៩៧០ រហូតដល់ឆ្នាំសម័យប៉ុលពត ឡូតិ៍នេះក៏នៅដាក់សំរាស់ដដែល។ បើគិតពីឆ្នាំ ១៩៨៣មកដល់បច្ចុប្បន្ន ឡូតិ៍នេះត្រូវបានប្រែក្លាយពីឈូងឆកក្រោយមកជាឡូតិ៍បំរុង(ឡូតិ៍លេខពីរស្ទួន) ដោយរដ្ឋាភិបាលកម្ពុជាយើង។ គាត់ក៏បានបន្ថែមទៀតថាចំពោះត្រីនៅក្នុងឡូតិ៍បើគិតពីឆ្នាំ១៩៩៥មកទល់ឆ្នាំ២០០៥ ត្រីមានការកែប្រែបរិមាណកាន់តែតិច និងបាត់ពូជត្រីធំៗមួយចំនួនដោយសារតែការឆក់ និងជនខិលខូចមួយចំនួនតែងតែលួចប្រព្រឹត្តបទល្មើសនេសាទ នៅក្នុងដែនឡូតិ៍បំរុងដោយការប្រើឧបករណ៍ខុសច្បាប់ដែលធ្វើអោយត្រីត្រូវបាត់បង់ស្ទើរអស់ ហើយម្យ៉ាងទៀតដោយសារតែប្រជានេសាទដួសយកកូនត្រីទាំងសំបុកៗ ដើម្បីដាក់ជានុយសំរាប់ត្រី

ចិញ្ចឹមរបស់ពួកគាត់។ ព្រៃរនាម ត្រូវគេបំផ្លាញចោលដើម្បីដាក់សំរាស់នេះជាកត្តាមួយសំខាន់បំផុតក្នុងការធ្វើអោយបាត់បង់ពូជត្រី ព្រោះគេបំផ្លាញទីជំរករបស់ត្រីទាំងរដូវប្រាំង និងរដូវវស្សា ជាពិសេសនៅរដូវត្រីពងគ្មានលំនៅសំរាប់តំកល់ពងដើម្បីញាស់។ ពេលញាស់ហើយនោះត្រូវពួកត្រីធំៗ ងាយស្រួលនឹងចាប់ធ្វើជាចំណីរបស់ខ្លួន។ ចំណែកសត្វស្លាបបាត់បង់ច្រើនណាស់នៅសល់តិចតួចបំផុត និងជីវៅរបស់ឡូតិ៍ពុំសូវមានការប្រែប្រួលទេ។ដូច្នេះគាត់សំនូមពរសុំអោយរដ្ឋាភិបាល អង្គការជាតិ និងអន្តរជាតិជួយផ្សព្វផ្សាយដល់ប្រជានេសាទ កុំអោយដួសយកកូនត្រីដើម្បីធ្វើជាចំណីត្រីចិញ្ចឹមរបស់ខ្លួន និងសូមកុំអោយមានការប្រើប្រាស់ឧបករណ៍ខុសច្បាប់ទៀត ។

# ប្រវត្តិបឹងកន្ទ្រាមចាប

ឃុំផាត់សណ្ដាយជាឃុំមួយដែលជាប់នឹងមាត់បឹងទន្លេសាប ស្ថិតនៅក្នុងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដែលមានចំងាយ៩០គីឡូម៉ែត្រពីទីរួមខេត្តនិងមានប្រជាពលរដ្ឋរស់នៅចំនួន៨០០គ្រួសារ ហើយប្រជាពលរដ្ឋភាគច្រើនប្រកបមុខប្របរនេសាទទាំងរដូវប្រាំង និងរដូវវស្សា។ ឃុំនេះមានព្រំប្រទល់ខាងជើងជាប់នឹងឃុំពេជជ្រៃ ខាងត្បូងជាប់នឹងឃុំឆ្នុកទ្រូ និងប្រឡាយមាស ខាងកើតជាប់នឹងឃុំកំពង់គោ និងខាងលិចជាប់នឹងឃុំអន្សាចំបក់ ស្រុកក្រគរ ខេត្តពោធិ៍សាត់។ ឃុំផាត់សណ្ដាយ ជាឃុំដែលមានបឹងតូចធំជាច្រើនដែលសំបូរទៅដោយជីវចំរុះ និងមច្ឆាជាតិជាច្រើនដែលអាចចិញ្ចឹមជីវិតប្រជាពលរដ្ឋនៅក្នុងឃុំបានយ៉ាងងាយស្រួល។ ចំពោះធនធានដ៏សំបូរនេះវាមិនត្រឹមតែចិញ្ចឹមជីវិត ប្រជាពលរដ្ឋនៅក្នុងខេត្តកំពង់ធំប៉ុណ្ណោះទេ វាថែមទាំងចិញ្ចឹមជីវិតប្រជាពលរដ្ឋនៅក្នុងខេត្តកំពង់ឆ្នាំង និងភ្នំពេញផងដែរ។ ដោយនៅក្នុងឃុំនេះមានបឹងធំៗជាច្រើន យើងបានលើកយកបឹងមួយដែលជាបឹងធំហើយសំបូរធនធានចំរុះគឺ "បឹងកន្ទ្រាមចាប "។

តាមការសំភាសន៍ពីលោកតា **អ៊ួ វង់** ដែលជាប្រជានេសាទ និងមានវ័យចំណាស់ជាងគេក្នុងភូមិផាត់សណ្ដាយឃុំផាត់សណ្ដាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ គាត់មានអាយុ៨០ឆ្នាំ និងកូនចំនួន ៥នាក់ ស្រី៤ ប្រុស១នាក់។ គាត់ជាអ្នកនេសាទប្រចាំឃុំផាត់សណ្ដាយតាំងពីវ័យក្មេង ជាពិសេសគាត់តែងទៅនេសាទនៅបឹងកន្ទ្រាមចាបនោះរហូតដល់គាត់បានអាយុ៣៥ឆ្នាំ គាត់បានធ្វើជាជិទប់ទី១ ក្រោយមកជាមេឃុំ

នៅក្នុងរបបសង្គមរាស្ត្រនិយម។ គាត់បានរៀបរាប់ពីប្រវត្តិបឹងកន្ទ្រាមចាបដូចខាងក្រោមនេះ: បឹងកន្ទ្រាមចាបជាបឹងមួយមានចំងាយប្រហែល៧ទៅ៨គីឡូម៉ែត្រពីភូមិផាត់សណ្តាយ បើយើងធ្វើដំណើរពីខេត្តកំពង់ធំតាមដងស្ទឹងសែនមានចំងាយ ៩៧គីឡូម៉ែត្រ បើគិតចំងាយពីបឹងទៅមាត់បឹងទន្លេសាបគឺមានចំងាយពី៣ទៅ៤គីឡូម៉ែត្រ។ បឹងនេះមានទំហំបណ្តោយ ១គីឡូម៉ែត្រ ទទឹង១៥០ម៉ែត្រ នៅរដូវប្រាំងមានជំរៅពី១ម៉ែត្រទៅ១.៥ម៉ែត្រ ចំណែកនៅរដូវវស្សាវិញមិនអាចកំណត់បានទេ ប្រហែលជំរៅពី ៨ទៅ៩ម៉ែត្រ ជួនកាលអាចឡើងដល់១០ម៉ែត្រ។ បឹងនេះមានដៃជាច្រើនបានហូរចូលមកដូចជាបឹងប៉ោង បឹងក្រចាប់តូច ធំ បឹងក្អេរ បឹងទទឹងថ្ងៃតូច ធំ បឹងស្បាត បឹងមាត់កន្ទង។ បឹងកន្ទ្រាមចាបនេះមានដៃមួយហូរចូលទៅបឹងទន្លេសាប។



លោកតា អ៊ួ វង់

បើតាមការសំភាសន៍លោកតាបានអោយដឹងថាប្រវត្តិ បឹងកន្ទ្រាមចាបនេះគាត់ដឹងមិនច្បាស់ទេព្រោះអ្នកដែលដឹងប្រវត្តិបានស្លាប់អស់ ហើយតែបើតាមការសន្និដ្ឋានរបស់លោកតា កាលពីមុននៅជិតបឹងនេះមានគ្រួសារមួយជាអ្នកនេសាទដែលមានលោកតាឈ្មោះ សោម និងលោកយាយឈ្មោះចាប តែងតែមកនេសាទត្រីនៅបឹងនេះ។ លុះពេលយូរៗទៅ ប្រជាពលរដ្ឋតែងហៅបឹងនេះថា បឹងតាសោមយាយចាប

លុះក្រោយមកបឹងនេះក៏ក្លាយពាក្យទៅជាបឹងកន្សែងរាមចាប គេហៅតៗគ្នារហូតដល់សព្វថ្ងៃនេះ។ តាមគាត់ដឹងថា កាលពីដើមឡើយបឹងនេះហ៊ុំព័ទ្ធដោយព្រៃរនាមក្រាស់ និងដើមឈើធំៗដូចជា ដើមរាំង ត្រសែង តាអួរ ចំណែកនៅក្នុងបឹងមានកំប្លោក និងក្រចាប់ កំពីងពួយ ដែលបង្កលក្ខណៈងាយស្រួលសំរាប់ការរស់នៅរបស់មច្ឆាជាតិ បក្សាបក្សី និងសត្វព្រៃអាចរស់នៅបានយ៉ាងងាយស្រួល។ ដោយសារតំបន់បឹងនេះសំបូរទៅដោយព្រៃរនាម និងដើមឈើធំៗ ធ្វើអោយពពួកសត្វព្រៃចូលចិត្តមករស់នៅទីនេះណាស់ដូចជាសត្វជ្រូកព្រៃ ឈ្លូស រមាំង ឆ្កែចចក ស្វា ជាពិសេសសត្វដំរីគឺសំបូរណាស់ ហើយនៅរដូវប្រាំង សត្វដំរីតែងតែនាំគ្នាទាំងហ្វូងៗឆ្លងកាត់តាមបឹងនេះ។ គាត់បានបញ្ជាក់ពីរឿងរ៉ាវរបស់គាត់ដែលបានជួបប្រទះនឹងសត្វដំរីថា ថ្ងៃមួយគាត់បានអុំទូកចេញទៅនេសាទជាមួយនឹងឪពុកព្រមទាំងបងប្អូនមានគ្នាចំនួន៥នាក់ រួមទាំងសត្វឆ្កែមួយផង ក្នុងគោលបំណងទៅនេសាទក្នុងបឹងនោះ ពេល ដល់ចុងបឹងស្រាប់តែឆ្កែរបស់គាត់រត់ទៅប្រទះនឹងសត្វដំរីមួយ ដែលកំពុងដេកធ្វើអោយវាផ្អើលក្រោកឡើងឃើញដូច្នេះឆ្កែក៏រត់ចេញ ហើយសត្វដំរីបែរមុខសំដៅមករកគាត់ប្រកបដោយភាពសាហាវបំរុងនឹងធ្វើបាបគាត់ តែពេលនោះ បានឆ្កែរបស់គាត់រត់ពីក្រោយមកទៅខាំកែងជើងដំរីពីក្រោយ ដែលហេតុធ្វើអោយដំរីបែរមុខមកប្រយុទ្ធជាមួយនឹងឆ្កែម្តង។ ដោយឃើញសភាពបែបនោះគាត់ និងឪពុកព្រមទាំងបងប្អូននាំគ្នារត់ឡើងលើឈើមួយសន្ទុះក្រោយមកទើបសត្វដំរីនោះរត់ទៅវិញបាត់ទៅ ពេលនោះហើយគាត់មានឱកាសបានគេចផុតពីកណ្តាប់ដៃសត្វដំរី។ ក្រៅពីសត្វព្រៃគេឃើញមានសត្វល្មូនដូចជា ក្រពើ ពស់វែក

ពស់ថ្លាន់ អណ្តើក គន្ធាយ.....រស់.នៅក្នុងបឹងនោះ។ ដោយបឹងនេះសំបូរទៅដោយធនធានមច្ឆាជាតិធ្វើអោយប្រជានេសាទចូលចិត្តមកនេសាទនៅទីនេះ មិនត្រឹមតែប្រជានេសាទនៅឃុំផាត់សណ្តាយទេ ថែមទាំងអ្នកដែលមកពីឃុំមួយចំនួនទៀតតែងតែទៅនេសាទក្នុងបឹងនោះដោយជាក្រុមៗ។ គាត់បានបន្តទៀតថា ការធ្វើនេសាទនៅសម័យនោះ គេប្រើប្រាស់ឧបករណ៍ចាប់ត្រីដូចជា ស្ទូច១ សមផ្លែបី អង្រុត អញ្ចង ដែលធ្វើអំពីខ្សែធ្មៃ ហើយគេតែងតែចាប់ត្រីដូចជា ត្រីរ៉ស់ ត្រីឆ្តោរ ត្រីកញ្ជាន និងត្រីអណ្តែង ដោយត្រីនៅជំនាន់នោះច្រើនតែធំៗមានទំងន់ពី៦ទៅ ៧គីឡូក្រាម។ ប្រភេទត្រីទាំងអស់នោះ នៅពេលដែលពួកគាត់នេសាទបានហើយតែងតែធ្វើជាត្រីងៀតដើម្បីលក់អោយឈ្មួញនៅឆ្នុកទ្រូ ដោយគិតជាហាប (១ហាប=៦០គីឡូក្រាម) ។

គាត់បានបន្តទៀតថា ដោយឡែកបច្ចុប្បន្ននេះព្រៃលិចទឹកត្រូវបានគេដុតបំផ្លាញអស់ច្រើនជាក់ស្តែងក្នុងឆ្នាំ២០០៣-២០០៤ ដោយមូលហេតុដុតព្រៃចាប់សត្វដើម្បីលក់និងធ្វើម្ហូប។ មានពាក្យស្លោកមួយបានពោលថា "ទីណាមានទឹក ទីនោះមានត្រី " តែផ្ទុយទៅវិញ បច្ចុប្បន្នត្រីត្រូវបានបាត់បង់អស់ជាច្រើន នៅសល់តែផ្ទៃទឹកដ៏ល្វឹងល្វើយគ្មានត្រីហែលឆ្វែលឆ្វាត់ដូចពីមុនទេ ដោយសារការប្រើប្រាស់ឧបករណ៍ល្មើសច្បាប់ដូចជា ឆក់ បូមបាច អួនក្រឡាញឹកជាដើម។ ចំណែកសត្វស្លាបវិញនៅសល់បរិមាណតិចតួចបំផុតដូចជា សត្វរំពេរ កុក ក្រសា ប្រវឹក មាន់ទឹក។ សព្វថ្ងៃប្រជានេសាទក្នុងឃុំផាត់សណ្តាយអស់សង្ឃឹមក្នុងការប្រកបមុខរបរនេសាទនេះ មិនត្រឹមតែរកត្រីមិនបានដោយត្រីថយចុះនោះទេ បញ្ហាឡូត៍នេសាទដែលម្ចាស់ឡូត៍ចេះតែពង្រីកដែនឡូត៍របស់

ខ្លួននោះកាន់តែធ្វើអោយពួកគាត់អស់សង្ឃឹមទៀតហើយ ពួកគាត់មានការព្រួយបារម្ភទៅថ្ងៃអនាគតនឹងមានការបាត់បង់នូវមច្ឆាជាតិ បក្សាបក្សី គ្រប់ប្រភេទដែលកំពុងតែនៅសល់តិចតួចបំផុតនេះ។ គាត់បានសំណូមពរដូចតទៅ:

១-សុំអោយម្ចាស់ឡូតិ៍គោរពតាមសៀវភៅបន្ទុកឡូតិ៍

២-សុំកុំអោយមានការឆក់ និងបូមបាច

៣-សូមអោយរដ្ឋាភិបាលពង្រឹងច្បាប់ និងអភិរក្សឡើងវិញ។

# ប្រវត្តិបឹងរាល

បឹងរាលជាបឹងមួយដ៏សំខាន់សំរាប់ប្រជានេសាទក្នុងឃុំកំពង់គោ ដែលជាបឹងមួយទទួលឥទ្ធិពលទឹកពីស្ទឹងសែន និងទឹកទន្លេសាប។ បឹងនេះមានចំងាយពី៥ ទៅ៦ គីឡូម៉ែត្រពីឃុំកំពង់គោ បើគិតពីទីរួមខេត្តកំពង់ធំមានចំងាយប្រហែល ១៨គីឡូម៉ែត្រ និងមានចំងាយប្រហែល ៧០ទៅ៧៦គីឡូម៉ែត្រដល់មាត់បឹងទន្លេសាប។ បឹងរាលស្ថិតនៅក្នុងភូមិខ្សាច់ជីរស់ ឃុំកំពង់គោ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដែលមានព្រំប្រទល់ ខាងជើងជាប់នឹងអូរទូចឡាក់ ខាងត្បូងជាប់នឹងបឹងករស្តីទឹម ខាងកើតជាប់នឹងវាលស្រែល្វឹងល្វើយ ខាងលិចជាប់នឹងអូរត្រសេក ។

តាមប្រសាសន៍លោកតា **លៀង ដេ** អាយុ ៧៨ឆ្នាំ អតីតជាកម្មករឡូតិ៍នេសាទតាំងពីជំនាន់បារាំង បច្ចុប្បន្នជាព្រឹទ្ធាចារ្យនៅភូមិកំពង់គោ។ គាត់បានអោយដឹងថា បឹងនេះមានដៃហូរចូលគឺដៃស្តីទឹមស្វា គោង-បាក់ដឹង និងអូរអ្នកតា។



**ទិដ្ឋភាពបឹងរាលមើលពីចំងាយ**

បឹងនេះមានបណ្តោយប្រវែង៣គីឡូម៉ែត្រ ទទឹង៥០០ម៉ែត្រ ជំរៅពី៣ ទៅ៤ ម៉ែត្រនៅខែវស្សា ចំណែកនៅខែប្រាំងមានបណ្តោយប្រវែង៣គីឡូម៉ែត្រ ទទឹង២០០ ម៉ែត្រ ជំរៅពី១ម៉ែត្រទៅ ១,៥ម៉ែត្រ នៅកណ្តាលបឹងមានអន្លង់មួយជំរៅដល់ទៅ ៥ម៉ែត្រ

នៅរដូវវស្សាវាងដូចស្លាបក្អោង។ គាត់បានរៀបរាប់បន្តទៀតថា បឹងរាលនេះកាលពីដើមជាបន្ទាយ ឬកន្លែងជួបជុំរបស់សត្វដំរី ថ្ងៃមួយកាលពីនៅវ័យជាង២០ឆ្នាំ គាត់ធ្លាប់មានប្រវត្តិដំរីដេញម្តងជាមួយមិត្តសំលាញ់របស់គាត់គឺលោក សោម អ៊ុត និង សោម អៀត ដោយពួកគាត់ទាំងបីនាក់នេះបានទៅបាចត្រីច្រើននៅកូនថ្លុកមួយក្បែរបឹងដំរីដេកពេលកំពង់បាចពួកគាត់បានឃើញសត្វដំរីដើរចុះដើរឡើងជាច្រើន ពេលនោះលោក សោម អ៊ុត បាននិយាយថាពួកយើងនាំគ្នាទៅដេញអាដំរីមួយចាស់ពពាលខ្លួនកំពស់៣ម៉ែត្រមានភ្លុកតែម្ខាងអោយដាច់ហ្វូងនោះ ដើម្បីយកភ្លុកវាដែលនៅចំងាយពីពួកគាត់ប្រហែល២០ម៉ែត្រ ដែលមានដើមរាំង និងដើមត្រែងជាច្រើននៅជុំវិញពួកគាត់ពេលនោះពួកគាត់បានបន្លឺសញ្ញារាប់មួយពីរ បីក៏ចោលដំរីនោះតែម្តងដើម្បី អោយដំរីរត់ចេញ តែផ្ទុយទៅវិញដំរីនោះបែរជាមកដេញពួកគាត់រត់ធ្លាក់ទឹក ធ្លាក់ភក់នៅក្បែរនោះស្ទើរតែរត់ពុំរួចទៅហើយ។ គាត់បានបន្តទៀតថា កាលពីជំនាន់បារាំងបាននាំទាហានជាច្រើននាក់បានធ្វើដំណើរទៅកន្លែងបន្ទាយ ដំរីពេលប្រទះឃើញក៏នាំគ្នាបាញ់ទៅដំរីដើម្បីអោយហ្វូងដំរីខ្លាចរត់ចេញពីបឹង ប៉ុន្តែត្រូវបានដំរីដេញពួកទាហានរត់ធ្លាក់ទឹកភ័យស្លន់ស្លោរវាលពាសពេញបឹងដើម្បីយកប្រាស់យកតែអាយុរៀង១ខ្លួន។ ដោយហេតុនេះហើយទើបបឹងនេះមានឈ្មោះថា បឹងរាល រហូតមកដល់សព្វថ្ងៃនេះ ។

គាត់បានមានប្រសាសន៍ទៀតថា កាលពីដើមបឹងរាលនេះមានព្រៃរនាមដុះយ៉ាងក្រាស់នៅជុំវិញបឹង និងដើមឈើធំៗជាច្រើនដូចជា ដើមរាំង ដើមតាអួរ ដើមត្រឡុកខ្សេវ ខ្ទុំ ផ្តៅល ដែលមានមុខកាត់ជាង ១ម៉ែត្រ និងកំពស់ពី១០ទៅ១៥ម៉ែត្រ ឈើ

ធំៗទាំងនេះច្រើនកាប់ដាក់កប៉ាល់ធ្វើអុសយកទៅលក់នៅភ្នំពេញ និងកំពង់ឆ្នាំង។ចំណែកសត្វស្លាបវិញក៏មានច្រើនណាស់ដូចជាសត្វទុង ត្រដក់ រនាល ក្រៀល ក្រសា ខ្វែក កុក ស្មោញ ក្អែកទឹក ហើរចុះឡើងនៅលើផ្ទៃបឹងដើម្បីចាប់ត្រីធ្វើចំណី រីឯសត្វក្រពើ ពស់វែក ពស់ថ្លាន់ អណ្តើក កន្ធាយ និងសត្វព្រៃមានដំរី ខ្លារខិន ខ្លាត្រី ខ្លាធំ ប្រើស រមាំង ចចក ជ្រូកព្រៃមានយ៉ាងច្រើនសន្ធឹកសន្ធាប់ ជាពិសេសត្រីនៅជំនាន់នោះសំបូរណាស់ហើយធំៗទៀតផងដូចជា ត្រីរ៉ស់ ត្រីឆ្តោរ ត្រីសណ្តាយ ត្រីក្រហោ ត្រីគល់រាំង ត្រីក្រាយ ត្រីត្រសក់ ត្រីកន្រ្ទប់ខ្លា ដែលមានទំងន់ពី១០ទៅ២០គីឡូក្រាមក្នុង១ក្បាល រីឯត្រីរៀលវិញក្នុង១ក្បាលមានទំងន់ពី ៣ខាំទៅកន្លះគីឡូក្រាម ។

បឹងរាលមិនគ្រាន់តែចិញ្ចឹមជីវិតប្រជាពលរដ្ឋក្នុងឃុំកំពង់គោនោះទេ មានថែមទាំងប្រជាពលរដ្ឋជាច្រើនក្នុងឃុំ និងស្រុកដទៃទៀតបានទៅនេសាទត្រីនៅបឹងរាលនេះដែរ មានដូចជាប្រជាពលរដ្ឋមកពីស្រុកកំពង់ស្វាយ ស្ទឹងសែន ស្ទោង សន្ទុក និងមួយភាគទៀតមកពីស្រុកបារាយណ៍។ ចំពោះឧបករណ៍ចាប់ត្រីជំនាន់នោះ មានអង្រុត សម មង ឆ្នុក ស្ន អួន អញ្ចងក្រឡាធំៗ។ល។ ផលនេសាទដែលបានមកគេច្រើនតែវះធ្វើជាត្រីងៀត ត្រីឆ្អើរ ប្រហុក ផ្អកសំរាប់ទុកធ្វើម្ហូបនៅរដូវដកស្ទូង ហើយសល់ពីនេះគេច្រើនដូរជាស្រូវអង្ករ រឺលក់ជាប្រាក់ខ្លះៗ រឺក៏ចែកគ្នាហូបខ្លះៗផងដែរ ហើយពួកគេទាំងអស់នេះច្រើនចុះមកនេសាទនៅរដូវច្រូតកាត់ ហើយត្រលប់ទៅស្រុកវិញនៅពេលជិតចូលឆ្នាំខ្មែរដោយមកជាក្រុម និងបរទេះ ព្រមទាំងថ្មើរជើង។ គាត់បានបញ្ជាក់ថា ក្រោយពីរបបប៉ុលពតឆ្នាំ១៩៧៩មក ពពួកសត្វដែលធ្លាប់តែសំបូរ

ថែបទាំងនេះឃើញថា នៅមានច្រើន ជាពិសេសត្រី និងព្រៃរនាម។ ក្រោយមក ដោយសារមានកំណើនប្រជាពលរដ្ឋច្រើន និងតំរូវការដីសំរាប់ធ្វើស្រែ ពួកគាត់បាន នាំគ្នាកាប់ព្រៃលិចទឹកធ្វើស្រែប្រាំង ធ្វើចំការ ជាហេតុធ្វើអោយបាត់បង់ជំរកត្រី សត្វ ព្រៃ និងធ្វើអោយដីចេះតែហូរចូលនិងបាក់ច្រាំងដែលបង្កអោយផ្ទៃបឹងចេះតែធំ និង ផ្ទៃខាងក្នុងចេះតែរាក់ទៅៗ។ លើសពីនេះ ប្រជានេសាទទាំងអស់បាននាំគ្នាប្រើប្រាស់ ឧបករណ៍ចាប់ត្រី ការនេសាទត្រីខុសច្បាប់ដូចជានៅរដូវត្រីពងកូន ការចាប់កូនត្រីធ្វើ ជាចំណីសត្វ និងធ្វើជីជាដើម កត្តាទាំងនេះហើយទើបបណ្តាលអោយធនធានទាំងនេះ ត្រូវបាត់បង់ និងខូចខាតយ៉ាងធ្ងន់ធ្ងរជា ពិសេសការបូមទឹកពីបឹងដើម្បីធ្វើស្រែប្រាំង។ ក្រៅពីនេះ អ្នកបរបាញ់មួយចំនួនបាននាំគ្នាប្រើប្រាស់ថ្នាំពុលដើម្បីសំលាប់សត្វ ការវាយ លុប និងការប្រើឧបករណ៍សំលេងក្នុងការចាប់សត្វដែលបណ្តាលអោយបាត់បង់ស្ទើរ តែបាត់ពូជនាពេលបច្ចុប្បន្ននេះ។ ដូច្នេះគាត់បានសំនូមពរទៅរាជរដ្ឋាភិបាលជួយទប់ស្កាត់ និងចាត់វិធានការយ៉ាងម៉ឺងម៉ាត់ចំពោះជនល្មើស និងសុំកុំអោយមានការកាប់ព្រៃលិចទឹក បន្តទៅទៀត ។

# បឹងក្បាលព្រួស

បឹងក្បាលព្រួសជាបឹងមួយស្ថិតនៅភូមិផាត់សណ្ដាយ ឃុំផាត់សណ្ដាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។ បឹងនេះមានប្រវែងបណ្ដោយ២គីឡូម៉ែត្រ និងទទឹង៤០០ម៉ែត្រ ទៅ៥០០ម៉ែត្រនៅរដូវវស្សា ហើយមានដៃពីរដែលដៃមួយហូរពីស្ទឹងសែន ហើយដៃមួយទៀតហូរពីបឹងទន្លេសាបចូលមកក្នុងបឹងនៅរដូវទឹកឡើង។ នៅរដូវប្រាំង ទឹកត្រូវហូរចេញតាមដៃទាំងពីរ។ បឹងនេះមានចំងាយ៨៣គីឡូម៉ែត្រ ពីខេត្តកំពង់ធំ ហើយចំងាយពីភូមិកំពង់ចំលង ៧គីឡូម៉ែត្រ និងដោយបឹងនេះទទួលទឹកពីទន្លេសាប នៅរដូវវស្សាទឹកមានជំរៅពី៨ទៅ៩ម៉ែត្រ ចំណែករដូវប្រាំង បណ្ដោយប្រវែង ១គីឡូម៉ែត្រ ទទឹងពី១០០ទៅ ១៥០ម៉ែត្រ និងជំរៅ១.៥ម៉ែត្រ។

បើតាមការសំភាសន៍របស់លោកតា **សាំង សូរ** អាយុ៧៥ឆ្នាំ ដែលមានស្រុក កំណើតនៅក្នុងភូមិអនង្សាចំបក់ ស្រុកក្រគរ ខេត្តពោធិ៍សាត់ រហូតដល់គាត់អាយុបាន២៧ឆ្នាំ បានមករស់នៅក្នុងឃុំផាត់សណ្ដាយ ខេត្តកំពង់ធំនេះ។ គាត់មានកូន៣នាក់ ហើយគាត់គឺជាប្រជានេសាទសុទ្ធសាធ។ គាត់តែងតែធ្វើនេសាទនៅបឹងនោះទាំងប្រាំង និងវស្សាដោយប្រើប្រាស់ឧបករណ៍បុរាណ និងការគៀរហឿន កំផ្លោក



**ទិដ្ឋភាពបឹងភាពមើលពីចំងាយ**

ដើម្បីចាប់យកត្រី និងប្រភេទសត្វផ្សេងៗទៀត ដែលគាត់ត្រូវការក្នុងការលក់ដូរ និងបរិភោគប្រចាំថ្ងៃ។ គាត់បានមានប្រសាសន៍បន្តទៀតថា ប្រវត្តិបឹងក្បាលព្រួសសព្វថ្ងៃគ្មាននរណាម្នាក់ដឹងពិតប្រាកដទេចាប់តាំងពីគាត់មករស់នៅភូមិនេះ គាត់ធ្លាប់តែលឺគេហៅតគ្នាថា បឹងក្បាលព្រួសតៗគ្នារហូតមក ប៉ុន្តែកាលពីដើមនៅជុំវិញបឹងនេះមានព្រៃដុះក្រាស់ ព្រមទាំងមានដើមឈើធំៗជាច្រើនដូចជា ដើមរាំង ផ្តៅល ខ្ទុំ។ល។ បឹងនេះសំបូរទៅដោយថ្កុក ត្រពាំង និងឈូង ឆក នៅក្បែរមាត់បឹងជាកន្លែងសំរាប់ត្រីកុំនិងសត្វល្អូន រីឯសត្វស្លាបវិញមានច្រើនប្រភេទគឺសំបូរទៅដោយសត្វស្មោញ ក្អែកទឹកប្រវឹក កុក មាន់ទឹក ទោម ក្រសា ក្អែក។ល។ សត្វទាំងនេះគេតែងប្រទះឃើញគ្រប់ទីកន្លែងនៃបរិវេណបឹង។ សត្វមាឌធំក្នុងសម័យនោះក៏មានសត្វ ដំរី ឆ្កែចចកខ្លាត្រី ខ្លាឃ្មុំ ពួកនេះភាគច្រើនតែងតែចុះមកនៅរដូវប្រាំងដើម្បីរកចំនី និងមកលេងទឹកក្បែរបឹងនោះ ព្រមទាំងមានសត្វស្វាជាច្រើនទៀត ដែលរស់នៅក្នុងព្រៃស្តុក និងដើមឈើធំដែលដុះជុំវិញ។ គាត់បានបញ្ជាក់ទៀតថា នៅក្នុងបឹង និងព្រៃរនាមក៏សំបូរទៅដោយសត្វល្អូនជាច្រើនដូចជា សត្វក្រពើ ពស់វែក ពស់ថ្លាន់ និងពស់គ្មានពិសជាច្រើន រួមមានពស់ព្រលិត ពស់ ក្រចាន់ ពស់សង់សឿ។ល។ កន្លែងបឹងនេះគឺជាតំបន់មួយដែលមានសារៈសំខាន់ណាស់សំរាប់ប្រជានេសាទ ព្រោះបឹងនេះសំបូរទៅដោយត្រីធំៗដូចជា ត្រីឆ្តោរ ត្រីរ៉ស់ ត្រីក្អែក ត្រីឆ្ញៀប ត្រីគល់រាំង ដែលមានទំងន់ពី៥ទៅ ៦គីឡូក្រាម និងត្រីតូចៗជាច្រើនប្រភេទទៀតដូចជាត្រីក្រាញ់ ច្រវ៉ាកញ្ជះ ត្រីរៀល ត្រីកន្ទ្រប់ ដែលប្រភេទ ត្រីតូចៗទាំងនេះតែងនាំគ្នាមកពងកូន

នៅទីណាដែលរាក់ហើយត្រជាក់ តែបើយើងពិនិត្យមើលលើត្រីដែលធំបំផុតប្រចាំបឹងវិញនោះមានទំងន់ពី១២ ឬ១៣គីឡូក្រាម ពួកវាមិនដែលមកលេងក្បែរទឹករាក់ទេ ភាគច្រើននៅទីណាដែលមានទឹកជ្រៅ ជាពិសេសចំកណ្ដាលបឹង។ ចំពោះអ្នកមកនេសាទភាគច្រើនមកពីស្រុកសន្ទុក បារាយណ៍ កំពង់ ស្វាយ និងស្ទោងព្រមទាំងជីក្រែងនៅខេត្តសៀមរាប អ្នកទាំងនោះចាប់ចុះមករកត្រីក្នុងបឹងនោះតាមទំលាប់គឺក្នុងខែកុម្ភៈដោយធ្វើដំណើរជាក្រុម និងមានរបស់របរគ្រប់គ្រាន់សំរាប់រយះពេលដែលគេមកនេសាទនេះ រហូតដល់ខែឧសភាទើបត្រលប់ទៅភូមិកំណើតវិញ ដោយនាំមកនូវត្រីងៀត ប្រហុក ផ្អកគ្រប់ប្រភេទ ចំពោះឧបករណ៍ ដែលគាត់យកមកនេសាទក្នុងបឹងនេះមានដូចជាអង្រុត ស្នផ្លែ១ សមផ្លែបី អញ្ចង ក្រលា៩ហ៊ុន ក្រោយពីនេសាទបានហើយពួកគាត់បានយកត្រីទាំងអស់នោះមកវះហាលងៀតដើម្បីយកទៅលក់ ឬសំរាប់ទុកដើម្បីផ្គត់ផ្គង់គ្រួសារ។ ក្រៅពីវះងៀតហើយនោះ ចំពោះកូនត្រីតូចល្មម គេយកធ្វើជាប្រហុក ផ្អក ត្រីឆ្អើរ ប្រលាក់ ដើម្បីយកទៅផ្ទះ ខ្លួនវិញ។ ដោយឡែកបច្ចុប្បន្ននេះ បឹងក្បាលព្រួសមានព្រៃរនាមដុះព័ទ្ធជុំវិញដដែល ប៉ុន្តែសំបូរទៅដោយប្រភពព្រៃលិចទឹក។ ចំនែកសត្វស្លាបមិនសំបូរទេ តាមគាត់សង្កេតឃើញតែមាន់ទឹកកុក និងក្រសា ចំណែកសត្វព្រៃ និងសត្វដីរីខ្លាត្រូវបាត់បង់ ឯស្វានៅមានតិចតួចព្រមទាំងសត្វល្មូនក៏សំបូរ។ ការបាត់បង់ទាំងនេះបណ្ដាលមកពីការរបរបាញ់របស់អ្នកប្រមាញ់ និងការវាយលុកយកសត្វ ការដាក់ថ្នាំបំពុលនៅតាមវាលពេលវាចេញរកចំណី។ ចំពោះក្នុងបឹងវិញមានភាពប្រែប្រួលច្រើនដូចជាជំរៅត្រូវរាក់ ហើយកំផ្លោក

បឿនជាពិសេសវារីជាតិត្រូវបាត់បង់ច្រើន និងផ្ទៃបឹងទៅជាស្រឡះធេង។ បរិមាណធនធានត្រីបានថយចុះស្ទើរបាត់បង់អស់ហើយ ដោយសារការនេសាទរបស់ពួកប្រជានេសាទមួយចំនួនដែលប្រើឧបករណ៍នេសាទដូចជា ការអូសអួនក្រឡាញឹកគ្រប់ប្រភេទ ការកៀរត្រីដោយព្រួល មង លប ជុច ឆក់ និងការដាក់សំរាស់ជាច្រើន។ ត្រីមួយចំនួនស្ទើរតែបាត់បង់អស់ដូចជា កញ្ចុះ ត្រីកំភ្លាញ រៀល និង ត្រីក្រាញ់ (ត្រីតូចៗទាំងអស់នេះសុទ្ធតែជានុយរបស់ត្រីធំៗដែលជាត្រីចិញ្ចឹមរបស់ប្រជានេសាទជាលក្ខណៈគ្រួសារ) និងត្រីអណ្តែងប៉ុណ្ណោះ ចំណែកត្រីធំត្រូវថយចុះ និងពូជត្រីខ្លះត្រូវបាត់បង់។ បើតាមប្រសាសន៍លោក **លេង សុខ** បានអោយដឹងថា ក្នុង១ឆ្នាំគេយកត្រីពីបឹងនោះចំនួន២០ទៅ ៣០តោន ដើម្បីយកទៅលក់ធ្វើជានុយ ត្រី ឆ្អើរធ្វើប្រហុក ផ្អក ។

តាមទស្សនះរបស់លោក លេង សុខ គាត់សង្កេតឃើញថាឆ្នាំ ២០០៥នេះប្រជាពលរដ្ឋមួយចំនួនមកកាប់ ព្រៃធ្វើជាស្រែប្រាំង និងអ្នកមួយចំនួនដែលមកនេសាទជាពិសេសនៅតំបន់ខាងលើគេប្រើឧបករណ៍ទំនើបៗដូចជាឆក់ អួនក្រលាស្បៃមុង និងការចាប់បូមបាច គាត់គិតថាទៅថ្ងៃអនាគត បឹងនេះអាចមានការបាត់បង់នូវពូជត្រី និងបរិមាណថយចុះ ចំណែកទឹកបឹងក៏ប្រហែលជានឹងត្រូវអស់ដែរដោយសារការធ្វើស្រែប្រាំង។ សកម្មភាពទាំងនេះធ្វើអោយក្លាយទៅជាបញ្ហាយ៉ាងធ្ងន់ធ្ងរសំរាប់ប្រជានេសាទ និងអ្នកដែលឃ្វាលគោ ក្របីព្រោះពួកគេនឹងត្រូវអត់ទឹកអោយគោ ក្របីផឹក ជាហេតុធ្វើអោយប្រជាពលរដ្ឋនៅភូមិមួយចំនួនអស់ក្តីសង្ឃឹម និងព្រួយបារម្ភយ៉ាងខ្លាំងពីអនាគត ។ ដូចនេះគាត់បានសំនូមពរអោយជួយទប់ស្កាត់ការចាប់កូនត្រីធ្វើជានុយ និងទប់ស្កាត់ការកាប់ព្រៃធ្វើស្រែប្រាំង។

# ប្រវត្តិបឹងដំរីស្លាប់

នៅក្នុងភូមិស្រីងងិត ឃុំចំណារក្រោម ស្រុកស្ទោង ខេត្តកំពង់ធំនៅភាគខាងលិចនៃភូមិចំងាយប្រហែលជា ២៣គីឡូម៉ែត្រ មានបឹងមួយដែលមានទំហំមិនសូវធំប៉ុន្មានទេ ប៉ុន្តែនៅជុំវិញបឹងមានដើមឈើជាច្រើននិងមានខ្យល់ អាកាសត្រជាក់ស្រួលដែលធ្វើអោយក្រុមអ្នកស្រាវជ្រាវដែលធ្វើដំណើរយ៉ាងឆ្ងាយ និងមានការនឿយហត់មានអារម្មណ៍ត្រជាក់ស្រួលនិងមិនចង់ទៅណាឆ្ងាយពីបឹងនេះទេ។បើតាមការសាកសួរចាស់ៗដែលមករកនេសាទនៅបឹងនេះបានអោយដឹងថាបឹងនេះគឺឈ្មោះ *បឹងដំរីស្លាប់* ។

តាមការសំភាសន៍លោក **ឃុត ស៊ត** មានអាយុ ៥៧ឆ្នាំ និងប្រពន្ធឈ្មោះឯក សឿង អាយុ៤២ឆ្នាំ មានកូន៨នាក់ ប្រុស៤នាក់ ស្រី៤នាក់ដែលរស់នៅក្នុងភូមិស្រីងងិត និងមានមុខរបរជាអ្នកនេសាទនៅបឹងនេះបាននិទានប្រាប់យើងពីដំណើររឿងដែលបណ្តាលអោយគេដាក់ឈ្មោះថា បឹងដំរីស្លាប់នេះថា: កាលពីដើមនៅបឹងនេះសំបូរសត្វដំរីណាស់ និងជាកន្លែងដែលសត្វដំរីធ្វើដំណើរឆ្លងកាត់ទៅរកស៊ីនៅតាមតំបន់ផ្សេងៗផងដែរ។ ជារៀងរាល់ថ្ងៃ នៅម៉ោងប្រហែល៣ ហ្វូងដំរីទាំងនោះតែងតែនាំគ្នាចុះមកបឹងដើម្បីងូតទឹក និងលេងទឹក។ នៅថ្ងៃមួយមានតា ឈឹម បានទៅនេសាទនៅបឹងនេះ តែដោយ



**លោក ឃុត ស៊ត**

សារសង្កេតឃើញ ថ្ងៃកាន់តែក្តៅហើយ ម៉្យាងភ័យខ្លាចជួបប្រទះហ្វូងដំរីផងដែលតែង តែចុះមកក្បែរបឹងនេះនៅពេលថ្មើរនេះផង គាត់ក៏បានរត់ទៅពួននៅលើដើមឈើ មួយ។ រំពេចនោះ ស្រាប់តែមានហ្វូងដំរីកំពុងដើរសំដៅមកក្បែរបឹងដើម្បីងូតទឹក លុះ មួយសន្ទុះមក ក៏មានមេដំរីមួយក្បាលបានហៅហ្វូងដំរីអោយត្រឡប់ទៅវិញហើយ ស្រាប់តែមានដំរីមួយក្បាលឡើងមិនរួចពីបឹងដោយសារជើងវាជាប់ផុងនឹងភក់ ហើយវា ធ្វើយ៉ាងណាក៏រើខ្លួនចេញមិនរួចឡើយអស់រយៈពេល២-៣ថ្ងៃ។ ដោយសារដំរីនោះ អត់ចំណី និងត្រាំនៅក្នុងទឹកយូរថ្ងៃពេក វាក៏បានស្លាប់នៅក្នុងបឹងនេះតែម្តងទៅ។ ចំណែកគាត់ដែលបានសង្កេតឃើញថា ដំរីនេះបានស្លាប់ហើយ ក៏តែងដំណាលប្រាប់ ប្រជានេសាទដែលចុះទៅរកនេសាទនៅបឹងនេះនោះថា *បឹងដំរីស្លាប់* រហូតមកដល់ សព្វ ថ្ងៃនេះ ។

គាត់បានរៀបរាប់ដោយដឹងទៀតថា កាលពីដើម បឹងដំរីស្លាប់នេះសំបូរទៅ ដោយព្រៃលិចទឹកដុះក្រាស់ខ្លាំងណាស់ មិនអាចរុកចូលបានដោយងាយស្រួលឡើយ។ បឹងនេះមានចំងាយពីបឹងទន្លេសាបប្រមាណ៤គីឡូម៉ែត្រ។ នៅរដូវវស្សាបឹងនេះតែង ទទួលរបបទឹកពីទន្លេសាប និងមានជំរៅពី៧ទៅ៨ម៉ែត្រ ចំណែកនៅរដូវប្រាំង បឹង នេះមានបណ្តោយពី១០០ទៅ១៥០ម៉ែត្រ និងជំរៅទឹក១ម៉ែត្រប៉ុណ្ណោះ។ នៅក្នុងបឹង សំបូរទៅដោយវារីជាតិដូចជាកំប្លោក ចក សារាយ កក់ កំពេញពួយដែលជាចំនី និង ជាជំរករបស់មច្ឆាជាតិគ្រប់ប្រភេទ។ នៅតំបន់ជុំវិញបឹងនេះមានដើមឈើធំៗជាច្រើន ដូច ជាដើម ត្រសែង ជាំព្រីង រាំង ថ្កោល ត្រសេក តាអួរ ផ្ទោល ភ្នំភ្លើង ត្រស់

ប្របួយ អញ្ចាញ ត្រែង និងដើមឈើធំៗជាច្រើនទៀតមានទំហំពី៤ទៅ៥អោបដែល ជាជំរករបស់សត្វស្លាប និងសត្វព្រៃគ្រប់ប្រភេទ ហើយកំរមាននរណាម្នាក់ទៅរុករានព្រៃដើម្បីសំរាប់ពួកវាបានឡើយ។នៅរដូវសំរកផ្ទៃបឹងរួមតូចដែលបន្សល់នូវមច្ឆាជាតិគ្រប់ប្រភេទនៅក្នុងបឹងដូចជាត្រីគល់រាំង ត្រីឆ្តោរ ត្រីរ៉ស់ ត្រីឆ្ពិន ត្រីគ្រុំ ត្រីពោធិ៍ ត្រីក្អែក ត្រីរាជ ត្រីដំរី ដែលសុទ្ធតែមានទំងន់ចាប់ពី២គីឡូក្រាម។ ជួនកាលប្រជានេសាទអាចចាប់ត្រីមួយទំងន់រហូតដល់៨ ទៅ១០គីឡូក្រាម ហើយអ្នកស្រុកនៅទីនេះមិនដែលយកទៅបរិភោគទេ គេទំលាប់ព្រលែងវាទៅក្នុងបឹងវិញព្រោះគេ តែងតែមានជំនឿថានេះជាមេបឹង និងជាត្រីដែលអ្នកតានៅថែរក្សា។ នៅរដូវសំរកប្រជានេសាទដែលនៅស្រុកខាងលើតែងតែប្រមូលផ្តុំគ្នានៅតាមបណ្តាបឹងតូច ធំដើម្បីស្វែងរកចាប់ត្រីសំរាប់ទុកហូបប្រចាំឆ្នាំ និងនៅពេលមានបុណ្យទានផ្សេងៗ។ ដោយឡែក អ្នកស្រុកដែលធ្លាប់មករកនេសាទនៅក្នុងបឹងនេះ ពួកគេមិនភ្លេចឡើយនូវដង្វាយទៀន ធូបស្លាធម៌សំរាប់សែនថ្វាយអ្នកតាសុំអោយរកត្រីបានច្រើន និងសុំសេចក្តីសុខពីអ្នកតាដែលថែរក្សាតំបន់នេះ។ ពួកគេទាំងនោះច្រើនមកពីក្នុងបណ្តាភូមិនៅក្នុងស្រុកស្ទោងស្រុកកំពង់ស្វាយ និងភូមិចំណាររក្រោម ចំណារលើ ដំរីស្លាប់ រួមទាំងប្រជាពលរដ្ឋដែលមកពីខេត្តសៀមរាប។ កាលពីសម័យមុន ពួកគេច្រើនប្រើឧបករណ៍នេសាទដូចជាអង្រុត ជុច លប ស្ទួ សមផ្ទៃបី ប្របក់ អញ្ចង ទ្រូ មងពាក់។ ចំពោះសត្វស្លាបមានដូចជា ទុង ត្រដក់ ក្រៀល ស្មោញ ប្រវឹក ក្អែកទឹក ត្រយង មាន់ទឹក អកក្រសា ខ្វែក ខ្សិប ត្នាត រនាល សេក ។ល។ សត្វទាំងនេះមានរាប់ពាន់ក្បាល

ព្រៃទាំងមានសត្វល្មនដូចជា អណ្តើក កន្ធាយ ភេ ពស់វែកក្របី ពស់ទ្រលងវនាម ពស់ក្រចាន់ ពស់ព្រលិត ពស់ថ្លាន់ ជាដើម។ ដោយនៅតំបន់នេះសំបូរទៅដោយព្រៃឈើធំៗបង្កលក្ខណៈងាយស្រួលដល់សត្វព្រៃធ្វើជាជំរក និងស្វែងរកចំណីបានយ៉ាងងាយស្រួ លធ្វើអោយតំបន់នេះសំបូរសត្វព្រៃច្រើនណាស់ដូចជា ប្រើស រមាំង ខ្លាតូច ខ្លាធំ ជ្រូកព្រៃ ចចក ឈ្លូស ជាពិសេសសត្វដំរីសំបូរណាស់។

គាត់បានបន្តទៀតថា ពីមុនដោយសារតែធនធាននៅតំបន់នេះសំបូរដែលបង្កលក្ខណៈងាយស្រួលដល់ការរស់នៅរបស់ប្រជាពលរដ្ឋ ហើយជីវភាពប្រជាពលរដ្ឋមានលក្ខណៈធូរធារច្រើន។ លុះមកដល់បច្ចុប្បន្ន ដោយសារតែការវិវឌ្ឍន៍របស់មនុស្ស និងកំណើនប្រជាពលរដ្ឋបានបំផ្លាញធនធានដែលធ្លាប់សំបូរពីមុនមកស្ទើរទាំងស្រុង ហើយព្រៃលិចទឹកនៅតំបន់នេះត្រូវបានគេដុត និងកាប់ឆ្ការធ្វើស្រែប្រាំង ជាពិសេសការដាំឈូកគឺច្រើនណាស់ ការបរបាញ់សត្វ ដាក់ថ្នាំបំពុល ដាក់អន្ទាក់ ចាប់យកសត្វព្រៃ និងបក្សាបក្សីមួយចំនួនត្រូវផុតពូជអស់ទៅហើយ។ បច្ចុប្បន្នតំបន់នេះគេធ្លាប់ឃើញមានតែសត្វកុក ក្រសា មាន់ទឹក ពីរទៅបីក្បាលប៉ុណ្ណោះ។ ការវិវឌ្ឍន៍របស់មនុស្ស និងឧបករណ៍ទំនើបៗដូចជាក្បាលឆក់ត្រី ស្បៃមុង អួនក្រឡាញឹកបានធ្វើអោយត្រីបាត់បង់អស់យ៉ាងច្រើនដែលឈានទៅដល់ការផុតពូជនៅពេលអនាគត់ ។

# ប្រវត្តិបឹងពាក់ព្រ័ទ្ធ

ប្រទេសកម្ពុជា ជាប្រទេសមួយដែលសំបូរទៅដោយសម្បត្តិធម្មជាតិមាន សមុទ្រ ទន្លេ ស្ទឹង បឹងបួរ ដងអូរ រ៉ែមាស រ៉ែដែក ត្បូង ថ្មបងថ្ម ព្រៃស្រោង ព្រៃលិចទឹក មច្ឆាជាតិ សត្វចតុបាត សត្វស្លាបគ្រប់ប្រភេទ។ ដោយឡែកនៅក្នុង ទឹកដីឃុំចំណារក្រោម ស្រុកស្ទោង ខេត្តកំពង់ធំមានបឹងមួយឈ្មោះថា *បឹងពាក់ព្រ័ទ្ធ* ដែលស្ថិតនៅវាលទំនាបស្របមាត់ទន្លេសាបប៉ែកខាងកើត ហើយនៅសងខាងបឹងពោរ



**លោក សែម រិន**

ពេញទៅដោយវាលស្រែប្រាំងយ៉ាងច្រើន ប្រហែលជា១៥០ហិតា។តាមការសំភាសន៍ លោកតា **សែម រិន** មានអាយុ៦១ឆ្នាំ និងប្រពន្ធឈ្មោះ ហៀង មុន អាយុ ៥៩ឆ្នាំ ដែលមានកូនស្រី០៣នាក់ និង ប្រុស០២នាក់នៅក្នុងបន្ទុក។ គ្រួសារ របស់គាត់ជាអ្នកនេសាទសុទ្ធសាធដែលតែងតែមកនេសាទនៅបឹងនេះ ជារៀងរាល់ ឆ្នាំ។ គាត់បានរៀបរាប់អោយដឹងថា បឹងពាក់ព្រ័ទ្ធនេះបើគិតពីស្ពានអង្រ្កងនៃឃុំចំណារ ក្រោមមកមានចំងាយពី៣០ ទៅ៣៥គីឡូម៉ែត្រ ។ នៅរដូវវស្សាបឹងនេះមានបណ្តោយ ប្រវែង ១៥០០ម៉ែត្រ និងទទឹង ៦០ម៉ែត្រ ជំរៅពី១០ ទៅ១២ម៉ែត្រ។ ចំណែកនៅ រដូវប្រាំងមានជំរៅ២ម៉ែត្រ។ បឹងនេះមានព្រំប្រទល់ខាងជើងជាប់នឹងក្បាលក្រពឺង ខាង លិចជាប់នឹងបឹងពាក់ថែប ខាងត្បូងជាប់នឹងត្រពាំងក្របីស្លាប់ ខាងកើតជាប់នឹង ក្បាល

ត្រពាំងចោរ។ បឹងនេះមានអូរមួយចំនួនដែលជាដៃ របស់បឹងមានដៃក្បាលកំពីង ទីពីរគឺដៃខ្មៅ ទីបីគឺដៃបឹងផ្ទៅ។ កាលពីដើមឡើយ បឹងនេះមិនទាន់មានឈ្មោះនៅឡើយទេ ក្រោយមកទៀតមានក្របីស្រុកមួយក្បាលយ៉ាងធំបានស្លាប់នៅមាត់បឹង ពេលនោះក្រុមអ្នកនេសាទប្រទះឃើញក៏នាំគ្នាពន្លះយកសាច់ក្របីនោះយកសាច់ធ្វើជាម្ហូប និងជារស្បែកធ្វើជាព្រ័ន្ធ ហើយដាក់ហាលស្បែកព្រ័ន្ធនោះនៅមាត់បឹងនេះ តាំងពីពេលនោះមកប្រជានេសាទនៅទីនោះដាក់ឈ្មោះបឹងនេះថា *បឹងពាក់ព្រ័ន្ធ*។ គាត់បានរៀបរាប់អោយដឹងទៀតថា ពីដើមនៅតំបន់បឹងនេះមានព្រៃរនាមដុះយ៉ាងក្រាស់ ដែលផ្តល់លក្ខណៈងាយស្រួលដល់ពពួកមច្ឆាជាតិរស់នៅនិងពងកូន និងមានដើមឈើធំៗដុះជុំវិញបឹងនោះដែលអាចអោយពពួកសត្វព្រៃ និងបក្សាបក្សីរស់នៅបានយ៉ាងងាយស្រួល។ នៅក្នុងបឹងនោះសំបូរទៅដោយមច្ឆាជាតិគ្រប់ប្រភេទរួមមាន ត្រីរ៉ស់ ត្រីឆ្តោរ ត្រីអណ្តែងត្រីតាអោន ត្រីក្រពាត់ ត្រីកន្ធរ ត្រីកញ្ចុះ ត្រីឆ្លាំង ត្រីតានេល ត្រីក្រាញ់ និងត្រីផ្សេងៗទៀតជាច្រើន ហើយត្រីដែលអ្នកស្រុកធ្លាប់ចាប់បានទំងន់ពី៥ ទៅ៧គីឡូក្រាម។ ប្រជាពលរដ្ឋទំលាប់ទៅនេសាទនៅក្នុងបឹងនោះជារៀងរាល់ឆ្នាំដើម្បីរកត្រីមក ធ្វើជាផ្អកប្រហុក ត្រីឆ្អើរ ត្រីងៀត ត្រៀមទុកសំរាប់រដូវដែលរវល់ការងារ និងទុកសំរាប់ចែកគ្នាហូបចំពោះគ្រួសារក្រីក្រ។ ចំពោះឧបករណ៍សំរាប់នេសាទអ្នកស្រុកប្រើប្រាស់តែឧ-បករណ៍បែបបុរាណមាន មង អង្រុត ស្ទូ ឈ្នាង សម សន្ទូច ហើយអ្នកដែលមកនេសាទនៅបឹងនេះមានអ្នកមកពីឃុំដីរស្លាប់ ឃុំចំណារក្រោម ឃុំចំណារលើ ឃុំស្ពានអង្រ្កង ឃុំសាន់គរ ឃុំសំព្រោច អ្នកស្រុកស្ទោង ដោយថ្មើរជើង ជួនកាលនាំគ្នាបរ-

រទេះគោ ក្របីជាក្រុមដែលមានចំងាយពីភូមិយ៉ាងតិចក៏២៨គីឡូម៉ែត្រ។ ការធ្វើដំណើរដោយជើង ជួនកាលមានដេកផ្លូវចំនួនពីរ ទៅបីយប់ទើបត្រឡប់មកកាន់ភូមិវិញ ដោយមិនហ៊ាន ស្នាក់នៅយូរទេព្រោះខ្លាចជួបពពួកសត្វព្រៃដូចជាហ្វូងដំរី ក្របីព្រៃ ខ្លាពស់ និងសត្វសាហាវផ្សេងៗ។ នៅតាមមាត់បឹងសំបូរទៅដោយ ពពួកសត្វស្លាបជាច្រើន ប្រភេទ ដូចជា កុក ក្រសា ស្មោញ ទុង រនាល ត្រដក់ ទោម មាន់ទឹក ប្រវឹក រំពេរ ឯអូត សេក លលក ត្រយង។ ល។

រហូតមកដល់សព្វថ្ងៃនេះ គាត់ឃើញថាព្រៃរនាមមិនមានទៀតទេ ធនធានធម្មជាតិផ្សេងៗទៀត ដែលធ្លាប់តែសំបូរនៅជុំវិញបឹងនេះមិនមានដូចពីមុនទេ ដោយសារសង្គ្រាមធ្វើអោយភ្លើងឆេះព្រៃមួយចំនួនធំ និងកំណើនប្រជាពលរដ្ឋដែលឈានទៅរកតំរូវការកាន់តែច្រើនឡើង។ ឥឡូវនេះ ប្រជាពលរដ្ឋមួយចំនួនបានបំផ្លិចបំផ្លាញព្រៃ និងដុតព្រៃដើម្បីយកដីធ្វើស្រែប្រាំងយ៉ាងច្រើនសន្ធឹកសន្ធាប់។ ម្យ៉ាងទៀត ជនល្មើសមួយចំនួនបានធ្វើការបរបាញ់ដោយកាំភ្លើង ដាក់អន្ទាក់ ដាក់ថ្នាំ បំពុល និងការប្រើឧបករណ៍បំពងសំលេង ដើម្បីចាប់សត្វដែលធ្វើអោយពពួកសត្វទាំងនោះផុតពូជ និងរត់ភៀសខ្លួនទៅកាន់តំបន់ផ្សេងៗ។ បច្ចុប្បន្នតំបន់នេះគេឃើញមានតែមាន់ទឹកកុក ក្រសាពីបួន ឬដប់ក្បាលប៉ុណ្ណោះ ហើយប្រភេទមួយចំនួនគេកំរជួបប្រទះណាស់។ ចំពោះបឹងវិញមានការប្រែប្រួលខ្លាំងណាស់ទាំងជំរៅទឹក និងធនធានក្នុងទឹកដូចជាត្រីត្រូវបាត់បង់អស់យ៉ាងច្រើន ដោយសារការប្រើឧបករណ៍នេសាទខុសច្បាប់មួយចំនួន ដូចជា ឆក់ បូមបាច អួនក្រឡាញ៉ឹក ស៊ៃមុង។ គាត់បានសន្និដ្ឋានថាបើនៅតែមិន

ទប់ស្កាត់អំពើទាំងនេះ ធនធានទាំងនោះនឹងត្រូវវិនាសបាត់បង់នៅពេលខាងមុខទៀត នេះ។ ដូចនេះគាត់បានសំនូមពរអោយអង្គការជាតិ និងអន្តរជាតិទាំងអស់ជួយទប់ស្កាត់ការប្រើឧបករណ៍ខុសច្បាប់ទាំងនេះ និងជួយពង្រឹងការអនុវត្តន៍ច្បាប់អោយមានប្រសិទ្ធភាព ដើម្បីអោយធនធានទាំងនេះឋិតថេរសំរាប់កូនខ្មែរជំនាន់ក្រោយ ។

# ប្រវត្តិបឹងតាពីរ

បើយើងធ្វើដំណើរពីស្រុកស្ទោង ខេត្តកំពង់ធំ តាមផ្លូវជាតិលេខ៦ ចំងាយប្រមាណជា៧គីឡូម៉ែត្រ យើងនឹងទៅដល់ភូមិមួយឈ្មោះថា ភូមិចំណារក្រោម រួចបន្តដំណើរទៅកាន់ភាគខាងលិចនៃភូមិប្រមាណជា ២៩គីឡូម៉ែត្រទៀត យើងនឹងទៅដល់បឹងមួយដែលមានទំហំធំមើលដាច់កន្ទុយភ្នែកគឺបឹងតាពីរ។ បឹងតាពីរគឺជាបឹងដែលមានទំហំធំហើយនៅជាប់នឹងឡូតិ៍លេខ០៩ទៀត ដែលធ្លាប់ល្បីថាជាបឹងដែលសំបូរទៅដោយធនធានធម្មជាតិជាច្រើន ជាពិសេសបឹងនោះសំបូរព្រៃរនាមដែលជាជំរកចំពោះមច្ឆាជាតិគ្រប់ប្រភេទ ។ ដោយសារបឹងនេះមានទំហំធំ និងមានព្រៃលិចទឹកដុះយ៉ាងក្រាស់នៅជុំវិញបឹងនិងដុះនៅចំកណ្តាលបឹងខ័ណ្ឌចែកបឹងនេះជាគ្នាទើបអ្នកភូមិនៅទីនោះហៅបឹងនេះថា បឹងទាំងពីរ តែក្រោយមកគេក៏ក្លាយពាក្យហៅថា បឹងតាពីរវិញ។

តាមប្រសាសន៍លោក **អ៊ឹម ទី**អាយុ ៦២ឆ្នាំនិងប្រពន្ធឈ្មោះ **យ៉ឹម សៀវ** ដែលមានអាយុ៦០ឆ្នាំ រស់នៅក្នុងភូមិនាងនួយ ឃុំចំណារក្រោមស្រុកស្ទោង ខេត្តកំពង់ធំបានមានប្រសាសន៍ថាកាលពីដើមគាត់ជាអ្នកនេសាទមួយរូបដែលតែងតែទៅនេសាទនិងឃ្វាលគោនៅក្នុងបឹងតាពីរ។ បឹងនេះតែងទទួលរបបទឹកទន្លេសាបជារៀងរាល់ឆ្នាំ និងមានចំងាយ៣គីឡូម៉ែត្រ ពីបឹង



**លោកតា អ៊ឹម ទី**

ទន្លេសាប និងពីភូមិចំណារក្រោមប្រហែលជា២៨គីឡូម៉ែត្រ។ នៅរដូវប្រាំង គេអាចធ្វើដំណើរដោយរទេះគោ ម៉ូតូ កង់ និងថ្មើរជើងបាន ទៅដល់បឹងនេះ តែបើនៅរដូវវស្សាវិញ យើងត្រូវធ្វើដំណើរដោយទូក រឺកាណូត។ បឹងនេះនៅរដូវប្រាំងមានបណ្តោយ១៥០០ម៉ែត្រ និងទទឹង៥៥០ម៉ែត្រ មានជំរៅពី១ ទៅ១,៥ម៉ែត្រ ហើយនៅរដូវវស្សាវិញមានជំរៅរហូត៧ ទៅ៨ម៉ែត្រ។ គាត់បានអោយដឹងទៀតថា កាលពីដើមគ្មាននរណាម្នាក់អាចចូលទៅកាប់ព្រៃទាំងនេះបានឡើយ ព្រោះព្រៃទាំងនោះមានអ្នកតាឈ្មោះថា អ្នកតាកែវឆេះព្រំខែតដែលជាអ្នកតាមថែរក្សាព្រៃ និងបឹងនេះ។ នៅជុំវិញបឹងនេះមានដើមរាំងធំៗប្រាំមួយដើមដែលមានទំហំ៥ ទៅ៦អោប ដែលធ្វើអោយអ្នកដែលមកនេសាទ និងឃ្វាលគោនៅបឹងនេះ មកគោរពបូជាសែនដង្វាយផ្សេងៗដើម្បីសុំសេចក្តីសុខ និងរកត្រីបានច្រើន។ គាត់បានបន្តទៀតថា បឹងនេះសំបូរធនធានធម្មជាតិណាស់ បើយើងក្រឡេកទៅមើលតំបន់នេះគឺ ឃើញសុទ្ធតែព្រៃបៃតងស្រស់នៅពាសពេញតំបន់នេះតែម្តងដែលធ្វើអោយត្រី និងសត្វជាច្រើនចូលចិត្តមករស់នៅនៅតំបន់នេះ។ បឹងនេះសំបូរត្រីច្រើនគ្រប់ប្រភេទ ដូចជាត្រីឆ្តោរ ត្រីរ៉ស់ ត្រីកន្ធ្រប់ ត្រីដំរី ត្រីកញ្ជ្រូនជ័យ ត្រីឆ្អិន ត្រីអណ្តែង ត្រីស្លាត ត្រីតាអោន ត្រីក្រម៉ម ត្រីកញ្ចុះ ត្រីក្អែកដែលសុទ្ធតែមានទំងន់ចាប់ពី៦ទៅ៨គីឡូក្រាម និងមានត្រីធំតូចជាច្រើនប្រភេទទៀត។ ចំពោះសត្វល្មូន គឺមានគ្រប់ប្រភេទ ដូចជាអណ្តើក កន្ធាយក្រពើ ភេ ហើយពស់វែក ពស់ថ្លាន់រនាមមានទំហំធំៗដែលអ្នកស្រុកពីសម័យមុនគេហៅថា ជាទូករបស់អ្នកតា ។

គាត់បានរៀបរាប់ប្រាប់យើងបន្តទៀតថា កាលពីគាត់អាយុបាន១៩ឆ្នាំ ពេលគាត់បានទូកទៅរកត្រី និងដាក់ជុចនៅក្នុងបឹងតាពីរនេះស្រាប់តែប្រទះឃើញពស់វែកអាក្រហមកំបុតកន្ទុយដែលមានទំហំប៉ុនដើមត្នោតនៅក្នុងបឹង។ ខណៈនោះលោកតាភ័យណាស់ក៏ប្រឹងអុំទូកត្រលប់ទៅវិញ។ លុះថ្ងៃក្រោយ គាត់ក៏ដូចជាអ្នកនេសាទដ៏ទៃទៀតដែរ ពេលណាចេញទៅនេសាទម្តងៗតែងតែមានការភ័យខ្លាច ព្រោះនៅក្នុងបឹងនេះសំបូរទៅដោយពស់ធំៗណាស់។ មិនតែប៉ុណ្ណោះនៅតំបន់បឹង នេះសំបូរសត្វស្លាបមករស់នៅយ៉ាងច្រើនកុះករដូចជា កុក ក្រសា សេក ខ្វែក ប្រវឹក ក្រៀល ស្មោញក្អែកទឹក ត្រដក់ រនាល មាន់ព្រៃដែលបង្កអោយមានសំលេងខ្ញាវខ្ញាររំពងពេញផ្ទៃបឹងនិងព្រៃដែលពទ្ធ័ជុំវិញបឹងនោះ។ចំណែកសត្វព្រៃដ៏ទៃទៀតដូចជាជ្រូកព្រៃ ខ្លា រមាសរមាំង ក្របីព្រៃ ស្វា ចចក ប្រើស ជាពិសេសសត្វដំរីអោយតែដល់ម៉ោងពារសៀលពួកតែងនាំគ្នាចុះមកផឹកទឹកនៅក្នុងបឹងនេះយ៉ាងច្រើនសន្ធឹកសន្ធាប់។ គាត់បានអោយដឹងទៀតថា ប្រជាពលរដ្ឋភាគច្រើនសុទ្ធតែរស់នៅពឹងផ្អែកលើការនេសាទដូចនេះមានអ្នកភូមិជិតឆ្ងាយជាច្រើនតែងតែបរទេះមកនេសាទនៅបឹងនេះដូចជា អ្នកនៅឃុំចំណារក្រោម ចំណារលើ ភូមិដំរីស្លាប់ ភូមិព្រះដំរី សំព្រោច បន្ទាយស្ទោង អ្នកស្រុកកំពង់ស្វាយ ស្រុកស្ទោង មកនេសាទដោយប្រើឧបករណ៍អង្រុត អញ្ចង ស្ទូសម ផ្លែបី លប ជុច ពេលនេសាទម្តងៗបានរាប់រយគីឡូក្រាម ប្រជាពលរដ្ឋយើងនិយមយកធ្វើជាត្រីងៀត ផ្អក ប្រហុក ដើម្បីទុកហូបនៅពេលចូលឆ្នាំ និងបុណ្យទានផ្សេងៗ ។

តាំងពីសម័យដើមរហូតមកដល់ឆ្នាំ១៩៩៥ ធនធាននៅតែសំបូរបែបគ្រប់យ៉ាងដូចជាត្រី សត្វស្លាប សត្វល្មូន សត្វព្រៃ លើកលែងតែសត្វដំរីដែលបានបាត់បង់អស់យ៉ាងច្រើននៅក្នុងសម័យសង្គ្រាម ដោយសារការទំលាក់គ្រាប់បែក និងស្នូរកាំភ្លើង។ បច្ចុប្បន្ននេះធនធានធម្មជាតិបានបាត់បង់ស្ទើរទាំងស្រុង ហើយ ព្រៃលិចមួយចំនួនទឹកត្រូវប្រជាពលរដ្ឋដុត និងកាប់ឆ្ការដើម្បីដាំឈូក និងធ្វើស្រែប្រាំង ។ ចំណែកត្រីកាន់តែខ្សត់ខ្សោយជាលំដាប់ ដោយសារការប្រើប្រាស់ឧបករណ៍ល្មើសច្បាប់ជាច្រើនដូចជាឆក់ ស្បៃមុង អួនក្រឡាញឹក ការដាក់សំរាស់ដែលធ្វើអោយពពួកត្រីត្រូវផុត។ ឥឡូវនេះ យើងសង្កេតឃើញសល់តែត្រីប្រភេទតូចៗដូចជាត្រីរ៉ស់ ត្រីអណ្តែងត្រីក្រាញ់ ត្រីកញ្ចុះ ត្រីកំភ្លាញ ត្រីស្លាតប៉ុណ្ណោះ។ ចំណែកសត្វព្រៃត្រូវបាត់បង់អោយអស់ហើយ នៅជុំវិញបរិវេណបឹងប្រែមកស្ងាត់ជ្រងំគ្មានលឺសំលេងសត្វទាំងនោះទៀតទេ។គាត់បានសន្និដ្ឋានថា បើសិនការប្រើឧបករណ៍ខុសច្បាប់នៅតែបន្តកើតមានដោយគ្មានការទប់ស្កាត់ ធនធានធម្មជាតិនឹងត្រូវរលាយសាបសូន្យអស់ ហើយអ្នកជំនាន់ក្រោយមុខតែជួបប្រទះនៅបញ្ហាជីវភាពជាក់ជាពុំខាន។ គាត់បានសំនូមពរដល់អ្នកដែលមានអំណាចគួរតែមានជួយទប់ស្កាត់ការកាប់ព្រៃលិចទឹក ការឆក់ត្រី និងដាក់សំរាស់តទៅទៀត ព្រោះវាធ្វើអោយត្រីកាន់តែបាត់បង់។ នៅពេលដែលត្រីត្រូវបាត់បង់គ្រួសារគាត់មុខតែជួបប្រទះនៅបញ្ហាជីវភាពជាក់ជាពុំខានឡើយ ព្រោះគ្រួសារគាត់ក៏ដូចជាអ្នកភូមិរស់នៅពឹងផ្អែកទៅលើមុខរបរនេសាទជាចំបង។

# ប្រវត្តិបឹងកាប់ផ្សោត

បើយើងធ្វើដំណើរពីស្រុកស្ទោង ខេត្តកំពង់ធំ ចំងាយប្រមាណជា៧គីឡូម៉ែត្រ យើងនឹងទៅដល់ភូមិមួយឈ្មោះថា ភូមិចំណារក្រោម រួចបន្តដំណើរទៅកាន់ភាគខាងលិចនៃភូមិប្រមាណជា២៨គីឡូម៉ែត្រទៀត យើងនឹងទៅដល់បឹងមួយដែលមានទំហំធំមើលដាច់កន្ទុយភ្នែកគឺបឹងតាពីរ តែបើយើងក្រឡេកទៅមើលនៅប៉ែកខាងជើងនៃបឹងនេះចំងាយ២គីឡូម៉ែត្រទៀតយើងនឹងឃើញបឹងមួយទៀតដែលមានទំហំតូចជាងបឹងតាពីរ គឺបឹងកាប់ផ្សោត ។

បើតាមប្រសាសន៍របស់លោកតា **មុំ ម៉ម** អាយុ៦៣ឆ្នាំ ដែលជាអ្នករស់នៅភូមិនាងនួយ ឃុំចំណារក្រោម ស្រុកស្ទោង បានរៀបរាប់អោយដឹងថា នៅរដូវប្រាំងបឹងនេះ មានបណ្ដោយ១២០ម៉ែត្រ និងទទឹង១០០ម៉ែត្រ និងមានជំរៅទឹក១ម៉ែត្រ។ នៅរដូវវស្សាបឹងនេះតែងទទួលរងរបបទឹកទន្លេសាបជារៀងរាល់ឆ្នាំ និងមានជំរៅទឹករហូតដល់៧ ទៅ៨ម៉ែត្រ។ គាត់បានតំណាលប្រាប់យើងពីប្រវត្តិបឹងនេះថា កាលពីដើមឡើយបឹងនេះសំបូរសត្វផ្សោតណាស់ និងសំបូរទៅដោយត្រីគ្រប់ប្រភេទ។ ប្រជានេសាទជាច្រើនតែងតែមកនេសាទនៅបឹងនេះដោយប្រើមង អង្រុត លប ពុំដែលខានឆ្នាំណាមួយឡើយ។ នៅថ្ងៃមួយមានអ្នក



**លោកតា មុំ ម៉ម**

នេសាទម្នាក់បានទៅដាក់លបនៅក្នុងបឹងនេះ លុះព្រឹកឡើងគាត់ទៅលើកលប ស្រាប់តែប្រទះឃើញសត្វផ្សោតមួយក្បាលជាប់ក្នុងលបនោះ។ ដោយសារពិបាកយកសត្វផ្សោតចេញពីលបពេក មិនដឹងធ្វើយ៉ាងម៉េច លោកតាម្នាក់នោះក៏កាប់ផ្សោតនោះ ជាបីបួនកង់ដែលធ្វើអោយមានឈាមពាសពេញផ្ទៃបឹង។ ចាប់តាំងពីពេលនោះមក អ្នកនៅទីនោះក៏បានហៅបឹងនេះថា *បឹងកាប់ផ្សោត* រហូតមក។ គាត់បានរៀបរាប់អោយដឹងទៀតថា នៅតំបន់នេះពេលរដូវវស្សាទឹកទន្លេបានស្រោចស្រពពាសពេញតំបន់នេះ ដែលធ្វើអាចអោយពពួកមច្ឆាជាតិគ្រប់ប្រភេទ ចេញពីបឹងទន្លេសាបមករកចំនីប្លែកៗនៅតាមបណ្តាវាលក្រោមនេះធ្វើអោយនៅតំបន់វាលក្រោមនិមួយៗ សំបូរទៅដោយធនធានមច្ឆាជាតិជាច្រើនគ្រប់ប្រភេទ។ ចំណែកព្រៃលិចទឹកវិញបានក្លាយទៅជាជំរករបស់ពពួកមច្ឆាជាតិកន្លែងពងកូន និងបន្តពូជរបស់ពួកវាផងដែរនៅក្នុងរយៈពេលទឹកតំឡើង។ នៅពេលរដូវសំរក តំបន់នេះមានធម្មជាតិស្រស់បំព្រង ព្រមទាំងមានវាលស្រង៉ែដុះខ្ពស់ៗពាសពេញតំបន់នេះ ហើយនៅក្នុងបឹងពោរពេញទៅដោយមច្ឆាជាតិគ្រប់ប្រភេទដូចជាត្រីឆ្ដោរ ត្រីគល់រាំង ត្រីឆ្ពិន ត្រីរ៉ស់ ត្រីពោធិ៍ ត្រី ឡៀប ត្រីដំរីត្រីតាអោន ដែលមានទំងន់ចាប់ពី២គីឡូក្រាមឡើងទៅ។ បើតាមទំនៀមទំលាប់របស់ប្រជាពលរដ្ឋជិតឆ្ងាយដែលមកពីភូមិចំណារលើ ចំណារក្រោម ភូមិព្រះដំរី ភូមិសំព្រោច ជីក្រែង ស្រុកស្ទោង ស្រុកកំពង់ស្វាយ និងមកពីខេត្តសៀមរាបតែងតែចុះមករកនេសាទត្រី និងអោយស្មៅគោក្របី។ ជាទំលាប់នៅសម័យនោះ ពេលអ្នកស្រុកមករកនេសាទត្រីម្ដងៗតែងតែធ្វើការបន់ស្រន់ដល់អារក្ស អ្នកតាតាមថែរក្សាបឹង

និងព្រៃនៅតំបន់នេះនៅតាមដើមឈើធំៗមានទំហំពី៤ ទៅ៥អោប ដើម្បីអោយតាមថែរក្សាពួកគេអោយមានសេចក្តីសុខ និងរកត្រីបានច្រើន។ ឧបករណ៍ដែលគេប្រើសំរាប់នេសាទត្រីនៅសម័យនោះមាន អង្រុត សមផ្លែបី អញ្ចង ស្ទូ មងពាក់ ជុច ប៉ោងប្របក់ ជាដើម។ គាត់បានបញ្ជាក់ថានៅតំបន់បឹងនេះសំបូរព្រៃ សំបូរត្រីធ្វើអោយពួកបក្សាបក្សីទៅណាមិនឆ្ងាយពីបឹងនេះទេ ពួកគាត់ប្រទះឃើញមានសត្វស្លាបគ្រប់ប្រភេទនិងច្រើនណាស់ ជាពិសេសសត្វសេកច្រើនមែនទែនពេលដែលវាផ្អើលម្តងៗ វាហើរឡើងមើលទៅស្រស់ស្អាតមែនទែន ដែលធ្វើអោយផ្ទៃបឹងមានពណ៌បៃតងស្រស់ដូចជាធម្មជាតិដែលនៅជុំវិញបឹងនេះដែរ និងមានសត្វស្លាបជាច្រើនទៀតដូចជា កុក ក្រសាទង់ ទោម ស្មោញ ប្រវឹក ត្មាត ក្អែកទឹក ត្រដក់ ក្រៀល រនាល ខ្វែក.....។ល។ ចំពោះសត្វល្មូនវិញ ពីដើមសំបូរជាងគេគឺសត្វផ្សោតវាចូលចិត្តមករស់នៅ និងបន្តពូជនៅបឹងនេះ ព្រមទាំងមានពស់ធំៗ ភេ អណ្តើក កន្ធាយ ។ល។ ឯសត្វព្រៃដូចជាដំរី ខ្លាធំ ខ្លាតូច ស្វា ចចក ប្រើស រមាំង ជ្រូកព្រៃ ក្របីព្រៃ មានច្រើនរាប់មិនអស់ ពេលដល់រដូវទឹកសំរកវាចុះមករកស៊ីនៅក្បែរបឹងនេះ ហើយពេលរដូវវស្សាទើបវានាំគ្នាឡើងទៅលើវិញពេល វាចុះមកម្តងៗរាប់ពាន់ក្បាល មានសំលេងលឺស្ទើរកក្រើកដី។ ចាស់ៗនៅក្នុងបឹងនេះបានបន្តទៀតថា កាលពីជំនាន់សង្គ្រាម ព្រៃលិចទឹកត្រូវបានឆេះអស់ខ្លះៗតែវាមិនច្រើនណាស់ណាទេ ចំណែកធនធានធម្មជាតិនៅសំបូរសប្បាយដូចពីមុនដដែល ព្រោះមិនទាន់មានអ្នកណាហ៊ានចូលទៅលុកលុយទេតែនៅជំនាន់នោះសត្វដំរីបានបាត់អស់ ហើយដោយសារតែវាភ័យខ្លាចដូចជា ការទំលាក់គ្រាប់

បែក ភ្លើងឆេះព្រៃដែលមិនអាចអោយពួកសត្វប្រភេទនោះរស់នៅបានងាយស្រួលបានឡើយ ដូច្នេះពួកវាត្រូវរត់ទៅនៅតំបន់ឆ្ងាយៗក្បែរជិតព្រំដែន។ រហូតមកដល់បច្ចុប្បន្ននេះ ថ្វីត្បិតតែមិនមានការទំលាក់គ្រាប់បែកមែនតែតំរូវការរបស់មនុស្សច្រើនពេកបានធ្វើអោយព្រៃលិចទឹកស្ទើរទាំងអស់ត្រូវប្រជាពលរដ្ឋដុះព្រៃ និងកាប់ឆ្ការក្លាយទៅជាវាលស្រែប្រាំង វាលដាំឈូក។ ពពួកសត្វព្រៃ សត្វស្លាបត្រូវប្រជាពលរដ្ឋយើងប្រើថ្នាំបំពុលការបរបាញ់ដោយប្រើកាំភ្លើង ការដាក់អន្ទាក់ដើម្បីចាប់សត្វយកមកធ្វើជាចំណីនិងលក់ដូរដែលធ្វើអោយពួកវាត្រូវបាត់បង់អស់យ៉ាងច្រើន ម្យ៉ាងទៀតដោយសារការភ័យខ្លាច និងគ្មានទីជំរកទើបពពួកសត្វទាំងនោះរត់ទៅរស់នៅតំបន់ផ្សេង។ ឥឡូវនេះតំបន់នៅសល់តែប្រភេទសត្វស្លាបមួយចំនួនដូចជា កុក ក្រសា មាន់ទឹក ហើយមានចំនួនតិចតួចតែប៉ុណ្ណោះ។ ព្រៃលិចទឹកក៏អស់ត្រីបាត់បង់ជំរក ថែមទាំងប្រជាពលរដ្ឋបានប្រើប្រាស់ឧបករណ៍ខុសច្បាប់ដើម្បីនេសាទ ដែលបណ្តាលអោយធនធានមច្ឆាជាតិយើងស្ទើរតែផុតពូជអស់ទៅហើយ។ គាត់បានសង្កេតឃើញបច្ចុប្បន្ននេះ អ្នកល្មើសច្បាប់តែងតែប្រើឧបករណ៍នេសាទដូចជាឆក់ ស្បៃមុង អួនក្រឡាញឹក ធ្វើអោយត្រីធំៗបានផុតពូជទៅហើយ ឃើញមានតែត្រីតូចៗដូចជាត្រីរ៉ស អណ្តែង កញ្ចុះ ស្លាត កំភ្លាញក្រាញ់ ដែលមានទំហំតូចៗបំផុត។ ដូចនេះគាត់បានសំនូមពរដល់រាជរដ្ឋាភិបាលជួយគិតគូរ និងការពារឡើងវិញនូវធនធានរបស់យើង បើមិនដូច្នេះទេវានឹងត្រូវបាត់បង់អស់នៅថ្ងៃណាមួយជាក់ជាមិនខាន។

# ប្រវត្តិបឹងពាក់ថែប

បឹងពាក់ថែប គឺជាបឹងមួយស្ថិតនៅក្នុងដែននេសាទរបស់សហគមន៍នេសាទស្ពានគ្រង ឃុំចំណារក្រោម ស្រុកស្ទោង ខេត្តកំពង់ធំ ។ បឹងនេះស្ថិតនៅប៉ែកខាងលិចនៃភូមិស្ពានគ្រង និងផ្លូវជាតិលេខ៦ ដែលមានព្រំប្រទល់ខាងលិចជាប់នឹងប្រឡាយប្រកពីង ខាងកើតជាប់នឹងដៃពាក់ព្រាត់ ខាងជើងជាប់នឹងព្រាំងចាក់ថ្លុក ខាងត្បូងជាប់បឹងគោលុង។ បើយើងធ្វើដំណើរនៅរដូវប្រាំងគេអាចជិះម៉ូតូ កង់ ឬតាមផ្លូវរទេះគោ ក្របី ចេញតាមក្លោងទ្វារវត្តចំណាក់ ឬប៉ុស្តិ៍នគបាលឃុំចំណារក្រោមតែម្តងក៏បាន ដែលគិតចំងាយប្រហែល២៤គីឡូម៉ែត្រ ពីភូមិស្ពានគ្រង និងផ្លូវជាតិលេខ៦ នៅតាមផ្លូវធ្វើដំណើរដោយមានការឆ្លងកាត់វាលស្រែ ព្រៃលិចទឹក វាលស្រងែ ពិសេសបឹងតូច ធំ ជាច្រើនទៀតទើបទៅដល់ *បឹងពាក់ថែប* ។

តាមការសំភាសន៍លោក **ទំ ហាំ** អាយុ ៤៩ ឆ្នាំប្រពន្ធឈ្មោះ **សុំ ចាន់ថន** មានកូន៣នាក់ ប្រុស ៣នាក់ ស្រី១នាក់រស់នៅភូមិចំណាក់ ឃុំចំណារក្រោម ស្រុកស្ទោង បានអោយដឹងថា ដោយសារបឹងនេះស្ថិតនៅចំងាយប្រមាណជា៣គីឡូម៉ែត្រពីបឹងទន្លេសាប។ កាលពីមុនមានលោកយាយ ចំណាស់ម្នាក់ឈ្មោះ **ណាម** ដែលជាជនជាតិវៀតណាម គាត់តែងតែចេញចូលទៅ



**លោកតា ទំ ហាំ**

រករបរនេសាទនៅបឹងទន្លេសាប ហើយជួនកាលគាត់ចេញទៅនេសាទនៅក្នុងបឹងនេះ ហើយគាត់បានធ្វើជាភ្លូលសំរាប់ស្នាក់នៅក្បែរដើមតាសែងមួយយ៉ាងធំ នៅពេលដែលប្រជានេសាទចេញចូលទៅរករបរនេសាទនៅតំបន់នោះ គេតែងតែក្រឡេកឃើញភ្លូលនោះដែលហៅថា ថែបនៅក្បែរបឹង ហើយក៏ចេះតែហៅថា *បឹងពាក់ថែប*តាំងពីពេលនោះតទៅរហូតដល់សព្វថ្ងៃនេះ។ កាលពីដើម នៅរដូវវស្សា បឹងនេះមានទំហំយ៉ាងធំដែលមានបណ្តោយប្រហែលជិត ២.៣០គីឡូម៉ែត្រ ទទឹងប្រហែល១៣០ម៉ែត្រ និងមានជំរៅប្រហែល៧ទៅ៨ម៉ែត្រ ចំណែកនៅរដូវប្រាំងបឹងនេះមានបណ្តោយប្រហែល ១.៥ទៅ២គីឡូម៉ែត្រ និងទទឹងប្រហែល ៧០ទៅ៨០ម៉ែត្រ និងមានជំរៅចាប់ពី ០.៨ទៅ១ម៉ែត្រ ។

គាត់បានអោយដឹងថា កាលពីដើមឡើយបឹងពាក់ថែបនេះនៅជុំវិញបឹង និងតាមផ្លូវមានព្រៃលិចទឹកយ៉ាងក្រាស់ក្រែល ដែលធ្វើអោយអ្នកនេសាទកាលពីមុនមកធ្វើនេសាទម្តងត្រូវចំណាយពេលពី២ទៅ៣យប់ ទើបអាចទៅដល់បឹងនោះ។ បឹងនេះសំបូរទៅដោយត្រីច្រើនប្រភេទដូចជា ត្រីគល់រាំង ត្រីឆ្តោរ ត្រីសណ្តាយ ត្រីគ្រុំ ត្រីក្អែក ត្រីពោធិ៍ ត្រីរាជ និងប្រភេទត្រីគ្មានស្រកាជាច្រើនទៀត។ ចំពោះសត្វស្លាបសំបូរទៅដោយសត្វក្អែកទឹក ស្មោញ កុក មាន់ទឹក ប្រវិក ក្រសា លលក ត្រដេវ វិច ខ្លែងស្រាក់ ជាដើម។ សត្វព្រៃសំបូរទៅដោយសត្វដំរី សត្វស្វា ខ្លាតូច ខ្លាធំ ប្រើស រមាំង ចចក ឈ្លូស ជ្រូកព្រៃ ឯពពួកល្មូនក៏សំបូរដែលដូចជាពស់គ្រប់ប្រភេទ អណ្តើក និងកន្ធាយ។ ដោយសារបឹងនេះសំបូរទៅដោយត្រីគ្រប់ប្រភេទ

ទើបធ្វើអោយប្រជានេសាទជាច្រើនចូលចិត្តមកនេសាទនៅបឹងនេះណាស់ ហើយភាគច្រើនមកពីឃុំចំណាររក្រោម ឃុំចំណារលើ ស្ទោង ដីរីស្លាប់ និងអ្នកដែលនៅជាប់ព្រំប្រទល់គ្នាជាច្រើនទៀត ហើយពេលពួកគេមកនេសាទម្តងៗតែងតែធ្វើជាខ្ទមតូចៗនៅមាត់បឹងសំរាប់ស្នាក់នៅជាបណ្តោះអាសន្នរយះពេលខ្លីពី១ខែទៅ២ខែ។ ចំពោះឧបករណ៍ដែលពួកគេប្រើប្រាស់នៅសម័យមុននោះមានលប អង្រុត មង អួន សន្ទូច ឈ្នាងដែលសុទ្ធតែជាឧបករណ៍បុរាណ ។

បច្ចុប្បន្ន តំបន់ពាក់ថែបក៏ដូចជាបឹងពាក់ថែបត្រូវបានទទួលរងនូវការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរពីជនល្មើសមួយចំនួនដែលប្រើប្រាស់ឧបករណ៍ខុសច្បាប់ដូចជា ឆក់ដាក់ថ្នាំបំពុល បូមបាចជាពិសេសការកាប់បំផ្លាញព្រៃលិចទឹកដែលជាជំរក និងជាកន្លែងពងកូនរបស់ពពួកមច្ឆាជាតិ និងពពួកសត្វស្លាប ដូច្នេះធនធាននៅក្នុងបឹងពាក់ថែបត្រូវបានថយចុះយ៉ាងខ្លាំង ។ សព្វថ្ងៃនេះ គេតែងតែប្រទះឃើញមានអ្នកដែលមកនេសាទនៅបឹងនេះច្រើនមកពីឃុំចំណាររក្រោម ឃុំចំណារលើ ឃុំបន្ទាយស្ទោង ឃុំព្រះដីរី ឃុំរុងរឿងដែលសរុបអ្នកដែលមកធ្វើនេសាទ ធ្វើស្រែប្រាំងប្រហែល៧៥ទៅ៨០គ្រួសារ ចំណែកការប្រើប្រាស់ឧបករណ៍នេសាទរបស់គេមានការដាក់សំរាស់ ឆក់អួនអូស លប សន្ទូច ឡី ដែលជាហេតុធ្វើអោយធនធានជលផលក្នុងបឹងពាក់ថែបក៏ដូចជាបឹងដ៏ទៃៗទៀតត្រូវទទួលរងការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរ ពីសំណាក់ជនខិលខូចមួយចំនួនតូច។ សព្វថ្ងៃនេះគេឃើញមានតែប្រភេទត្រីរ៉ស់ ត្រីអណ្តែង ត្រីក្រាញ់ ត្រីកំភ្លាញ ចំណែកត្រីឆ្តោរកំរប្រទះឃើញមានណាស់នៅក្នុងបឹង។ ចំណែកសត្វស្លាបគាត់

ធ្លាប់ឃើញនៅសល់ប្រភេទសត្វកុក មាន់ទឹក កំពីងដូង ចំណែកសត្វដំរីត្រូវបាត់អស់តាំងពីសម័យសង្គ្រាមមកម្ល៉េះ។ ដោយសារធនធានធម្មជាតិត្រូវទទួលរងការបំផ្លិចបំផ្លាញជាពិសេសធនធានត្រី គាត់បានសំនូមពរអោយគ្រប់ស្ថាប័នពាក់ពន្ធ័ទាំងអស់មេត្តាជួយលុបបំបាត់នូវការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ ហើយជួយថែរក្សាព្រៃលិចទឹកក្នុងតំបន់បឹងពាក់ថែបក៏ដូចជាតំបន់នានាផងដែរ និងសូមអោយបឹងពាក់ថែបនេះជាបឹងអភិរក្សរបស់សហគមន៍ស្ពានគ្រង និងសូមជួយដោះស្រាយបញ្ហាទាហ៊ាននៅភ្នំជីមុសដែលតែងតែមកគ្រប់គ្រងបឹងពាក់ថែបសព្វថ្ងៃនេះ ។

# ប្រវត្តិបឹងអន្ទង់

បឹងអន្ទង់ជាបឹងមួយស្ថិតនៅក្នុងភូមិរលួស ឃុំស្រយ៉ូវ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ។ បើយើងធ្វើដំណើរពីកំពង់ធំទៅបឹងអន្ទង់មានចំងាយប្រហែលពី២០ ទៅ១៥ គីឡូម៉ែត្រ តែគិតពីបឹងអន្ទង់ទៅបឹងទន្លេសាបពី ២០ទៅ២៥គីឡូម៉ែត្រ។ បឹងអន្ទង់នេះមានប្រវែងប្រហែល៥០០ ម៉ែត្រ និងទទឹង១០០ ទៅ១៥០ម៉ែត្រ នៅរដូវប្រាំងមានជំរៅពី១ម៉ែត្រទៅ១ម៉ែត្រកន្លះ។ បឹងអន្ទង់ស្ថិតនៅផ្នែកវាលក្រោមនៃឃុំស្រយ៉ូវ ជាទូទៅតំបន់វាលធ្វើស្រូវឡើងទឹកនៅរដូវវស្សា តែងទទួលរងរបបទឹកទន្លេសាបមកស្រោចស្រពលើវាលល្ហល្ហេវគ្រប់ទិសទី។ កត្តាទាំងអស់នេះហើយ ទើបមានត្រីជាច្រើនប្រភេទចេញពីទន្លេសាបមករកចំណីប្លែកៗពងកូនបន្តពូជនៅតំបន់នេះ ។ លុះដល់ទឹកទន្លេសាបស្រកផុតទៅវិញ តំបន់វាលនេះសំបូរដោយថ្លុកត្រពាំង បឹងបួររាប់មិនអស់ ប្រកបដោយទឹកពាសពេញ និងសំបូរដោយរុក្ខជាតិនានា និងត្រីសំបូរបែបស្ទើរគ្រប់មុខ។ កាលពីសម័យមុន ចំពោះឈ្មោះបឹងនិមួយៗ ចាស់បុរាណតែងតែហៅឈ្មោះតាមព្រឹត្តការណ៍ជាក់ស្តែងដែលកើតឡើងនៅទីនោះ ។



**លោកតា ប៊ូ ប៊ិន**

តាមការសំភាសន៍លោកតា **ប៊ូ ប៊ិន** មានអាយុ៨០ឆ្នាំ មានប្រពន្ធឈ្មោះ **ស្វាយ អ៊ុត** អាយុ ៧៣ឆ្នាំ និងមានកូន ៥នាក់ ដែលមានប្រុស៣នាក់ និងស្រី ២

នាក់។ គ្រួសាររបស់គាត់គឺជាគ្រួសារកសិករ និងអ្នកនេសាទដែលមានភូមិកំណើត នៅភូមិរលួស ឃុំស្រយ៉ូវ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ គាត់រស់នៅទីនេះរហូត ដល់បច្ចុប្បន្ននេះ។ គាត់ជាអ្នកនេសាទ និងធ្វើស្រែតាំងពីក្មេងរហូតមកដល់អាយុ ៦០ ឆ្នាំ និងមានដី១០ហិតាសំរាប់ធ្វើស្រែ។ គាត់បានប្រាប់ពីបឹងនេះថា: បឹងអន្ទង់ពីដើម ស្ថិតនៅក្នុងភូមិរលួស ឃុំស្រយ៉ូវ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ កាលពីដើមនោះ មានលោកតាម្នាក់ ឈ្មោះ **ឡាយ ស៊ន** រស់នៅក្នុងភូមិនោះ លោកជាចាស់ទុំមួយរូប ដែលជាអ្នកនេសាទនៅក្នុងភូមិនេះ ថ្ងៃមួយគាត់បានបបួលគ្នាទៅរកត្រីនៅបឹងនោះ គាត់ក៏យកលបទៅដាក់ក្នុងបឹងនោះលុះព្រឹក ឡើងទៅលើកលបក៏ឃើញមានអន្ទង់ ចូលពេញលប។ ដោយអន្ទង់ច្រើនពេកគាត់ខ្លាចអន្ទង់រួចអស់មិនដឹងធ្វើយ៉ាងដូចម្តេច គាត់ក៏បានលីទាំងលប មកកន្លែងស្នាក់នៅដែលនៅជាប់មាត់បឹងនោះ លុះពេលនោះ ស្រាប់ តែប្រជាពលរដ្ឋនៅទីនោះភ្ញាក់ផ្អើល ឆោឡោឡើងនាំគ្នាមកមើល ហើយក៏បាន នាំគ្នាដាក់ឈ្មោះថា "បឹងអន្ទង់" រហូតមកដល់សព្វថ្ងៃនេះ ។

គាត់បានមានប្រសាសន៍ថា: បឹងអន្ទង់ជាបឹងមួយដែលមានលក្ខណៈខុសប្លែក ពីបឹងដទៃដោយវាសំបូរទៅដោយព្រៃរនាមក្រាស់ និងដើមឈើធំៗដូចជា ដើមរាំង ដើមតាអួរ ដើមអញ្ចាញ ដើមភ្នំភ្លែន ដើមត្រស់។ល។ នៅក្នុងតួរបឹងសំបូរទៅដោយ បឿន និងដើមកក់ខ្ពស់ៗនៅព័ទ្ធជុំវិញមាត់បឹង និងមានភក់ជ្រៅៗ។ កាលគាត់មាន អាយុ១៦ឆ្នាំ គាត់ឃើញនៅតំបន់នេះសំបូរទៅដោយព្រៃរនាម និងត្រែងខ្ពស់ៗ ហើយ នៅរដូវប្រាំងគាត់ឃើញមានសត្វព្រៃដូចជា ឆ្កែចចក ខ្លា ទន្សោង ប្រើស ជ្រូកព្រៃ

ជាពិសេសហ្វូងដំរីមកនៅទីវាលនោះ។ គាត់បានប្រាប់ការពីរឿងពិតដែលគាត់ជួបប្រទះ ថ្ងៃមួយគាត់ទៅនេសាទត្រីជាមួយគ្នាគាត់ចំនួន៥ នាក់ ពេលកំពុងធ្វើដំណើរពួកគាត់បាននិយាយគ្នាថា ពួកយើងមើលផ្លូវអោយច្បាស់លាស់ប្រយ័ត្នមានជួបហ្វូងសត្វដំរី។ ស្រាប់តែមួយរំពិចនោះក៏មានដំរីមួយលេចចេញពីព្រៃមកដេញពួកគាត់ ហើយពួកគាត់ទាំងអស់គ្នាភ័យណាស់ក៏នាំគ្នារត់ឡើងដើមឈើធំៗដែលនៅជិតនោះរៀងខ្លួនៗ។ ចំណែកគាត់វិញមានវ័យក្មេងជាងគេហើយកំពុងស្ពាយឆ្នាំងបាយជាប់និងខ្នង គាត់ក្រលេកឃើញដំរីគាត់ភ័យពេកមិនដឹងធ្វើយ៉ាងម៉េច ក៏រត់ឡើងដើមធំដែលកំពុតចុងមានកំពស់តែ៣ម៉ែត្រប៉ុណ្ណោះ ចៃដន្យពេលនោះគាត់ធ្លាក់ឆ្នាំងបាយមកក្រោមលឺសូរផាំងយ៉ាងខ្លាំងធ្វើឱ្យដំរីភ័យរត់បាត់ទៅ ។

គាត់បានអោយដឹងទៀតថា បឹងនេះសំបូរធនធានមច្ឆាជាតិ និងអំណោយផលដល់អ្នកនេសាទនៅភូមិនេះ គេទៅនេសាទម្តងៗមានរយះពេលពី១ខែ ទៅ២ខែទើបត្រឡប់ទៅផ្ទះវិញ។ ចំណែកបឹងអន្លង់ជាបឹងមួយដែលប្រជាពលរដ្ឋមួយចំនួនតែងមកស្នាក់នៅដើម្បីនេសាទ ហើយអ្នកដែលមកនេសាទនោះច្រើនតែមកពីឃុំស្រយ៉ូវកំពង់រទេះ អូរគន្ធរ មួយចំនួនទៀតមកពីស្រុកសន្ទុក និងស្រុកសណ្តាន់។ នៅបឹងនេះសំបូរទៅដោយសត្វស្លាប សត្វល្មូន និងមច្ឆាជាតិគ្រប់ប្រភេទដូចជា ត្រីឆ្តោរ ត្រីរ៉ស់ ត្រីកញ្ជានជ័យ ត្រីគន្ធរ ត្រីក្រាញ់ ត្រីស្លាត ពស់គ្រប់ប្រភេទ អន្ទង់ អណ្តើក កន្ធាយ។ល។ ការនេសាទត្រីនៅសម័យនោះគេច្រើនប្រើអង្រុត លប បប៉ក បង្កៃ ស្ទូ ពាក់មងធ្វើពីធ្មៃដែលមានក្រឡាពី១ ទៅ១តឹកកន្លះ ត្រីនៅសម័យនោះធំៗណាស់

មានទំងន់ចាប់ពី៤ទៅ៥គីឡូក្រាមឡើង ត្រីដែលចាប់បាននោះប្រជាពលរដ្ឋតែងធ្វើជាប្រហុក ផ្អក ត្រីងៀត ដើម្បីដូរជាស្រូវ និងចែកញាតិជិតខាងត្រៀមទុកសំរាប់បរិភោគនៅពេលបុណ្យចូលឆ្នាំ ។

ដល់ឆ្នាំ១៩៨២ ដល់ឆ្នាំ១៩៩៥ តំបន់នេះមិនសូវសំបូរធនធានដូចពីមុនទេដីព្រៃលិចទឹកមួយចំនួនត្រូវបានប្រជាជនកាប់ដើម្បីធ្វើស្រែឡើងទឹកអស់មួយចំនួនហើយចំណែកធនធាននៅក្នុងបឹងដូចជា ត្រីរ៉ស់ ត្រីឆ្តោរ ត្រីកញ្ជនជ័យ ត្រីកន្ធរ ត្រីក្រាញ់ ត្រីស្លាតមិនសូវសំបូរដូចពីមុននោះទេហើយក៏មិនធំៗដូចមុនដែរ កាលពីមុនគាត់អាចចាប់ត្រីមានទំងន់ពី១-៣ គីឡូក្រាមប៉ុណ្ណោះ។ ឥឡូវសត្វពស់ អន្ទង់ អណ្តើក កន្ធាយក៏មិនសូវឃើញមានដូចពីមុនដែរ។ ដោយសារតែសង្គ្រាម និងការដុតព្រៃធ្វើអោយសត្វព្រៃ និងសត្វស្លាបនៅមានតិចតួចណាស់ដូចជា ប្រវឹក មានទឹក កុក ក្រសាស្មោញ ត្រយង ជាដើម ។

លុះមកដល់បច្ចុប្បន្ននេះធនធានធម្មជាតិ និងធនធានមច្ឆាជាតិយើងបានថយចុះស្ទើរតែបាត់បង់អស់ ហើយព្រៃលិចទឹកនៅតំបន់នោះបានបាត់បង់អស់ទៅហើយនឹងក្លាយទៅជាវាលឡើងទឹក និងស្រែប្រាំង ។ មច្ឆាជាតិត្រូវបានបាត់បង់ស្ទើរតែទាំងស្រុង ដោយសារការប្រើប្រាស់ឧបករណ៍ទំនើបៗដូចជា ឆក អួនក្រឡាញឹក ការបូមពង្រីង និងកត្តាធម្មជាតិ។ ចំនែកសត្វស្លាបត្រូវបាត់បង់អស់ហើយដោយសារការប្រើឧបករណ៍ចាប់ទំទើបដូចជា បំពង់សំលេង ការបំពុលដោយថ្នាំពុល និងការចាប់ហួសកំរិត។ ជាពិសេសការកាប់ព្រៃជុំវិញបឹងជិតអស់ធ្វើឱ្យផ្ទៃបឹងត្រូវរាក់ជា

បណ្តើរៗ ដោយសារការហូរច្រោះដីចូលក្នុងបឹង និងបូមទឹកធ្វើប្រាំង ។

ដោយសារការបាត់បង់ហ្លួសក៏រិតនេះមានទំហំធំធេងពេក ដូច្នេះហើយទើបសហគមន៍នៅភូមិរលួសបានបង្កើតជាសហគមន៍នេសាទដើម្បីអភិរក្សធនធានបឹងនេះឡើងវិញដោយមានការឧបត្ថម្ភគាំទ្រពីអង្គការ CODEC និងអង្គការ GTZ និងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរដែនដី និងសមត្ថកិច្ច។ ដូចនេះសុំសំនូមពរអោយអង្គការ និងរដ្ឋាភិបាលជួយជំរុញនូវការលប់បំបាត់ឧបករណ៍ខុសច្បាប់ និងសុំជួយថែរក្សាការពារឡើងវិញ ដើម្បីទុកអោយក្មេងជំនាន់ក្រោយស្គាល់ឃើញ និងដឹងលឺជាពិសេសគួរតែកុំធ្វើស្រែប្រាំងនៅក្នុងបឹង ។

# ប្រវត្តិបឹងប្រវែង

បើយើងធ្វើដំណើរពីទីរួមខេត្តកំពង់ធំទៅទិសខាង លិចតាមបណ្តោយដងស្ទឹងសែនចំងាយប្រហែលជា១៥ ទៅ១៦គីឡូម៉ែត្រដោយឆ្លងកាត់ភូមិកំពង់រទេះ យើងនឹងទៅដល់បឹងមួយឈ្មោះថា បឹងប្រវែងដែលស្ថិតនៅក្នុងភូមិអូគន្ធរ ឃុំកំពង់រទេះ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ។ បឹងប្រវែងនេះជាបឹងមួយធំវែងរាងកំប៉ោងធំកណ្តាលតូចសងខាង បណ្តោយប្រវែងប្រហែល២០០ម៉ែត្រ ចុងសងខាងប្រហែល១០០ម៉ែត្រ មានដៃតជាប់មកពីបឹងកណ្តឹង ខ្វែងកោះគោ និងបឹងកំភ្លុក។

តាមការកិច្ចសំភាសន៍លោកតា **លាង ជួន** អាយុ ៥៧ឆ្នាំ នៅភូមិកំពង់រទេះ ឃុំកំពង់រទេះ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ មានមុខរបរជាអ្នកធ្វើស្រែ និងជាអ្នកនេសាទម្នាក់។ គាត់តែងទៅឃ្វាលគោ ក្របីនៅបឹងប្រវែងតាំងពីវ័យក្មេងតពូជពីជីដូនជីតារហូតមកដល់បច្ចុប្បន្ននេះបានអោយដឹងថា បឹងប្រវែងបានទទួលប្រភពទឹកពីទន្លេសាបតាមដៃ និងព្រែករបស់បឹងនៅ រដូវវស្សាធ្វើអោយបឹងនេះមានទំហំធំល្វឹងល្វើយមើលដាច់កន្ទុយភ្នែកដែលមានជំរៅទឹកប្រហែល៧ ទៅ៨ហាត់ (ជាង៣ម៉ែត្រ)។ នៅខែប្រាំង មានជំរៅប្រហែលជា២ម៉ែត្រ ។ នៅជុំវិញបឹងមានព្រៃដ៏ក្រាស់ ហើយស្តុកដូចជា ដើមត្រស់ ភ្នំភ្លេង ប្របួយ រាំង ខ្ទុំ សណ្តាន់ ផ្ទោល ដែលជាជំរកដ៏សំខាន់សំរាប់ត្រី និងពពួកសត្វស្លាប សត្វល្មូនគ្រប់ប្រភេទ។ ក្រៅពីនោះមានពើកបឿនស្បូវត្រាវ កំប៉ោង ស្មៅ ចំរុះយ៉ាងក្រាស់ដុះជុំវិញមាត់បឹងដែលបង្កលក្ខណៈងាយស្រួលសំរាប់ត្រីពងកូន និងសត្វបក្សី។ នៅក្បែរបឹងនេះយើងឃើញមានរោងអ្នកតា២ ប៉ែក

ខាងលិចមានមួយខ្នងមានបួនបន្ទប់សំរាប់រូបអ្នកតាធំៗបួន សង់អំពីឈើប្រក់ក្បឿងខ្ពស់ពីដីប្រហែល ៤ម៉ែត្រ កុំអោយលិចទឹកនៅរដូវវស្សា និងនៅទិសខាងកើតមានរោងមួយខ្នងសង់អំពីឈើប្រក់ក្បឿងខ្ពស់ដូចគ្នាតែគ្មានរបាំងបន្ទប់ទេ រោងអ្នកតាទាំងពីរនេះគឺជាសក្ការៈសំរាប់ធ្វើបុណ្យ និងគោរពបូជារបស់អ្នកស្រុក ជាពិសេសសំរាប់ប្រជា-នេសាទនៅពេលពួកគេចុះនេសាទម្តងៗ ដើម្បីផ្សងសុំសេចក្តីសុខ និងទទួលបានផលច្រើន។ ដោយតំបន់នេះទទួលរងរបបទឹកទន្លេសាបជារៀងរាល់ឆ្នាំបានបង្កលក្ខណៈងាយស្រួលដល់ការរស់នៅរបស់វារីជីវសាស្ត្រ និងផ្តល់ទីជំរកយ៉ាងសំខាន់ដល់ថនិកសត្វដូចជាសត្វសំពោច អណ្តើក កន្ធាយ ពស់វែក ពស់ថ្លាន់ កុក ក្រសារ មាន់ទឹកទោម ថ្លិយ៉ាងច្រើននៅក្នុងទឹកកណ្តាលបឹងមានទុង ក្អែកទឹក ស្មោញ ប្រវឹក ភេហោះហែលច្រវ៉ាត់ច្រវ៉ែងរកចាប់ត្រីស៊ី។ តំបន់បឹងនេះសំបូរទៅដោយដើមឈើធំៗដែលជាជំរកសត្វស្លាបដូចនៅលើដើមផ្អៅលខ្ពស់ៗមានអុកធ្វើសំបុកពង និងកូនរាល់ឆ្នាំ ហើយនៅក្រោមដើមឈើនេះ ក៏មានចាស់ៗខ្លះមកចាំរើសយកត្រីសល់ពីចំណីកូនអក ឬត្រីរ៉ស់ធំៗរើរួចពីក្រញ៉ាំអកធ្លាក់មកដីយកទៅធ្វើម្ហូបអាហារដែរ។ មិនតែប៉ុណ្ណោះតំបន់នេះសំបូរទៅដោយហ្វូងដំរី ស្វា ជ្រូកព្រៃ ឈ្លូស រមាំង ខ្លា យ៉ាងច្រើននៅរដូវប្រាំង។ រីឯរដូវវស្សាវិញគេច្រើនឃើញហ្វូងសត្វទាំងអស់នេះ នៅពេលវាឡើងពីបឹងទន្លេសាបវិញ។ នៅរដូវប្រាំងពេលទឹកសំរក បឹងប្រវែងជាកន្លែងជំរកត្រីចំរុះយ៉ាងសំបូរបែប ជាពិសេសគឺត្រីរ៉ស់ ត្រីអណ្តែង ត្រីក្រាញ់ ត្រីគល់រាំង ត្រីសណ្តាយធំៗ។ គាត់បានអោយដឹងទៀតថា ការនេសាទត្រីជាមុខរបរពេញនិយមរបស់ប្រជាពលរដ្ឋមួយ

ចំនួនដែលទាញយកផលពីធម្មជាតិសុទ្ធសាធបានរាប់ពាន់តោន ដោយគ្រាន់តែចំណាយដើមទុន និងកំលាំងពលកម្មបន្តិចបន្តួចប៉ុណ្ណោះ ដូច្នេះអោយតែដល់រដូវប្រាំងតំបន់នេះក្លាយទៅជាកន្លែងប្រមូលផ្តុំប្រជាពលរដ្ឋមកពីភូមិជិតឆ្ងាយមានស្រុកបារាយណ៍ កំពង់ស្វាយ សន្ទុកជាដើម មានទាំងប្រពន្ធកូនបររទេះមករកនេសាទត្រីនៅទីនេះដើម្បីធ្វើប្រហុក ផ្អក ងៀត ឆ្អើរ កន្ត្រាំ សំរាប់ទុកហូបប្រចាំឆ្នាំ។ ការប្រកបមុខរបររកត្រីនៅពេលនោះគឺគេរាំងព្រួល កាត់កប៊ឹងដាក់លប ហ៊ុំសំរាស់ ចាក់សម ចាក់ស្ទូគ្រប់ឆ្នុក រុតគន ប្របក់ ដាក់ជុច អូសមង ដាក់ប៉ោង អន្ទង់។ តាមការពិនិត្យឃើញរបស់គាត់ ក្រោយឆ្នាំ១៩៧០ ដល់ឆ្នាំ ២០០៥នេះធនធានធម្មជាតិដូចជាទឹកដី ព្រៃ មច្ឆាជាតិសត្វព្រៃ បក្សីបក្សាដែលធ្លាប់មាននៅបឹងប្រវែងកាលមុនឆ្នាំ១៩៧០ ដែលជាអំណោយផលយ៉ាងល្អជួយលើកកំពស់ជីវភាពរស់នៅប្រជាពលរដ្ឋ ឥឡូវនេះត្រូវបានវិនាសអន្តរាយស្ទើរតែសាបសូន្យអស់ហើយ ដូចជាព្រៃដែលធ្លាប់មានក្រាស់ត្រូវក្លាយទៅជាដីស្រែ ដើមឈើធំៗ រាំង ខ្ទុំ តាអូរ កាប់ហូរហែពីឆ្នាំ១៩៧១ មកដោយសារប្រជាពលរដ្ឋ និងពួកទាហានចូលលុកលុយ ហើយសត្វស្លាប មច្ឆាជាតិពីមុនច្រើនកុះករឥឡូវនៅតិចតួចបំផុតស្ទើរតែគ្មានផង ចំណែកសត្វព្រៃវិញដូចជា ដំរី ខ្លា ប្រើស រមាំង ជ្រូកព្រៃបាត់ស្រមោលអស់មិនឃើញមានមួយទេក្នុងឆ្នាំ១៩៧០នៅតំបន់នេះ។ ត្រីត្រូវចាប់បាត់បង់ពីឆ្នាំ១៩៩៩-២០០១ ទឹករីងខះបាតបឹងប្រេះក្រហែង។ ក្នុងឆ្នាំ ២០០៣-២០០៤មកបណ្តាលមកពីបូមទឹកដាក់ស្រែប្រាំង ធ្វើអោយបឹងរាក់ចាប់ត្រីផង ហើយបាតបឹងប្រេះក្រហែង។ ជាក់ស្តែងក្នុងថ្ងៃ២២-២៤-ខែមករា២០០៥ មុននេះ

ម្ចាស់ម៉ាស៊ីនបូមទឹកបានចាប់ត្រីចំរុះប្រហែល ៧-៨រឺម៉កគោយន្តមកលក់។ ចំណែក



ស្ថានភាពថ្ងៃបាតបឹងប្រវែង នាពេលបច្ចុប្បន្ន

អ្នកក្រីក្រគ្មានលទ្ធភាព មិនអាចចូលចាប់បានឡើង ជាមូលហេតុធ្វើអោយប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជីវិតរស់នៅរបស់ប្រជាពលរដ្ឋក្រីក្ររកត្រីហូបក៏ពុំបានរកទឹកអោយគោក្របីផឹកក៏គ្មាន ។

គាត់បានមានប្រសាសន៍ទៀតថាតំបន់បឹងមិនត្រឹមតែជាជំរកសត្វព្រៃ សត្វស្លាបនោះទេវាក៏ជាតំបន់ដែលសត្វស្រុកស្នាក់នៅបណ្ដោះអាសន្នពេលអ្នកនេសាទមករកត្រី និងទឹកបឹងមិនត្រឹមតែសំរាប់សត្វព្រៃនោះទេវាក៏ជាដំណាក់ទឹកសំរាប់គោ ក្របី អ្នកស្រុកផឹកដែរ។ នៅពេលដែលបាត់បង់ធ្វើអោយអ្នកក្រីក្រកើនឡើងជារៀងរហូត ដោយសារការបាត់បង់បរិស្ថាន អត់ទឹក អត់បាយ អត់ត្រី អត់ចំណីអាហារ អត់ការងារធ្វើ។

ដូចនេះក្នុងនាមគាត់ជាប្រជានេសាទមួយរូបសុំអោយរាជរដ្ឋាភិបាលជួយស្តារបឹងរាក់ៗអោយបានជ្រៅវិញ និងទប់ស្កាត់បទល្មើស ឆក់ត្រី បូមយកត្រី បំពុលត្រី និងកាប់បំផ្លាញព្រៃនៅតំបន់វាលក្រោម។សូមប្រជាពលរដ្ឋជួយថែរក្សា និងការពារធនធានធម្មជាតិអោយសំបូរដូចពីមុន ព្រោះការបាត់បង់ធនធានទាំងនេះធ្វើអោយក្មេងៗជំនាន់ក្រោយលែងដឹង លែងស្គាល់ លែងលឺពីភាពសំបូរនូវធនធានធម្មជាតិរបស់ខ្មែរយើងទៀតហើយ ។

# ប្រវត្តិបឹងផ្សោត

បឹងផ្សោតជាបឹងមួយនៅក្នុងទឹកដីឃុំស្រយ៉ូវ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ។ បច្ចុប្បន្នបឹងនេះមានចំងាយពីខេត្តកំពង់ធំប្រហែលពី២០ ទៅ២៥គីឡូម៉ែត្រ បើគិតពីសាលាឃុំស្រយ៉ូវទៅដល់បឹងផ្សោតនោះមានចំងាយពី៦ ទៅ១០គីឡូម៉ែត្រ និងគិតពីបឹងផ្សោតទៅទន្លេសាបមានចំងាយប្រហែលពី១៥ទៅ២០គីឡូម៉ែត្រ។ ដោយបឹងផ្សោតនេះទទួលឥទ្ធិពលពីទឹកទន្លេសាបជារៀងរាល់ឆ្នាំ បឹងនេះនៅរដូវប្រាំងមានជំរៅប្រហែល ១ម៉ែត្រទៅ១.៨ម៉ែត្រ និងនៅរដូវវស្សាចំងាយប្រហែលពី២ ទៅ៤ម៉ែត្រ និងមានប្រវែងប្រហែលពី៧០០ទៅ១០០០ម៉ែត្រ និង ទទឹងបឹងពី១០០ ទៅ១៥០ម៉ែត្រ ។

តាមការសំភាសន៍លោកតា **ទា យី** ដែលមានអាយុ ៥៩ឆ្នាំ បានអោយដឹងថា គាត់ជាកសិករម្នាក់រស់នៅក្នុងភូមិកំរែង ឃុំស្រយ៉ូវ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ និងមានប្រពន្ធឈ្មោះ **នួន ស៊ុត** ហើយមានកូន៧នាក់ ស្រី៣នាក់ ប្រុស ៤នាក់។ គ្រួសាររបស់គាត់កាលពីដើមមានមុខរបរធ្វើស្រែផងនិងនេសាទត្រីសំរាប់ផ្គត់ផ្គង់គ្រួសារផង។ គាត់បានមានប្រសាសន៍ប្រាប់ពីព្រឹត្តការណ៍បឹងផ្សោតថា:



លោកតា ទា យី

កាលពីដើមឡើយនៅក្នុងភូមិកំរែង គាត់ជាអ្នកមានឥទ្ធិពលក្នុងភូមិ ហើយអ្នក

ភូមិតែងគោរព និងស្តាប់តាមគាត់ណាស់។ គាត់បានរាទព្រៃធ្វើស្រែចំការ និងតែងតែទៅឃ្វាលគោនៅជិតបឹងមួយឈ្មោះថា បឹងបវរទាដែលមានទួលបីនៅជុំវិញបឹងនោះ ហើយប្រជាពលរដ្ឋមួយចំនួននៅក្នុងភូមិ ក៏បានទៅរាទព្រៃធ្វើចំការនៅទីនោះជិតៗកន្លែងគាត់ដែរ ហើយគាត់បានដាំដើមត្នោត ដើមសំរោង ដើមអំពិលនៅជិតមាត់បឹងមុនគេ។ នៅថ្ងៃមួយនៅពេលដែលប្រជាពលរដ្ឋកំពុងតែធ្វើចំការនៅទីនោះ ស្រាប់តែគេឃើញមានសត្វចំលែកមួយផុសចេញពីទឹកឡើងធ្វើអោយប្រជាពលរដ្ឋមានភ្ញាក់ផ្អើលស្រែកឆោឡោឡើង ហើយក៏សួរថានេះជាសត្វអ្វី? នៅពេលនោះគាត់បានដឹងនិងស្គាល់ថា ជាសត្វផ្សោតក៏បានប្រាប់ទៅប្រជាពលរដ្ឋថានោះជាសត្វផ្សោត។ តាំងពីពេលនោះមកគេឃើញមានសត្វផ្សោតតែងតែផុសក្នុងបឹងនេះជាញឹកញ៉ាប់ ហើយប្រជាពលរដ្ឋក៏បានហៅបឹងនេះតៗគ្នាថាជា "បឹងផ្សោត "។ បឹងនេះបានប្តូរឈ្មោះពីបឹងបវរទាទៅជាបឹងផ្សោតចាប់ពីពេលនោះមក ហើយទួលដែលប្រជាពលរដ្ឋនាំគ្នាឆ្លូរឆរទៅមើល ហើយហៅថាទួលផ្សោត និងទួលពីរទៀតគឺទួលចេក និងទួលបវរទា។

តាមរយៈគាត់ និងចាស់ៗនៅក្នុងភូមិកំរ៉ែងបានអោយដឹងថាកាលពីដើមបឹងផ្សោតនៅរដូវប្រាំងមានជំរៅពី៤ ទៅ៥ម៉ែត្រ និងរដូវវស្សាពី៧ ទៅ៨ម៉ែត្រ។ កាលពីដើមធនធានធម្មជាតិ និងមច្ឆាជាតិ ជារៀងរាល់ឆ្នាំនៅរដូវសំរក ហ្វូងសត្វដូចជា ដំរី ឈ្លូស ខ្លា រមាំង និងប្រភេទសត្វដ៏ទៃទៀតតែងតែធ្វើដំណើរឆ្លងកាត់ទីនេះ ខ្លះមកជ្រកនៅទីនេះព្រោះនៅតំបន់នោះសំបូរទៅដោយព្រៃរនាមក្រាស់ក្រៃ និងដើមឈើធំៗជាច្រើនដែលជាជំរកពពួកសត្វទាំងនោះ។ ចំណែកនៅជុំវិញបឹងផ្សោតវិញសំបូរទៅដោយ

ព្រៃរនាមក្រាស់ព័ទ្ធជុំវិញមាត់បឹងដែលជាជំរករបស់សត្វស្លាបដូចជា សត្វកុក ទង់ ស្មោញ ត្រដក់ រនាល ត្រយង កុកស មាន់ទឹក ប្រវឹក ទោម ។ល។ មិនតែ ប៉ុណ្ណោះក្នុងបឹងសំបូរដោយត្រីគ្រប់ប្រភេទ និងសុទ្ធតែជាត្រីធំៗដូចជា ត្រីគល់រាំង ត្រីក្លាំងហាយ ត្រីសណ្តាយ ត្រីឆ្តោរ ត្រីដំរី ត្រីក្រាយ ត្រីអណ្តែង ត្រីក្រាញ់ ត្រីខ្ជឹង .និងមានត្រីជាច្រើនប្រភេទទៀតដែលយើងរាប់មិនអស់ប្រហែលពី៥០ ទៅ៧០ប្រភេទ ហើយនៅមានអណ្តើក កន្ធាយ ក្រពើ ពស់ ផ្សោត។ល។ ប្រជាពលរដ្ឋតែងតែនេ-សាទដោយប្រើឧបករណ៍បូរាណដូចជា សន្ទូច បង្កៃ បប៉ក ស្ទូរ អួនដែលមាន ក្រឡាចាប់ពី១ តឹក២ហ៊ុនដែលធ្វើពីខ្សែធ្មៃឡើងទៅពេលគេរកត្រីបានគេតែងតែចែកគ្នា ហូប រឺដូរជាអង្ករ និងសំភារះផ្សេងៗទៀត ។ ប្រជាពលរដ្ឋនៅសម័យនោះគេចូលចិត្ត យកត្រីធ្វើជាប្រហុក ផ្អក ត្រីងៀតសំរាប់ទុក ហើយប្រភេទត្រីដែលប្រជាពលរដ្ឋ តែងតែយកធ្វើជាប្រហុកមាន ត្រីរ៉ស់ ត្រីសណ្តាយ ត្រីគល់រាំង ដែលមានទំងន់ ចាប់ពីពាគីឡូក្រាមឡើង ចំណែកប្រភេទត្រីខ្នាន់ទំងន់ចាប់ពីពាគីឡូក្រាមឡើង គេកែច្នៃ ធ្វើជាផ្អក។ នៅកាលនោះគេសង្កេតឃើញ លក្ខណះពិសេសមួយដែលជាទំនៀម ទំលាប់របស់ចាស់ៗពីដើមគាត់តែង ផ្តាំកូនចៅមិនអោយចាប់ត្រីធំៗដែលមានទំងន់ពី ២០គីឡូក្រាម ឡើងទៅទេព្រោះត្រីធំៗទាំងនោះជាអ្នកនាំត្រីតូចៗ ហើយគចាត់ទុកត្រី ធំៗនោះថាជាមេបឹងដែលនាំងកូនចៅរបស់ខ្លួនឡើងមកហែលលេង និងរកចំនីនៅ ខាងលើផ្ទៃទឹក។

គាត់បានបន្តទៀតថា កំឡុងឆ្នាំ១៩៦០ ដល់ឆ្នាំ១៩៩៥ យើងសង្កេតឃើញថា

ជំរៅទឹកក្នុងបឹងនេះពេលខែប្រាំងមានជំរៅពី១ ទៅ១ម៉ែត្រកន្លះ និងពេលរដូវវស្សាមានជំរៅពី៤ទៅ៥ម៉ែត្រ ការដែលធ្វើអោយបឹងនេះកាន់តែរាក់ ដោយសារពេលវេលាចេះតែយូរឆ្នាំ ស្លឹកឈើ កំទេចកំទីផ្សេងៗរលួយធ្លាក់ចូលក្នុងទឹកបឹងធ្វើអោយទឹកកាន់តែរាក់ទៅ។ នៅកំឡុងនោះ ព្រៃលិចទឹកនៅតំបន់នេះមានសល់មិនច្រើនណាស់ទេ ដោយសារប្រជាពលរដ្ឋនៅទីនោះនាំគ្នាវាតព្រៃធ្វើស្រែប្រាំង និងកាប់ដីធ្វើចំការតាមមាត់បឹង។ ដោយសារព្រៃនៅតំបន់នេះមានការថយចុះមិនក្រាស់ក្រែលដូចមុនធ្វើអោយប្រភេទសត្វស្លាបមិនសូវសំបូរទេ ចំនែកមច្ឆាជាតិមានការថយចុះខ្លះដែរ នៅ-មានប្រហែលជា១៥ប្រភេទប៉ុណ្ណោះប្រភេទត្រីសណ្តាយ ត្រីឆ្លាំង ត្រីឆ្តោរ ត្រីរ៉ស់ ត្រីដំរី ត្រីក្រាយ ត្រីខ្ជឹង ត្រីក្រាញ់ សល់សុទ្ធតែជាប្រភេទ ត្រីដែលមានទំហំមិនសូវធំៗដូចពីមុននោះទេ ដោយសារឧបករណ៍នេសាទចេះតែវិវត្តន៍ដូចជា ឆ្នុក បៀ អង្រុតលប អួនដែលមានក្រឡាទំហំ៣ ទៅ៤ហ៊ុន។ អ្នកដែលតែងតែមករកនេសាទត្រីនៅទីនេះសំបូរទៅដោយអ្នកនៅក្នុងឃុំស្រយ៉ូវនេះ និងអ្នកមកពីតំបន់ផ្សេងទៀតដូចជាមកពីស្រុកបារាយណ៍ ចំការលើ ស្ទឹងសែន សន្ទុក និងកំពង់ចាមតែងមកនេសាទត្រីនៅបឹងនេះជារៀងរាល់ឆ្នាំ។ គាត់បានអោយដឹងទៀតថាលុះដល់កំឡុងឆ្នាំ ១៩៩៥ ដល់បច្ចុប្បន្ននេះតំបន់បឹងផ្សោតនេះគ្មានព្រៃទៀតទេ ទីនោះក្លាយទៅជាវាលស្រែប្រាំង និងចំការអស់ហើយចំនែកសត្វស្លាបបានបាត់បង់អស់ហើយ នៅសល់តែសត្វកុកបន្តិចបន្តួចតែប៉ុណ្ណោះ ចំណែកសត្វព្រៃដូចជាដំរី ខ្លា រមាំង គោព្រៃ ឈ្លូស និងសត្វជាច្រើនទៀត គេពុំដែលជួបប្រទះឡើយនៅក្នុងតំបន់នេះ ម្យ៉ាងទៀតដោយសារតែ

សង្គ្រាម និងការចង់មានចង់បានរបស់មនុស្សបានធ្វើអោយក្លាយទៅជាចំណីរបស់មនុស្សអស់ទៅហើយ។ នៅពេលបច្ចុប្បន្ននេះធនធានមច្ឆាជាតិបានបាត់បង់ស្ទើរទាំងអស់ហើយប្រភេទត្រីជាច្រើនត្រូវបាត់អស់នៅសល់តែត្រីតូចៗ។ ចំណែកក្រពើ ពស់ អណ្តើក កន្ធាយក៏ពុំឃើញមានមិនមានទៀតដែរ ដោយសារការលោភលន់របស់មនុស្សចង់បានតែច្រើនប្រើឧករណ៍សុទ្ធតែទំនើបៗដូចជា ឆក់ អួន ស្បៃមុង អួនប្រយុងដែលមានក្រឡា២ហ៊ុន និងមានល្អិតៗជាងនេះទៀត ការជីកបៀ និងឧបករណ៍ល្មើសច្បាប់ជាច្រើនទៀត។

គាត់ពិនិត្យឃើញថាធនធានធម្មជាតិរបស់ប្រទេសយើង សព្វថ្ងៃមានការធ្លាក់ចុះខ្លាំងណាស់ បើប្រៀបទៅនឹងសម័យមុនដែលធ្លាប់តែសំបូរហូរហៀរបានរលាយស្ទើរតែបាត់អស់ទៅហើយ។ ត្រីជាធនធានមួយដ៏សំខាន់របស់យើងដែលធ្លាប់តែសំបូរក្រាស់ក្រែល ហើយជាប្រទេសដែលធ្លាប់តែនាំចេញទៅប្រទេសគេ តែឥឡូវនេះសូម្បីតែប្រជាពលរដ្ឋដែលនៅក្នុងស្រុកក៏ផ្គត់ផ្គង់មិនគ្រប់គ្រាន់ដែរ។ ដូច្នេះយើងគួរតែពិនិត្យមើលឡើងវិញ និងរិះរកវិធីសាស្ត្រណាដើម្បីថែរក្សាការពារធនធានធម្មជាតិរបស់យើងអោយបានល្អ។ គាត់សុំរាជរដ្ឋាភិបាល ក្រុមប្រឹក្សាឃុំ និងអ្នកជំនាញជួយផ្សព្វផ្សាយ ពង្រឹងច្បាប់នេសាទ និងការគ្រប់គ្រងធនធានធម្មជាតិ ដើម្បីអោយធនធានធម្មជាតិទាំងនេះសំបូរដូចពីមុន ។

# ប្រវត្តិបឹងតាសែង

លោកតា **ញ៉ុញ ឌឹប** អាយុ ៩៥ ឆ្នាំ ប្រពន្ធ ឈ្មោះ នួន លឹម អាយុ ៨៦ឆ្នាំ រស់នៅភូមិកំរ៉ែង ឃុំស្រយ៉ូវ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ពីមុនលោកតាជាអ្នកធ្វើស្រែផង នេសាទត្រីផង បច្ចុប្បន្ននេះលោកក្លាយជាចាស់ព្រឹទ្ធាចារ្យម្នាក់នៅក្នុង។

គាត់បានរៀបរាប់អោយដឹងថា កាលពីជំនាន់គាត់នៅក្មេង គាត់ធ្លាប់បានទៅឃ្វាលគោ ក្របី និងរកត្រីនៅបឹងតាសែងជាប្រចាំខួបប្រាំង លុះដល់រដូវវស្សាទើបត្រឡប់មកផ្ទះវិញ កាលនោះមានតាម្នាក់ឈ្មោះ តា អ៊ូច ជាអ្នកនៅចាំបឹងនេះទាំងប្រាំង ទាំងវស្សា រកត្រីផងនិងជួយមើលការខុសត្រូវអ្នកដែលមករកត្រីផង។ បឹងតាសែង កាលពីដើមជាបឹងមួយធំល្វឹងល្វើយ នៅរដូវវស្សាទឹកបឹងមានកំពស់ប្រហែលពី៧ទៅ១០ម៉ែត្រ នៅរដូវប្រាំងកំពស់ប្រហែល២ទៅ៣ម៉ែត្រ។ បឹងនេះមានរាងពងក្រពើមានបណ្តោយប្រហែល ៨០០ម៉ែត្រ និងទទឹងប្រហែលជាង ៥០០ម៉ែត្រ នៅជ្រុងខាងត្បូងបឹងមានព្រែកមួយធ្លាក់ទៅស្ទឹងស្លាប់ ចំងាយប្រហែល២គីឡូម៉ែត្រ។ នៅជុំវិញបឹងនេះមានព្រៃរនាមក្រាស់ពន្ធ័ជុំវិញមាត់បឹងដូចជា ត្រស់ សណ្តាន់ ភ្កុំភ្លែង តាអួរ អញ្ចាញ រាំង ខ្ទុំ និងមានដើមតាសែងធំមួយដើមទំហំប្រហែល២អោប នៅជ្រុងខាងជើង ខាងក្រោមមានរោងអ្នកតាមួយ ហៅឈ្មោះថាលោកតា សែង និង



លោកតា ញ៉ុប ឌិប

រូងក្រពើមួយធំនៅក្រោម។ ក្រពើនេះបើគេចង់លឺសំឡេងវា គេយកឈើទៅសំពង ដើមតាសែងនេះអោយខ្លាំងៗវានឹងគ្រហឹមដាក់វិញភ្លាម រូងក្រពើនៅមានរហូតដល់សព្វថ្ងៃ។នៅក្នុងបឹងមានទឹកថ្លាឈ្វង់ស្រឡះល្អល្ហេវមានសត្វស្លាបគ្រប់ប្រភេទដូចជា ស្មោញ ក្អែកទឹក ប្រវឹក ទុង ជាដើម។ ត្រីចំរុះស្មើរគ្រប់មុខ ពិសេសសំបូរត្រីធំៗដូចជា ត្រីខ្យា ត្រីសណ្តាយ ត្រីក្រាយ ត្រីគល់រាំង ដែលមានទំងន់រហូតដល់ទៅ ១០ គីឡូក្រាមឡើងទៅ។ ក្រៅពីត្រីមានក្រពើអន្សង អណ្តើក គន្ធាយធំៗ ពស់វែក ពស់ទ្រូងរនាម ថ្លាន់ ក្រចាន់ ព្រលឹត ទ្រមម សត្វភេ។ នៅតំបន់នេះ សំបូរដោយសត្វអក ទោម មាន់ព្រៃមាន់ទឹក កុក ក្រសា ទោម ពាសពេញព្រៃ ។ នៅក្នុងបឹងតាសែងនេះ កន្លែងទឹកជ្រៅពុំសូវមានមនុស្សហ៊ានចុះទេ គេខ្លាចជួបក្រពើអ្នកតា តែក្រពើនេះមិនដែលខាំទេ គ្រាន់កល់ទូកម្តងម្កាលតែប៉ុណ្ណោះ។ ទូកដែលចុះអុំនៅបឹងនេះបានលុះត្រាតែទូកធំៗប្រវែងពី ៦ទៅ៧ម៉ែត្រឡើងទៅ ព្រោះខ្លាចរលកបោកលិច។ បឹងតាសែងជាបឹងមានប្រភពទឹកចេញកន្លងមកបង្ហូរមិនរីងស្រកអស់បណ្តើរថែមពេញវិញបណ្តើរ។ កាលសម័យសង្គមរាស្ត្រនិយមមានយួន ឈ្មោះ យ៉យ មានប្រពន្ធឈ្មោះ ភ្លឹងបានជួលអ្នកស្រុកអោយស្ការព្រែក ហើយជួលអ្នកមានដីរ ក្របី



**ទិដ្ឋភាពបឹងតាសែងមើលពីចំងាយ**

មួយថ្ងៃ ៥០០រៀលអោយជិះដើរសារចុះឡើង១ក្នុងព្រៃកធ្វើអោយព្រៃកជ្រៅមុខទឹកធំ ហូររហ័សអស់ពីបឹងដើម្បីចាប់យកត្រី ទោះបីខំប្រឹងអស់លទ្ធភាពយ៉ាងណាក៏ទឹកបឹងមិនរីងដែរ ស្រកព្រឹក ពេញល្ងាច ស្រកល្ងាច ពេញព្រឹកដដែលធ្វើអោយឃួន យ៉យ អស់ចិត្តធ្វើមិនកើតទើបឈប់បង្ហូរ ។

នៅរដូវប្រាំងបឹងតាសែង ជាកន្លែងប្រជុំជនប្រមូលផ្ដុំទៅដោយ អ្នករកត្រីធ្វើប្រហុក ផ្អក និងជាកន្លែងដំណាក់សំរាប់ឈប់សំរាកដាំបាយដាំ ហូបចុក សំរាកអោយទឹកគោទឹកក្របីមុននឹងចេញដំណើរបន្តរទៅបឹងក្រោមទៀត រឺក៏ឡើងទៅភូមិលើវិញឯមួយចំណែកទៀតក៏ជាកន្លែងជិរកសត្វព្រៃ ដំរី ប្រើស រមាំង ជ្រូកព្រៃ ម្ដងម្កាល មួយរយៈពេលបណ្ដោះអាសន្ន នៅពេលឡើងពីវាលក្រោមទៅភ្នំ។ តាមទំនៀមទំលាប់ប្រពៃណីខ្មែរពីដើម ក្រោយពីបានមកដល់បឹងហើយ អ្នកស្រុកតែងតែទៅសែនបាយ៉ាប មានម្លូស្លា មែកឈើ ទាន ធូប ស្រាកូនដបភ្ជួរនៅដើមតាសែង ដើម្បីបន់ស្រន់សុំអោយលោកតាជួយថែរក្សាការពារអោយបានសុខចំរើន និងរកត្រីអោយបានច្រើនធ្វើប្រហុក ផ្អក ឆ្អើ ត្រីងៀតហូបគ្រប់គ្រាន់ប្រចាំឆ្នាំ។ ចំពោះអ្នកស្រុកដែលមកនៅរកត្រីក្នុងបឹងនេះគឺមានច្រើនមកពីស្រុកសន្ទុក ស្រុកបារាយណ៍ អ្នកភូមិរកា ភូមិកំរ៉ែង ម្នាវ ពុកយុក មានរទេះគោក្របីមនុស្សចាស់ ក្មេង ប្រុសស្រី ធ្វើខ្ទមនៅជិតមាត់បឹងនោះ ហើយចងគោក្របីកណ្ដាលការពារចោរលួចពេលយប់ ពេលថ្ងៃគេនាំគ្នាទៅរកត្រីជាពួកជាក្រុមតាមការឯកភាពគ្នា។ ការប្រើប្រាស់ឧបរកណ៍រកត្រីនៅពេលនោះគឺមានមង អួនអូស សន្ទូចចង ស្ន ត្រីដែលរកបាននៅទីនេះច្រើនតែត្រីធំ១ ហើយមិន

ចេះអស់ទេ។ ធនធាននៅក្នុងបឹងនេះបានត្រូវបាត់បង់ជាហូរហែរពីឆ្នាំ១៩៩៥ រហូតដល់ឆ្នាំ២០០៥ ស្ទើរអស់ទៅហើយនៅសល់តែទឹកបឹងនៅមានច្រើននៅឡើយ ខ្ចបប្រាំង ខ្ចបវស្សា ចំណែកត្រីវិញទោះជាតូចតាចក៏រកហូបចង់លែងបានទៅហើយ ដោយសារ-មានភាពអនាធិបតេយ្យ មិនគោរពច្បាប់ ប្រជាពលរដ្ឋចង់មានហួសហេតុឥតពិចារណាអំពីវាសនាបរិស្ថាន និងគ្រោះថ្នាក់ធម្មជាតិទៅអនាគតកាល ដូចជាព្រៃរនាមត្រូវកាប់បំផ្លាញរានដីធ្វើស្រែប្រាំង និងដាក់សំរាស់យកត្រី ក្រពើ អណ្តើក កន្ធាយត្រូវបានគេឆក់ ដាក់ថ្នាំបំពុលចាប់យកអស់។ ជាក់ស្តែងនៅឆ្នាំ២០០៣ បឹងតាសែងនេះត្រូវបានពួកល្មើសយកថ្នាំបំពុលរបស់កសិកម្មយកមកបំពុលត្រីធ្វើអោយត្រីទាំងតូច ធំរាប់តោនត្រូវបានពុលស្លាប់ ហើយមានអ្នកស្រុកជិតឆ្ងាយរហូតដល់ស្រុកសន្ទុក បានមករើសត្រីនោះធ្វើប្រហុក និងហូប ចំពោះអ្នកបានហូបត្រីទាំងប៉ុន្មាននោះ មានខ្លះហើមពោះរាគ ខ្លះស្ទើរស្លាប់ក៏មាន។ ក្រោយមកនៅ ក្នុងឆ្នាំ២០០៤នេះយើងឃើញថាមានក្រចាប់ឈ្មូក និងសារាយដុះច្រើបនពាសពេញ ក្នុងបឹង។

តាមការប៉ាន់ស្មានរបស់លោកតាប្រហែលក្នុងរយៈកាល១០ឆ្នាំទៀត បឹងតាសែងរាក់ ហើយរីងអស់ទឹកអស់ត្រី ដោយសារការកាប់ព្រៃរនាមជារបាំងទប់ទឹកកុំអោយច្រោះដីចូលបឹង ការរានយកដីធ្វើស្រែប្រាំង និងការបូមទឹកដាក់ស្រែប្រាំងដែលកំពុងកើនឡើងយ៉ាងច្រើនជារៀងរាល់ឆ្នាំ។ នៅឆ្នាំ២០០៤ មានអ្នកធ្វើស្រែប្រាំងតិចតួចតែនៅឆ្នាំ២០០៥នេះមានជាង៣០គ្រួសារ ហើយបានមកវាតដីមាត់បឹងធ្វើស្រែចំការ ។

ដូច្នេះគាត់បានសុំអោយរដ្ឋអំណាចមូលដ្ឋានគ្រប់ជាន់ថ្នាក់មានវិធានការទប់ស្កាត់

ការកាប់ឆ្ការព្រៃមាត់បឹងធ្វើស្រែប្រាំងច្រើនហួសហេតុ។ គួរតែមានវិធានការបង្ក្រាប បទល្មើស ឆក់ បំពុលត្រីអោយបានម៉ឺងម៉ាត់តឹងរឹង ចាប់ផាកពិន័យផង ដាក់គុកផង កុំអោយមានអ្នកការពារអ្នកឆក់ អ្នកបំពុល ដែលធ្វើអោយសម្បត្តិធម្មជាតិរបស់យើងត្រូវរលាយសាបសូន្យអស់ មិនត្រឹមតែធនធានធម្មជាតិជាតិទេដែលត្រូវបាត់បង់សូម្បីតែមនុស្សក៏ត្រូវរងទុក្ខវេទនាដែរ ។

# ប្រវត្តិបឹងភក់

តាមការសំភាសន៍លោក **ឡុង ភឿក** មានអាយុ៦៥ឆ្នាំ ក្នុងភូមិរកា ឃុំស្រយ៉ូវ ស្រុកស្ទឹងសែន ខេត្តកំពង់ធំបានមានប្រសាសន៍ថា គាត់គឺជាអ្នកនេសាទ និងឃ្វាលគោក្របីនៅបឹងភក់តាំងពីតូចរហូតមកដល់បច្ចុប្បន្នបានអោយដឹងថាបឹងភក់គឺបឹងមួយដែលពីដើមស្ថិតនៅក្នុងភូមិរកា ឃុំស្រយ៉ូវ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ



**លោក ឡុង ភឿក**

បើយើង ធ្វើដំណើរពីកំពង់ធំឆ្លងកាត់តាមភូមិរកាទៅបឹងនេះមានចំងាយប្រហែល១៣ គីឡូម៉ែត្រ តែបើគិតពីភូមិរកាទៅបឹងវិញមានចំងាយប្រហែលពី៣ទៅ៤គីឡូម៉ែត្រ និងពីបឹងភក់ទៅបឹងទន្លេសាបវិញចំងាយប្រហែល១៥ ទៅ២០គីឡូម៉ែត្រ។ បឹងនេះមានប្រវែង៣៦០ម៉ែត្រទទឹង ១៥០ម៉ែត្រ នៅរដូវប្រាំងមានជំរៅពី២ទៅ ៣ម៉ែត្រ និងនៅរដូវវស្សាមានជំរៅពី៥ ទៅ៦ម៉ែត្រ។ បឹងភក់នេះពីដើមសំបូរទៅដោយព្រៃរនាមយ៉ាងក្រាស់នៅព័ទ្ធជុំវិញមាត់បឹងដូចជាដើមភ្នំភ្លែង ត្រស់ អញ្ចាញ និងមានដើមឈើធំៗមួយចំនួនដូចជា ដើមរាំង ខ្ទុំ ។ល។ គាត់មានប្រសាសន៍បន្តទៀតថា ពីដើមមានហ្វូងដំរីធ្វើដំណើរពីភ្នំសន្ទុកទៅមកតំបន់វាលទន្លេ-សាបតែងតែឆ្លងកាត់បឹងនេះហើយតែងសំរាករយៈពេល២ ទៅ៣ថ្ងៃ នៅក្នុងបឹងនេះជារៀងរាល់ឆ្នាំនៅរដូវទឹកសំរក។ ដោយសារតែបឹងនេះជាកន្លែងដែលដំរីឆ្លងកាត់ និង

សំរាកនៅបឹងនេះទើបធ្វើអោយផ្ទៃបឹងបែកភក់ និងល្អក់ទឹកបឹងពាសពេញ ដោយហេតុនេះទើបគេដាក់ឈ្មោះ **បឹងភក់** រហូតដល់សព្វថ្ងៃ ។



ទិដ្ឋភាពបឹងភក់មើលពីចំងាយ

តាមប្រសាសន៍តានិងចាស់ទុំក្នុងភូមិបានអោយដឹងទៀតថា កាលពីមុននៅតំបន់នេះសំបូរទៅដោយធនធានធម្មជាតិ និងសត្វគ្រប់ប្រភេទ។ ចំពោះសត្វដែលគាត់ឃើញមានសំបូរពីសម័យនោះរួមមាន សត្វឈ្លូស រមាំង ជ្រូកព្រៃ ស្វា និងសត្វស្លាបជាច្រើនប្រភេទដូចជា: មាន់ទឹក ប្រវឹក ក្រសា កុក ទោម ស្មោញ ត្រដក់ ក្រៀល និងសត្វជាច្រើនប្រភេទទៀត។ ចំណែកឯធនធានមច្ឆាជាតិវិញសំបូរទៅដោយ ត្រីក្រាយ ត្រីក្រម៉ម ត្រីសណ្តាយ ត្រីគល់រាំង ត្រីឆ្តោរ ត្រីដឹរី ត្រីទនេល ត្រីខ្ជឹង ត្រីកេស លក្ខណៈពិសេសរបស់បឹង នេះសំបូរត្រីច្រើនជាង គេគឺត្រីក្រាយ ចំណែកត្រីរ៉ស់ រីត្រីឆ្តោរវិញមិនសូវសំបូរប៉ុន្មានទេ។ គាត់មានប្រសាសន៍ទៀតថា ដោយបឹងនេះសំបូរទៅដោយមច្ឆាជាតិ ហើយស្ថិតនៅមិនឆ្ងាយពីភូមិ និងងាយស្រួលសំរាប់ប្រជាពលរដ្ឋក្នុងការទៅមករកនេសាទ ទើបធ្វើឱ្យគេចូលចិត្តមកនេសាទនៅបឹងនេះណាស់មិនត្រឹមតែអ្នកនៅក្នុងស្រុកទេ ថែមទាំងមានអ្នកមកពីសន្ទុក បារាយណ៍ ស្ទឹងសែន និងមួយចំនួនទៀតមកពីខេត្តកំពង់ចាម តែងតែមកនេសាទនៅទីនេះ។ កាលពីដើមឡើយគេច្រើនទៅនេសាទចាប់តាំងពីខែកុម្ភៈ ទៅដល់ខែមេសា ទើបបានត្រឡប់ទៅផ្ទះវិញ

ចំណែកអ្នកនេសាទមួយចំនួនទៀតនេសាទទាំងប្រាំង និងទាំងវស្សា។ កាលពីសម័យនោះប្រជានេសាទនិយមប្រើប្រាស់ឧបករណ៍សាមញ្ញដូចជា អង្រុត ឆ្នុក ជុច លាយ ស្ទូ អួនធ្វើពីធ្មៃដែលមានទំហំពី ៥ទៅ ៧ហ៊ុន ពីព្រោះថានៅបឹងនេះសំបូរទៅដោយត្រីធំៗដូចជា ត្រីសណ្តាយ ត្រីក្រាយ ត្រីគល់រាំងមានទំងន់ពី៧ ទៅ៨គីឡូក្រាម។ ចំពោះត្រីដែលមានទំងន់ចាប់ ពី១០គីឡូក្រាមឡើង នៅពេលដែលពួកគាត់នេសាទបានហើយតែងព្រលែងវាទេវិញ ពីព្រោះពួកគាត់គិតថាវាជាត្រីមេបឹង និងជាស្តេចត្រី ។ គាត់បានបញ្ជាក់ទៀតថា ប្រជាពលរដ្ឋនៅសម័យនោះមិនចេះលក់ដូរទេ គឺច្រើនតែចែកគ្នាហូបនៅសល់ប៉ុន្មាន គេច្រើនយកមកធ្វើប្រហុក ផ្អក ត្រីប្រលាក់ ដោយយកតែត្រីធំៗដូចជាត្រីសណ្តាយ ត្រីរ៉ស់ ត្រីឆ្តោរ និងទុកហូបសំរាប់រដូវវស្សា។ គាត់បានបញ្ជាក់ទៀតថា ក្នុងភូមិបានអោយដឹងថា ដោយសារជីវភាពរបស់ប្រជាពលរដ្ឋនៅស្រយ៉ូវ និងសន្ទុកពឹងពាក់លើតំបន់នេះ។ នៅឆ្នាំ១៩៨២ ដល់ឆ្នាំ១៩៩៥ កំនើនប្រជាជននៅឃុំស្រយ៉ូវ និងសន្ទុកកាន់តែកើនឡើង ទើបធ្វើឱ្យតំរូវសំរាប់ការចិញ្ចឹមជីវិតកាន់តែកើនឡើងរធ្វើអោយតំបន់បឹងនេះត្រូវគេកាប់ព្រៃលិចទឹក និងព្រៃជាប់ជុំវិញមាត់បឹងធ្វើស្រែ និងចំការរបស់បុគ្គលម្នាក់ៗជាកម្មសិទ្ធិស្ទើរតែអស់ទៅហើយ។ ដោយហេតុធ្វើអោយសត្វស្លាបគ្មានជំរករស់នៅ សត្វស្លាបចំនួនត្រូវបង្ខំចិត្តចាកចេញពីតំបន់នេះ នៅសល់តែសត្វបន្តិចបន្តួចដូចជា សត្វកុក ក្រសា មាន់ទឹក ប្រវិកតែប៉ុណ្ណោះ ចំនែកសត្វធំៗវិញនៅសល់តែឆ្កែចចក និងហ្វូងសត្វជ្រូកព្រៃ ឈ្លូសបាត់បង់តាំងពីសម័យឆ្នាំ១៩៧០។ ចំណែកមច្ឆារស់នៅបឹងនេះ វិញមានត្រីធំៗដូចជា ត្រីក្រាយ ត្រីសណ្តាយ ដែលមានទំងន់ពី២ ទៅ៣គីឡូក្រាម ប៉ុណ្ណោះ។ គាត់ក៏មានប្រសាសន៍

ទៀតថា មកដល់បច្ចុប្បន្ននេះ ព្រៃលិចទឹកនិងព្រៃរនាមនៅតាមមាត់បឹងទាំងឡាយ ក៏ក្លាយទៅជាដីស្រែវស្សា និងចំការទាំងស្រុងអស់ហើយ បឹងដែលធ្លាប់តែមាន ជំរៅពី៤ ទៅ៥ម៉ែត្រ ក្លាយទៅជាបឹងមានជំរៅនៅសល់ជំរៅតែ១ទៅ ១,៥ម៉ែត្រ ក្នុងរដូវប្រាំង ចំណែកក្នុងរដូវវស្សានៅត្រឹមតែ២,៥ម៉ែត្រ ទៅ៣,៥ ម៉ែត្រប៉ុណ្ណោះ។ សត្វស្លាបធ្លាប់តែមានច្រើនគ្រប់ប្រភេទនៅសល់តែ កុក មាន់ទឹក ប្រវឹក ហើយស្ទើរតែគ្មានទៀតផង ចំនែកមច្ឆាជាតិវិញឃើញកាន់តែថយចុះគួរអោយចាប់អារម្មណ៍ ព្រោះនៅសល់តែត្រីកាហែរមានទំងន់ពី១ ទៅ១,៥០គីឡូក្រាមប៉ុណ្ណោះ។ ប៉ុន្តែត្រីក្រាយផុតពូជអស់ទៅហើយ ចំពោះការបាត់បង់ទាំងធនធានធម្មជាតិ និងមច្ឆាជាតិបក្សាបក្សី ព្រមទាំងសត្វតូចធំ ដោយសារតែការប្រើប្រាស់ឧបករណ៏ទំនើបដូចជា ឆក់ អួន ក្រឡាញ៉ឹក ការកើនឡើងពីប្រជានេសាទ និងការប្រែប្រួលពីធម្មជាតិ ការកាប់ ព្រៃ ការដុតព្រៃ ការបំពុល និងការវាយលុប ។

ដោយពិនិត្យឃើញបែបនេះពួកគាត់យល់ថា ធនធានរបស់យើងកាលពីមុនធ្លាប់តែសំបូរហូរហៀរ តែឥឡូវប្រភេទខ្លះត្រូវបានផុតពូជអស់ទៅហើយ ដូចនេះក្នុងនាមគាត់ តំណាងអោយប្រជាពលរដ្ឋខ្មែរសូមសំណូមពរដល់អាជ្ញាធរ ព្រមទាំងអង្គការជាតិ និងអន្តរជាតិសូមជួយលុបបំបាត់នូវឧបករណ៏ខុសច្បាប់ នាំគ្នាជួយអភិរក្សបឹង និងព្រៃឡើងវិញ និងសុំអោយអ្នកដែលមានអំណាចធំៗជួយពង្រឹងការអនុវត្តន៍ច្បាប់អោយបានល្អដើម្បីអោយធនធានធម្មជាតិនៅប្រទេសយើងនៅឋិតថេរ និងសំបូរសប្បាយដូចពីមុនទៀត ។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

# សេចក្តីអំពាវនាវ

ដើម្បីទទួលបាននូវមតិចូលរួមឱ្យបានទូលំទូលាយពីគ្រប់ផ្នែក វិស័យឯកជន សហគមន៍ និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមជម្រាបជូនឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី ថ្នាក់ដឹកនាំក្រសួង ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួង ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត និងនាយកក្រុមហ៊ុនវិនិយោគលើវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទាំងអស់ សូមមេត្តាជ្រាបថា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងរៀបចំវេទិកាកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១៩ នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៩ ខាងមុខនេះ នៅទីស្តីការក្រសួង អគារផ្ការំដួល សាលប្រជុំធំសែនពិដោរ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមអំពាវនាវចំពោះឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រីទាំងអស់មេត្តាជួយឧបត្ថម្ភថវិកាទៅតាមសមានចិត្តជ្រះថ្លាចូលរួមក្នុងការរៀបចំកម្មវិធីខាងលើនេះ ឱ្យទទួលបានជោគជ័យ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានក្តីសង្ឃឹម និងរង់ចាំទទួលអំណោយសប្បុរសរបស់ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រីគ្រប់ពេលវេលាតាមរយៈខុទ្ទកាល័យរដ្ឋមន្ត្រី និងនាយកដ្ឋានកិច្ចការរដ្ឋបាល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

សូម ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី ជួបប្រទះតែសុភមង្គល វិបុលសុខ និងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃ៧ ៨ ៩ កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**សូមផ្តល់ថវិកាតាមរយៈ:**

-ឯកឧត្តម ចាន់ ហេង (ទូរស័ព្ទ៖ ០១២ ៨៤១ ៤២៥)

-លោក ជា ច័ន្ទវាសនា (ទូរស័ព្ទ៖ ០១២ ៨៤១ ៨៦៧)

-លោក ប៊ុន កាដេត (ទូរស័ព្ទ៖ ០១៦ ៣៣៤ ៣៣៩)

បឹងទន្លេសាប គឺជាបឹងមួយ ដែលផ្តល់នូវសារៈប្រយោជន៍យ៉ាងច្រើន ដល់ប្រជាពលរដ្ឋកម្ពុជាដែលរស់នៅជុំវិញបឹងនេះ ដូចជា ត្រីផ្តល់នូវជាតិប្រូតេអ៊ីន ប្រភពទឹក ព្រៃលិចទឹក ប្រព័ន្ធអេកូឡូស៊ី និងធម្មជាតិដ៏រស់រវើក។ មុនទសវត្សរ៍ឆ្នាំ៧០ បឹងទន្លេសាបសំបូរដោយត្រីគ្រប់ប្រភេទ ហើយគេអាចនេសាទបានទិន្នផលត្រីយ៉ាងច្រើនលើសលប់ ។



បច្ចុប្បន្ននេះ ផលត្រីនៅក្នុងបឹងទន្លេសាប បានធ្លាក់ចុះយ៉ាងខ្លាំង និងគំរាមកំហែងដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដែលពឹងផ្អែកលើធនធានត្រីជាចំបង ។